ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 11-Dec-2012, 08:30
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២**

**ម៉ោង ០៩: ០៥នាទី**

**សវនាការលើកទី១៣៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម យូរ ឧត្ដារា

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ដាវ អានសាន

លោក រ៉ូជឺ ហ្វីលីព*(Mr.Roger Phillips)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ត់

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ

*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក វ៉េន ពៅ

លោក ឡោ ជុនធី

លោក សំ សុគង់

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ហ្សាស្តេី ប៉ៅ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក វ៉ែន ពៅ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ហ៊ុន ឈុនលី (TCW-247) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ហ៊ុន ឈុនលី** (TCW-247)

សួរបន្តដោយលោក អាប់ឌុលឡាក់ ថារីក ផ្តើមពី៖....................ទំព័រ ២
សួរដោយលោក វ៉ែន ពៅ ផ្តើមពី៖....................ទំព័រ ៩
សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ផ្តើមពី៖....................ទំព័រ ២១
សួរដោយ លោក សុន អរុណ ផ្តើមពី៖....................ទំព័រ ២៩
សួរដោយលោក ហ្សាស្តេ ប៉ៅផ្តើមពី៖....................ទំព័រ ៣៥
សួរដោយចៅក្រម ស៊ីវៀល ខាតវ៉ាយថ៍ ផ្តើមពី៖....................ទំព័រ ៦៤
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី៖....................ទំព័រ ៧២
សួរដោយលោក គង់ សំអុន ផ្តើមពី៖....................ទំព័រ ៨០

# **កិច្ចដំណើរការនីតិវិធី**

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៥:០៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី ហ៊ុន ឈុនលី។ ហើយមន្ត្រីក្រឡាបញ្ជីសវនាការ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមាន ភាគី និងបុគ្គល ដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្តីមានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ ដោយមូលហេតុសុខភាព។ លោក អាង ឧត្តម ដែលជាមេធាវីការពារក្តីជាតិឲ្យលោក អៀង សារី នឹងមកដល់សាលសវនាការយឺតបន្តិច។ សាក្សីដែលត្រូវបន្តស្តាប់សក្ខីកម្មថ្ងៃនេះ គឺលោក ហ៊ុន ឈុនលី។ សាក្សីរូបនេះមានវត្តមាន។ សម្រាប់សវនាការថ្ងៃនេះ មិនមានសាក្សីបម្រុងនោះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។ ប៉ុន្តែមុននឹងជូនទៅសូមលោក -- សូមរំឭកដល់តំណាងសហព្រះរាជអាជ្ញាថា ទាំងតំណាងសហព្រះរាជអាជ្ញា ទាំងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានពេលវេលាតែមួយពេលទៀតទេ គឺពីនេះទៅរហូតដល់ពេលសម្រាកព្រឹកនេះ។ ទី១។ ទី២ សូមរំឭកថា នៅក្នុងកិច្ចដំណើរការសវនាការនេះ សូមឲ្យមានការតាំងសំណួរដេញដោលនៅក្នុងក្របខ័ណ្ឌវិសាលភាពនៃអង្គភាពសំណុំរឿង០០២/០១ ហើយនៅក្នុងអង្គហេតុពាក់ព័ន្ធជាមួយនឹងសាក្សីរូបនេះ គឺយើងកំណត់នៅក្នុងការអនុវត្តគោលនយោបាយជម្លៀស ហើយនិងរចនាសម្ព័ន្ធរដ្ឋបាលមូលដ្ឋាន។

[០៩:០៧:៣៧]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ជម្រាបសួរលោកវេជ្ជបណ្ឌិត ឈុនលី ដូចដែលលោកបានឮលោកប្រធានមានប្រសាសន៍ ហើយ គឺថាខ្ញុំមានពេលខ្លីណាស់។ ដូច្នេះ ខ្ញុំសូមឲ្យលោកឆ្លើយខ្លីសង្ខេបច្បាស់ នូវចំណុចពីរបីដែលខ្ញុំត្រូវសួរលោកនៅព្រឹកនេះ។ ពីម្សិលមិញយើងបាននិយាយគ្នាអំពីការបាត់ខ្លួនកម្មាភិបាលនៅភូមិភាគពាយ័ព្យខ្លះ ហើយនិងរចនាសម្ព័ន្ធអំណាច ហើយថ្ងៃនេះគឺថា ខ្ញុំនឹងសួរចំណុចពាក់ព័ន្ធមួយចំនួន ដែលលោកក៏បានរៀបរាប់នៅក្នុងសៀវភៅរបស់លោកផងដែរ។ នេះERN ខ្មែរគឺ 006778865, ERN អង់គ្លេស 00369758 ហើយដើម្បីជាប្រតិចារឹកថ្ងៃនេះគឺ ឯកសារ D313/1.2.8។ ខ្លឹមសារនៅក្នុងសៀវភៅនេះគឺថានិយាយអំពីខ្មាំងក្នុងជួរបក្ស គឺលោកសរសេរដូចខាងក្រោម ខ្ញុំសូមដកស្រង់៖ "... គឺមួយ គឺការប្រកាសជាផ្លូវការរបស់កម្មាភិបាលខ្មែរក្រហម និយាយអំពីការដកខ្លួន -- ដក ហ៊ូ នឹម រដ្ឋមន្ត្រីក្រសួងព័ត៌មាន ហើយសាច់ឈាមរបស់ ហ៊ូ នឹម ក៏ត្រូវគេយកទៅបាត់។ កម្មាភិបាលខ្មែរក្រហម គឺតាមដានរកអ្នកក្បត់"។ ខ្ញុំចង់និយាយអំពីការប្រកាសពាក់ព័ន្ធទៅនឹង ហ៊ូ នឹម រដ្ឋមន្ត្រីក្រសួងព័ត៌មាន។ លោកអាចជម្រាបជូនតុលាការបានទេថា លោកឮសូរការប្រកាសព័ត៌មានពាក់ព័ន្ធនឹង ហ៊ូ នឹម ហ្នឹងនៅកន្លែងណា?

[០៩:១០:០៥]

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ខ្ញុំបានឮការប្រកាសដកហូតរដ្ឋមន្ត្រី ហ៊ូ នឹម នេះ គឺនៅពេលយប់ៗក្រោយពីយើងធ្វើការងារពលកម្ម គេប្រជុំរួមទាំងអស់ ហើយគេប្រកាសអំពីការដកៗហូតរដ្ឋមន្ត្រី ហ៊ូ នឹម។ អាហ្នឹងគឺខ្ញុំឮផ្ទាល់នឹងត្រចៀក ហើយមិនមែនតែខ្ញុំទេ ឮទាំងអស់គ្នាបាទ។ ពីព្រោះថាពួកខ្មែរក្រហម គឺថាគេច្រើនតែពេលថ្ងៃ គេឲ្យបុគ្គលិក គេឲ្យពលករធ្វើការអ៊ីចឹង ហើយដល់ពេលល្ងាច ពេលយប់គេប្រជុំ។

**ស៖** សូមអរគុណដែលបានបញ្ជាក់ត្រង់ចំណុចនេះ។ ឥឡូវនេះ ខ្ញុំសូមចូលទៅផ្នែកមួយទៀតដែលលោកបានជម្រាបជូនសហព្រះរាជអាជ្ញាជាតិ គឺសុន្ទរកថាដែលលោកបានស្ដាប់ឮតាមវិទ្យុ សុន្ទរកថាដែលថ្លែងដោយ ខៀវ សំផន ដែលអានអំពីរដ្ឋធម្មនុញ្ញថ្មីនោះ។ លោកបានជម្រាបថា លោកបាន

ស្គាល់លោក ខៀវ សំផន នៅពេលដែលគាត់ធ្វើជាចាងហ្វាងកាសែតនៅទីក្រុងភ្នំពេញនោះ លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ លោកស្គាល់លោក ខៀវ សំផន ហ្នឹងដោយរបៀបណា?

[០៩:១១:៥៣]

**ផ៖** ខ្ញុំស្គាល់លោក ខៀវ សំផន ក្នុងឋានៈលោក ខៀវ សំផន ជាបញ្ញវន្តមួយរូប និងជាប្រធានកាសែត ឡុបសែវ៉ាទ័រ បាទ។ មិនមែនស្គាល់ជិតដិតទេ គ្រាន់ស្គាល់ដូច្នេះបាទ។ ហើយការដែលថា ការដែលថាលោក ខៀវ សំផន ៗអានរដ្ឋធម្មនុញ្ញនោះ ត្រូវតែនិយាយភ្ជាប់ជាមួយៗសម្តេច សីហនុ ដែរ ពីព្រោះពេលនោះឯងនៅមន្ទីរពេទ្យយោធា ប្រធានមន្ទីរពេទ្យបានប្រជុំបុគ្គ -- ហៅបុគ្គលិកមកធ្វើប្រជុំគ្នា ហើយដាក់វិទ្យុមួយចំកណ្តាល បើកយ៉ាងខ្លាំងឲ្យស្តាប់។ ដូចខ្ញុំបានជម្រាបម្សិលមិញអ៊ីចឹង គឺថាមុនដំបូង គឺថាយើងឮស្នូរសម្តេច សីហនុ លោកប្រកាសលាលែងពីឋានៈប្រមុខរដ្ឋ ជាភាសាខ្មែរ ក្រោយមកជាភាសាបារាំង។ បន្ទាប់មកបានលោក ខៀវ សំផន បានគេប្រកាសលោក ខៀវ សំផន តែងតាំងជា "ប្រធានគណៈប្រធានរដ្ឋ"។ ហើយបន្ទាប់មកលោក ខៀវ សំផន ក៏អានសុន្ទរកថាដែលមានជាង២០ជំពូក ខ្ញុំចាំតែពីរ គឺថាជំពូកមួយនោះចែងថា "ប្រជាពលរដ្ឋគ្រប់គ្នាមានសិទ្ធិជឿ ឬមិនជឿសាសនា"។ ជំពូកមួយទៀតលោកអានថា លោកអាន "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិ មានការងារធ្វើគ្រប់គ្នា"។

[០៩:១៣:៥៨]

**ស៖** សូមអរគុណ។ បាទប្រតិចារឹកដែលយើងអាចរកបានចុះថ្ងៃទី៥ មករា ១៩៧៦ នៅក្នុងកំណត់នោះ មានកត់ត្រាសុន្ទរកថារបស់លោក ខៀវ សំផន។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតដើម្បីបញ្ចាំងបង្ហាញឯកសារនេះ ដើម្បីចង់សួរទៅសាក្សីថាតើគាត់អាចស្គាល់ឯកសារនេះ ឬអត់? E3/273 ចុះថ្ងៃទី០៥ មករា (១៩)៧៦ ជាប្រតិចារឹកដែលកត់ត្រាសុន្ទរកថារបស់លោក ខៀវ សំផន។ សូមការអនុញ្ញាតលោកប្រធាន ចង់សួរសាក្សីថាតើគាត់នៅចាំឯកសារនេះដែរឬក៏អត់?

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

**លោក អាប់ឌុលឡាក់ ថាវីក៖**

ខ្ញុំសូមអភ័យទោសផង គឺថាឯកសារនេះគឺសាក្សីមិនធ្លាប់ឃើញពីមុនទេ ខ្ញុំអាចអានជូនសាក្សីផងក៏បាន ហើយបង្ហាញសាក្សីក៏បាន បាទ។

**ប្រធានអង្គជំនុំ៖**

បើដឹងច្បាស់ថាសាក្សីអត់ដែលបានឃើញពីមុនហើយ ម៉េចក៏ឲ្យសាក្សីពិនិត្យមើល? ឯកសារណាដែលសាក្សីមិនបានឃើញពីមុន គឺមិនអនុញ្ញាតឲ្យបង្ហាញសាក្សីទេ។

**លោក អាប់ឌុលឡាក់ ថាវីក៖**

លោកប្រធាន យោងទៅតាមសេចក្តីណែនាំនេះ ខ្ញុំសូមមិនបង្ហាញឯកសារទេ។ ប៉ុន្តែដូចដែលអង្គជំនុំជម្រះចាំហើយ ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍បែបនេះ វាមានទំនាក់ទំនងរវាងឯកសារទៅនឹងភស្តុតាងដែលបានផ្តល់ជូនអង្គជំនុំជម្រះ។ គឺថាមានមូលដ្ឋានរបស់វាបែបនេះ គ្រាន់តែសួរថា តើមានខ្លឹមសារដូចដែលអ្វីសាក្សីធ្លាប់បានឮ ឬក៏អត់? ដូច្នេះ ខ្ញុំគ្រាន់តែសុំបង្ហាញនូវខ្លឹមសារនៃការដកស្រង់ខ្លី ថាតើដូចដែលអ្វីដែលគាត់បានឮដែរឬក៏អត់?

[០៩:១៦:២៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណច្រើនលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថាវីក៖**

**ស៖** លោកវេជ្ជបណ្ឌិត ហ៊ុន ឈុនលី ខ្ញុំសូមអានថាតើខ្លឹមសារនេះដូចអ្វីធ្លាប់ឮទេ គឺERN ជាភាសាខ្មែរ 00657436, ERN ជាភាសាបារាំង 00725795, ERN អង់គ្លេស 00167810។ គឺមានចំណងជើងថា "អត្ថបទវាយការណ៍របស់ឧបនាយករដ្ឋមន្ត្រី ខៀវ សំផន ស្តីអំពីសេចក្តីព្រាងរដ្ឋធម្មនុញ្ញដែលបានបង្ហាញជូននៅថ្ងៃទី១៤ ធ្នូ ៧៥ ក្នុងសមាជជាតិលើកទី៣នៅភ្នំពេញ"។

សូមដកស្រង់ "នៅពេលរៀបចំរដ្ឋធម្មនុញ្ញនេះ គឺថាយើងបានកម្ចាត់ចោលពួកក្បត់ដែលជាឫសគល់នៃពួកឈ្លានពានចក្រពត្តិអាមេរិក និងបរិវាររបស់វា។ ពួកអាក្បត់ លន់ នល់, សិរិមតៈ, សឺងង៉ុកថាញ់។ យើងគឺថាបានកម្ចាត់ពួកនេះពីភូមិមួយទៅភូមិ ចេញពីឃុំមួយទៅឃុំមួយ និងពីចេញពី

ស្រុកមួយទៅភូមិមួយ រហូតទាល់តែយើងបានបណ្តេញពួកវាចេញនៅទូទាំងប្រទេស"។

[០៩:១៨:០៥]

ហើយអត្ថបទមួយទៀត ដែលខ្ញុំសូមអានជូនផងដែរ។ ទី១ -- ខ្លឹមសារទី១ គឺថាដូចខាងក្រោម សូមដកស្រង់ "ប្រជាជនយើងទាំងអស់ គឺថាមានការងារធ្វើទាំងអស់គ្នា។ ដូច្នេះមិនមានអ្នកណាម្នាក់មិនមានការងារធ្វើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យរបស់យើង"។ ហើយខ្លឹមសារខាងក្រោម សូមដកស្រង់ "ជំពូក១៥ មាត្រា២០ ចែងថា ប្រជាជនរបស់យើងមានសិទ្ធិជឿសាសនាអ្វីដែលពួកគាត់អាចជឿទៅបាន គឺថាមិនមានអ្នកណាហាមឃាត់មិនឲ្យគោរពសាសនាណានោះទេ។ នេះគឺជាសិទ្ធិរបស់ប្រជាជនយើង។ ហើយក្នុងរដ្ឋធម្មនុញ្ញរបស់យើង គឺជំហររបស់យើងមិនអនុញ្ញាតឲ្យពួកចក្រពត្តិបរទេសប្រើប្រាស់សាសនាណាមួយ ដើម្បីធ្វើវិទ្ធង្សនាដល់យើងនោះទេ"។

លោកវេជ្ជបណ្ឌិត ហ៊ុន ឈុនលី តាមអ្វីដែលលោកបានឮ ហើយនិងចាំ តើខ្លឹមសារនេះជាខ្លឹម-សារនៃសុន្ទរកថាដែលលោកបានស្តាប់ឮនៅពេលនោះដែរ ឬក៏យ៉ាងណា?

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** សូមជម្រាបថា ឯកសារនេះ ខ្ញុំមិនដែលបានឮទេ ហើយការសុន្ទរកថាលាលែងរបស់សម្តេច សីហនុ ក៏ខ្លីដែរ មិនវែងទេ។ លោកនិយាយច្បាស់ៗជាខ្មែរ ច្បាស់ៗជាបារាំង ហើយខ្លី។ ហើយចំពោះរដ្ឋធម្មនុញ្ញក៏ដូច្នេះដែរ មិនវែងទេបាទ។ ខ្ញុំមិនដែលឃើញឯកសារនេះទេ មិនដែលដឹង។

[០៩:១៩:៥១]

**ស៖** ខ្ញុំយល់ ប៉ុន្តែខ្ញុំគ្រាន់តែចង់សួរទៅលោកថា ពាក្យពេចន៍ដែលខ្ញុំអានអម្បាញ់មិញនេះ តើខ្លឹមសារ ឬក៏ពាក្យពេចន៍ទាំងអស់នេះ ពាក្យពេចន៍ខ្លះនេះ គឺជាពាក្យពេចន៍ ដែលលោកស្តាប់ ឮ ពីសុន្ទរកថារបស់លោក ខៀវ សំផន ពេលនោះដែរឬក៏យ៉ាង?

**ឆ៖** បាទ ពាក្យពេចន៍ដែលក្នុងឯកសារនេះ មិនមែនពាក្យពេចន៍ដែលលោក ខៀវ សំផន អាន ឬមួយសម្តេចអាននៅពេលៗប្រជុំនៅថ្ងៃនោះទេ បាទ។

**ស៖** សូមអរគុណ។ ខ្ញុំសូមចូលទៅផ្នែកមួយទៀត ដោយសារពេលវេលារបស់ខ្ញុំខ្លី ដូច្នេះ ខ្ញុំមិនអាចគ្របដណ្តប់ទៅដល់ផ្នែកទាំងអស់ ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធអំណាចនៅក្នុងភូមិពាយ័ព្យនោះទេ។ ជាពិសេសទាក់ទងទៅនឹងអ្វីដែលលោកធ្លាប់បានដឹង ប៉ុន្តែខ្ញុំសូមសួរលោក ពាក់ព័ន្ធបុគ្គលពីរនាក់។ ដុកទ័រដែលធ្វើការជាមួយលោកនៅក្នុងដំណាក់កាលមួយនោះ ក្នុងពេទ្យរបស់ខ្មែរក្រហម ជាពិសេស

វេជ្ជបណ្ឌិតពីររូបដែលលោកបានសរសេរនៅក្នុងសៀវភៅពីរបីកន្លែង គឺដុកទ័រ ហ៊ុន គឹមស៊ា (ស៊ីក) ដែលលោកបានរៀបរាប់ថា ជាប្រធានមន្ទីរសុខាភិបាលខេត្ត និងដុកទ័រ គឹមសាន។ លោកសាក្សី សូមឲ្យលោករៀបរាប់សង្ខេបបន្តិច នូវអ្វីដែលលោកបានដឹង ថាតើលោកបានដឹងថាមានអ្វីកើតឡើងចំពោះវេជ្ជបណ្ឌិតទាំងពីររូបនោះ គឺវេជ្ជបណ្ឌិត ឃឹម គឹមសាន និងវេជ្ជបណ្ឌិត ពឹង គឹមស៊ា?

[០៩:២២:១៥]

**ផ៖** បាទ លោកវេជ្ជបណ្ឌិត ឃឹម គឹមសាន ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើការនៅមន្ទីរពេទ្យថ្នាក់ស្រុក ឈ្មោះមន្ទីរពេទ្យ ព្រែកហ្លួង។ ចំពោះលោកវេជ្ជបណ្ឌិត ពឹង គឹមស៊ា គាត់ត្រូវបានចាត់តាំងឲ្យធ្វើការនៅមន្ទីរស្រុកមួយទៀត ឈ្មោះថា មន្ទីរពេទ្យសោមនស្ស ដែលមានទីតាំងនៅវត្តសោមនស្ស។ ហើយលោកវេជ្ជបណ្ឌិត ឃឹម គឹមសាន គឺថាបាត់ខ្លួន បន្ទាប់ពី -- លោកវេជ្ជបណ្ឌិតទាំងពីរនាក់នេះ គឺបាត់ខ្លួនជាបន្តបន្ទាប់ ក្រោយចូលឆ្នាំខ្មែរ ឆ្នាំ១៩៧៧។ នៅឆ្នាំ១៩៨០ ពេលដែលខ្ញុំមកបាត់ដំបង ខ្ញុំឃើញរូបថតលោក ឃឹម គឹមសាន នៅទួលស្លែង បាទ។ ទួលស្លែងឃើញរូបថតគាត់ច្បាស់នៅទួលស្លែង។ ចំពោះលោក ពឹង គឹមស៊ា ខ្ញុំបានឃើញតែឈ្មោះគាត់ នៅក្នុងបញ្ជីសៀវភៅ សៀវភៅដែលថា ខ្មាំងហ្នឹងឯង។ ដូច្នេះអ្នកទាំងពីរនាក់នេះ គឺថាបាន ត្រូវបានគេនាំមកទួលស្លែង។

**ស៖** សូមអរគុណលោកវេជ្ជបណ្ឌិត។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញជូនសាក្សីនូវបញ្ជីអ្នកទោសពីមន្ទីរស-២១ ថាតើគាត់អាចស្គាល់ឈ្មោះបុគ្គលនៅក្នុងបញ្ជីអ្នកទោសនេះដែរ ឬក៏អត់។ ឯកសារនេះគឺ D312.1.49។ បាទ ខ្ញុំមានឯកសារជាក្រដាស ខ្ញុំសូមបង្ហាញជូនសាក្សីផង។

[០៩:២៤:២០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៥:១៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជូនឯកសារជាក្រដាសទៅមន្ត្រីតុលាការ ដើម្បីជូនទៅសាក្សី

ហើយក៏សូមការអនុញ្ញាតបញ្ចាំងនៅលើអេក្រង់នេះ។ ហើយបង្ហាញជាភាសាខ្មែរ ដើម្បីឱ្យអ្នកអានភាសាខ្មែរគឺ ERN ពាក់ព័ន្ធនោះគឺជាភាសាខ្មែរ 00006618 ហើយជាភាសាអង់គ្លេស 00837537។

**អ្នកបកប្រែ៖**

បាទ សូមកែតម្រូវ ERN ជាភាសាខ្មែរ 00006623។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកវេជ្ជបណ្ឌិត ឈុនលី នៅក្នុងឯកសារនេះខ្ញុំ -- ដោយសារបញ្ជីនេះវែងណាស់ ខ្ញុំសូមបង្ហាញជូនឈ្មោះពីរបី ដែលជាបញ្ជីអ្នកទោសនៅស-២១ គឺលេខ១រៀងទី៨ ដែលមានឈ្មោះថា ឃឹម គឹមសាន ពាយ័ព្យ តំបន់៤ ចុះថ្ងៃទី២៧/១២/៧៧ ថ្ងៃចូល ហើយនិងថ្ងៃសម្លាប់គឺថ្ងៃ៣០/១២/៧៧។ ដូច្នេះខ្ញុំចង់សូមបញ្ជាក់តើឈ្មោះនេះជាឈ្មោះដែលបុគ្គលបានរៀបរាប់នេះឬក៏មិនមែនទេ?

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

មិនទាន់ ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេលោកវេជ្ជបណ្ឌិត។

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បាទ ឈ្មោះ១ ឃឹម គឹមសាន ឈ្មោះលេខ៨ ឃឹម គឹមសានហ្នឹង គឺពិតជាវេជ្ជបណ្ឌិតប្រធានមន្ទីរពេទ្យខេត្តបាត់ដំបង។ ហើយចំពោះលោកទី២ ម៉ែន មុនីដ៉ាម ខ្ញុំមិនស្គាល់ទេ។ សូមទោស។ ចំពោះឈ្មោះទី៣ ពឹង គឹមស៊ា គឺជាប្រធានសុខាភិបាលខេត្តមែនបាទ។ ចំពោះលោក ឃឹម គឹមសាន ខ្ញុំបានឃើញទាំងរូបថតគាត់ទៀតបាទ ប៉ុន្តែចំពោះលោក ពឹង គឹមស៊ា ខ្ញុំមិនបានឃើញរូបថតទេនៅទួលស្លែងបាទ។

[០៩:២៧:៤៩]

**ស៖** បាទ សូមអរគុណ។ ដើម្បីជាប្រតិចារឹកគឺវេជ្ជបណ្ឌិត ពឹង គឹមស៊ា គឺនៅលេខរៀងទី១០ ហើយក៏យើងមានបញ្ជីអ្នកទោសនៅក្នុងសំណុំរឿងគឺថា គាត់ស្លាប់ដោយសារតែការធ្វើទារុណកម្ម។ ឯកសារនេះគឺមានលេខ IS5.80 និងឯកសារ D82/II/32។ សូមអរគុណវេជ្ជបណ្ឌិត ដោយសារពេលវេលាខ្ញុំនៅសល់ខ្លី។ ខ្ញុំសូមសួរអំពីជោគវាសនារបស់វេជ្ជបណ្ឌិតផ្សេងទៀត ដែលធ្វើការនៅភូមិភាគពាយ័ព្យដែរនោះ។ លោកបានសរសេរនៅក្នុងសៀវភៅរបស់លោក ខ្ញុំសូមឱ្យលេខ ERN លោក

-- ទី១ លោកបញ្ជាក់ថា "ខ្ញុំជឿជាក់ថាចំណុចនេះពាក់ព័ន្ធទៅនឹងខេត្តបាត់ដំបង ខ្ញុំជឿថានៅបាត់ដំបងមានវេជ្ជបណ្ឌិតរស់រានមានជីវិត គឺមានតែពីររូបទេ។ វេជ្ជបណ្ឌិត អ៊ុន ស៊ី ដែលគាត់ធ្វើទាំងនៅមន្ទីរពេទ្យស៊ីវិលផង ទាហានផង"។ ERN ពាក់ព័ន្ធនេះគឺជាភាសាខ្មែរ 00678908, ERN ជាភាសាអង់គ្លេស 00369794 ដោយសារថាលោកធ្វើការនៅបាត់ដំបងភ្លាមៗក្រោយពេលនោះ តើនេះគឺជាអ្វីដែលលោកបានកត់សម្គាល់ថាមានវេជ្ជបណ្ឌិតតែ ពីររូបគត់ដែលនៅរស់រានមានជីវិត ឬក៏យ៉ាងណា? បាទ គឺវេជ្ជបណ្ឌិត អួន ស៊ី។

[០៩:៣០:០០]

**ធ៖** បាទ នេះជាការពិត ខ្ញុំសូមគ្រាន់តែបញ្ជាក់ថា លោក អ៊ួន ស៊ី គាត់ជាគ្រូពេទ្យស៊ីវិលទេ មិនមែនគ្រូពេទ្យទាហានទេបាទ។ ហើយសព្វថ្ងៃនេះគាត់នៅប្រទេសកាណាដា ហើយនិងនៅរស់មួយទៀត គឺរូបខ្ញុំបាទនេះឯង។

**សៈ** សូមអរគុណ។ ចំណុចចុងក្រោយមួយទៀត គឺជោគវាសនារបស់បុគ្គលិកពេទ្យមួយរូប គឺនៅត្រង់ERN ជាភាសាខ្មែរ 00678912, ហើយជាភាសាអង់គ្លេស 00369797។ នៅត្រង់នេះលោកសរសេររៀបរាប់អំពីមន្ទីរពេទ្យបាត់ដំបង ដែលលោកបានចូលធ្វើការភ្លាមៗ គឺនៅក្រោយបាត់ដំបង ខ្មែរក្រហមកាន់កាប់ គឺសមាជិក១២៥នាក់ បាទមានចំនួនតិចជាង៣០នាក់ប៉ុណ្ណោះបានរួចពីការស្លាប់ដោយខ្មែរក្រហម។ ក្នុងនោះពាក់កណ្ដាលជាបុគ្គលិកស្ត្រីមេម៉ាយ។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះថាលោកប៉ាន់ប្រមាណតួលេខនេះបានដោយរបៀបណាដែរ?

[០៩:៣១:៣០]

**ធ៖** គឺថាចំនួនតិចជាង៣០នាក់ មិនពិបាកប៉ាន់ប្រមាណទេបាទ។ ហើយភាគច្រើនអស់លោកស្រីទាំងនោះ គឺថាប្ដីត្រូវគេសម្លាប់។

**សៈ** សូមអរគុណ។ តើលោកស្គាល់អ្នកខ្លះ ឬក៏មួយចំនួន -- បុគ្គលិកមួយចំនួនដែលធ្វើការនៅមន្ទីរពេទ្យស៊ីវិលបាត់ដំបងហ្នឹងទេ? ដែលបាត់ខ្លួននោះលោកស្គាល់ខ្លះដែរទេ?

**ធ៖** ខ្ញុំធ្វើការនៅមន្ទីរពេទ្យបាត់ដំបងពីឆ្នាំ១៩៦៧ ដល់ឆ្នាំ១៩៧៣។ ដូច្នេះ ខ្ញុំស្គាល់ទាំងអស់បុគ្គលិកពេទ្យនៅមន្ទីរពេទ្យបាត់ដំបងបាទ។ ដល់៧៣ បានខ្ញុំចូលទៅពេទ្យទាហាន។

**សៈ** សូមអរគុណលោកវេជ្ជបណ្ឌិត។ ដោយពេលខ្ញុំខ្លីមែនទែន ដូច្នេះខ្ញុំជិតដល់ពេលបញ្ចប់ហើយ ខ្ញុំយល់ថា តាមសៀវភៅរបស់លោករៀបរាប់ថា លោកបាត់សមាជិកគ្រួសារច្រើនណាស់ ដែល

ខ្ញុំសូមអរគុណលោកច្រើនណាស់។ សំណួរខ្ញុំដែលសួរលោកទាំងអម្បាលម៉ានយល់ឃើញថាពិបាកណាស់ ប៉ុន្តែលោកបានឆ្លើយយ៉ាងច្រើន។

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមអរគុណច្រើនចំពោះសាក្សីរូបនេះ ហើយខ្ញុំអស់សំណួរហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

[០៩:៣៣:២៩]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល! លោកវ៉ែន ពៅ ហើយនិងលោកស្រីមេធាវីអេលីហ្សាបេត ស៊ីម៉ុនណូហ្វត នឹងលើកសំណួរចំពោះលោកសាក្សីរូបនេះ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត! សូមអញ្ជើញ!

**លោក វ៉ែន ពៅ៖**

សូមគោរពលោកប្រធាន! សូមគោរពលោក លោកស្រីចៅក្រម! សូមគោរព តំណាងសហព្រះរាជអាជ្ញា និងអង្គសវនាការទាំងមូល!

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** ជម្រាបសួរលោកវេជ្ជបណ្ឌិត ឈុនលី។ ខ្ញុំបាទឈ្មោះ វ៉ែន ពៅ ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរមួយចំនួន ដោយសារពេលវេលាខ្លី ខ្ញុំសង្ឃឹមថាលោកនឹងឆ្លើយឲ្យបានខ្លីដែរ។ ហើយសំណួររបស់ខ្ញុំភាគច្រើននៅពេលនេះគឺពាក់ព័ន្ធទៅនឹងសៀវភៅរបស់លោក ដែលសហព្រះរាជអាជ្ញាបានប្រគល់ជូនលោករួចហើយ។ សំណួរខ្ញុំដំបូង ខ្ញុំចង់សួរលោកឲ្យលោកបញ្ជាក់ឡើងវិញអំពីព្រឹត្តិការណ៍មុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ នៅទីក្រុងបាត់ដំបង។ លោកបានបញ្ជាក់ប្រាប់សហព្រះរាជអាជ្ញារួចហើយថា នៅមុនថ្ងៃ១៧ មេសា ឆ្នាំ៧៥ លោកបម្រើការជាពេទ្យ នៅក្នុងមន្ទីរ

ពេទ្យយោធា គឺមន្ទីរពេទ្យ៤០៣។ ហើយលោកក៏បានបញ្ជាក់ផងដែរថា អ្នកជំងឺនៅទីនោះភាគច្រើនសុទ្ធតែជាទាហានលន់ នល់។ ខ្ញុំសូមបញ្ជាក់ឲ្យលោកជម្រាបអង្គសវនាការថាតើទាហានទាំងនោះប្រភេទនៃជំងឺទាហាន ពួកគាត់មានជំងឺបែបណា ដោយសាររបួស ឬក៏ឈឺធម្មតាបាទ?

**ឆ៖** បាទ នៅពាក់កណ្តាលឆ្នាំ១៩៧៣ ខ្ញុំត្រូវផ្លាស់ពីមន្ទីរពេទ្យស៊ីវិល មកបម្រើការនៅមន្ទីរពេទ្យយោធា ៤០៣ ខេត្តបាត់ដំបង។ អ្នកជំងឺនៅមន្ទីរពេទ្យៗយោធានេះ គឺសុទ្ធតែជាទាហាន ហើយភាគច្រើនគឺជាអ្នករបួស។

**ស៖** តើលោកដឹងទេ អ្នករបួសជាទាហាន លន់ នល់ ទាំងនោះ តើគេយកពីកន្លែងណាមកខ្លះជុំវិញខេត្ត ឬពីកន្លែងណាបាទ? ពីសមរភូមិណាខ្លះលោកដឹងទេបាទ?

**ឆ៖** ខ្ញុំមិនអាចដឹងទាំងអស់បានទេ គ្រាន់តែដឹងថាមាននៅមន្ទីរយោធាខេត្ត មានអំប៊ុយឡង់មួយហើយទៅដឹកអ្នកជំងឺនៅកន្លែងនៅ ទៅដឹកអ្នកជំងឺពីក្រៅ យកមកចូលមន្ទីរពេទ្យខេត្តបាទ។

[០៩:៣៦:១៨]

**ស៖** តើលោកអាចប៉ាន់ប្រមានបានទេ អ្នកជំងឺជាទាហាន លន់ នល់ នៅពេលនោះមានចំនួនប្រហែលប៉ុន្មាននាក់ ច្រើនរាប់រយអ្នកឬក៏យ៉ាងណាបាទ?

**ឆ៖** បើតាមខ្ញុំដឹងគឺថា អ្នកជំងឺមានដាក់ប្រភេទអ្នកជំងឺស្រាល ប្រភេទអ្នកជំងឺធ្ងន់ និងប្រភេទអ្នកជំងឺត្រូវវះកាត់។ បាទ ទាំងអស់គឺថាមិនដល់ៗ ១០០នាក់ទេបាទ។

**ស៖** តើលោកអាចបញ្ជាក់បានទេ នៅពេលដែលលោកធ្វើការនៅពេលនោះ តើមាន -- នៅជុំវិញខេត្តបាត់ដំបងមានព្រឹត្តិការណ៍អ្វី មានឮសូរកាំភ្លើងផ្លោងដាក់ ឬក៏មានឮសំឡេងប្រយុទ្ធគ្នានៅជិតៗនោះទេ នៅមុនថ្ងៃ១៧ មេសា ៧៥?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ សាក្សី!

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បាទមាននៅសមរភូមិក្តៅជុំវិញខេត្តបាត់ដំបង ដូចជានៅម៉ោងឫស្សី បន្ទាយព្រៃស្វាយ ថាមានការវាយប្រយុទ្ធគ្នាខ្លាំង ហើយមាននៅមួយទៀតនៅតាប៉ុន ហើយនិងសមរភូមិដទៃទៀតជុំវិញខេត្តបាត់ដំបងហ្នឹងបាទ។

[០៩:៣៧:៤៦]

**ស៖** បាទ សូមអរគុណ។ សំណួរខ្ញុំបន្ទាប់ទៀតគឺឈានចូលដល់ទិដ្ឋភាពនៃថ្ងៃ១៧ មេសា ឆ្នាំ ៧៥ នៅក្នុងទីក្រុងបាត់ដំបង។

**លោក វ៉េន ពៅ៖**

លោកប្រធាន ខ្ញុំមាន -- សូមអនុញ្ញាតលោកប្រធានដើម្បីអានឯកសារនេះ គឺដែលនៅក្នុងសៀវភៅរបស់គាត់ គឺដែលមាន ERN ជាភាសាខ្មែរលេខ 00678756, ហើយ ERN ជាភាសាអង់គ្លេស 00369680។ ខ្ញុំសូមអាននៅក្នុងអត្ថបទនេះ គាត់បានលើកឡើងថា "នៅវេលាម៉ោងមួយភ្លឺ អ្នកក្រុងភ្ញាក់ផ្អើលដោយសំឡេងម៉ូតូរាប់រយគ្រឿងបើកបរនៅតាមផ្លូវក្នុងក្រុង និងសំឡេងស្រែកឡើងប៉ោកញ្ច្រៀវជាច្រើនម៉ោង"។

**សួរដោយលោក វ៉េន ពៅ៖**

**ស៖** សំណួររបស់ខ្ញុំ ចង់សួរលោកថា តើក្រៅពីឮសូរស្រែកកញ្ច្រៀវ ឬក៏សំឡេងម៉ូតូ តើមានសូរបាញ់កាំភ្លើង ឬក៏គ្រាន់ផ្ដោងអីទេបាទនៅយប់នោះ?

[០៩:៣៩:០៦]

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បាទ មុននិយាយពីយប់នោះ ខ្ញុំសូមនិយាយពីថ្ងៃសិន។ នៅថ្ងៃ១៧ មេសា នោះ ពេលព្រឹកអត់ទាន់ឃើញមានខ្មែរក្រហមចូលក្រុងបាត់ដំបងទេ អត់ទេ។ បន្ទាប់ពីការប្រកាសរបស់ឧត្តមសេនីយ៍ ម៉ីស៊ីចន និងឧត្តមសេនីយ៍ លន់ នល់ ឲ្យកងទ័ពសាធារណរដ្ឋចុះចាញ់នោះ គឺថាពុំឃើញមានទ័ពខ្មែរក្រហមចូលក្រុងបាត់ដំបងនៅឡើយទេ អត់មានទេបាទ។ រហូតដល់ម៉ោងមួយ ខ្ញុំឃើញផ្ទាល់ រថយន្តលោកចៅហ្វាយខេត្តឧត្តមសេនីយ៍ សេង សំអៀត គាត់បើកកាត់មុខផ្ទះខ្ញុំហ្នឹងតម្រង់ទៅស៊ីសុផុន ហើយតាមដំណឹងគាត់ឡើងអេឡេកូនៅចម្ការចេកប្រហែលប្រាំគីឡូម៉ែត្រពីស្ពានថ្មថ្មីពីក្រុង ហើយតម្រង់ទៅថៃបាទ។ អាហ្នឹងពេលម៉ោងមួយថ្ងៃ។ ដល់ម៉ោងបី បានមានឃើញខ្មែរក្រហមជាក្រុមតូចៗ ពីប្រាំនាក់ទៅដល់១០នាក់ មានស្រីផង ប្រុសផងឈរនៅតាមសួនច្បារនៅទីកន្លែងផ្សេងគ្នា ឈរ យាមបាទ។ អាហ្នឹងពេលៗថ្ងៃ ដល់ពេលយប់ៗ ស្រាប់តែម៉ោង១ភ្លឺ ឮសូរសំឡេងម៉ូតូ និងសំឡេងប៉ោកញ្ច្រៀវបើកពេញទីក្រុងបាទ បើកពេញទីក្រុង។ ហើយខ្ញុំមិនដឹងថា គេបានម៉ូតូពីណាមកដែរ។ ប៉ុន្តែ ខ្ញុំសួរគេគេថាយប់នោះ ពួកខ្មែរក្រហមបានទម្លាយគុក។ ទី១ បានទម្លាយគុកហើយមួយទៀតបាន បាន ដាស់

ប្រជារាស្ត្រយកម៉ូតូ ដើម្បីជិះហែរជាក្បួនៗ បញ្ចេញសំឡេងប៉ោកព្រៀវនៅពេលយប់ នៅក្រុង។ នេះជាព្រឹត្តិការណ៍មួយ ប្រហែលជាដោយឡែកចំពោះក្រុងបាត់ដំបង តាមមើល៍។

[០៩:៤១:៣៥]

**ស៖** បាទ សូមអរគុណ។ កាលពីម្សិលមិញ លោកបានឆ្លើយបញ្ជាក់រួចហើយ ទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាថា សហការីដែលជាពេទ្យយោធាធ្វើការជាមួយលោកចំនួន១៣នាក់ ត្រូវបានខ្មែរក្រហមយកទៅសម្លាប់នៅព្រឹកថ្ងៃ២១ ខែមេសា ឆ្នាំ៧៥ នៅវាលស្រែមួយនៅទល់មុខស្ថានីយ៍ៗកសិកម្មឱម៉ាល់។ ហើយនៅព្រឹកថ្ងៃបន្ទាប់ លោកបានឆៀងចូលទៅមន្ទីរពេទ្យយោធា ដែលលោកធ្វើការនោះ តាមទ្វារតូច ហើយមានទាហានម្នាក់ដែលស្គាល់លោកបានចាប់ដៃលោក ទាញលោកមិនឱ្យចូល ហើយបានប្រាប់ពីហេតុការណ៍ទាំងនេះ។ ក្រោយមកលោកបានឆៀងទៅទ្វារខាងមុខទៀត ហើយមានមនុស្សម្នាក់ទៀតបានចាប់ដៃលោក ឃាត់ទុកដូចគ្នា។ ហើយលោកក៏បានបញ្ជាក់ផងដែរថា លោកបានសង្កេតឃើញមានអ្នកជំងឺខ្លះដើរចេញពីមន្ទីរពេទ្យ ហើយមានអ្នកខ្លះទៀត ក៏មានបងប្អូនមកនាំចេញ ហើយមានអ្នកខ្លះដាក់រ៉ឺម៉ករុញចេញ គួរឱ្យរន្ធត់យ៉ាងខ្លាំង។ សំណួររបស់ខ្ញុំ ចង់សួរលោកថា តើលោកមានសង្កេតឃើញ ឬបានឮអ្នកណាប្រាប់ថា អ្នកជំងឺទាំងនោះចេញដោយសារខ្លួនឯង ឬក៏ត្រូវបានយោធាខ្មែរក្រហមបង្ខំឱ្យពួកគាត់ចេញនៅពេលនោះ?

**ឆ៖** នៅពេលដែលខ្ញុំមកមន្ទីរពេទ្យយោធា ដើម្បីចូលទៅមើលសភាពការណ៍នៅក្នុងមន្ទីរពេទ្យនោះ ខ្ញុំឃើញពីក្រៅ ឃើញអ្នកជំងឺចេញរកេតរកូត គឺថាខ្ញុំមិនដឹងថា តើខ្មែរក្រហមដេញ ឬមួយគេចេញខ្លួនគេដោយខ្លាច ពីព្រោះថាគ្រូពេទ្យអត់មាន អត់មានគ្រូពេទ្យ។ ខ្ញុំមិនដឹងថា តើគេចេញដោយខ្លួនគេ ឬមួយគេចេញដោយខ្លាចពួកខ្មែរក្រហម។ តែខ្ញុំយល់ថា គេចេញដោយខ្លាចពួកខ្មែរក្រហមជាងបាទ។

[០៩:៤៣:៥០]

**ស៖** បាទ ក្រៅពីលោកឃើញអ្នកជំងឺទាំងនោះចេញ តើលោកបានឮ ឬក៏មានឃើញ ថាមានទាហានខ្មែរក្រហមបាញ់អ្នកជំងឺឱ្យស្លាប់នៅក្នុងពេទ្យនោះទេ នៅព្រឹកនោះ ឬក៏នៅថ្ងៃនោះ?

**ឆ៖** បាទ អត់មានទេបាទ អត់មានទេ។

**ស៖** បាទ សំណួរខ្ញុំបន្តទៀតពាក់ព័ន្ធទៅនឹងថ្ងៃជម្លៀសប្រជាជនចេញពីក្រុងបាត់ដំបងនៅក្នុងសៀវភៅរបស់លោក គឺខ្ញុំសូមអាន គឺលេខ ERN លេខ 00678766 -- 69 និងERN ជាភាសាអង់គ្លេស 00369689។ ខ្ញុំសូមអាន “នៅវេលាព្រលឹមស្រាងៗថ្ងៃទី២៥ មេសា ឆ្នាំ១៩៧៥ ពួកទាហាន

ឯកសណ្ឋានខ្មៅជួតក្បាលក្រមាបាញ់កាំភ្លើងផ្ទងផាំង ព្រោងព្រាតឡើងទៅលើគ្រប់កន្លែងនៃទីក្រុង។ ចំណែកពួកវាផ្សេងទៀត ដើរទៅតាមផ្លូវមុខផ្ទះស្រែកសន្ធាប់ខ្លាំងៗ តាមប្រដាប់បំពងសំឡេងចេញពីផ្ទះៗ។ ខ្ញុំផ្អៀតចេញមកក្រៅសួរ សុម៉ាត់ត្រា ហៅ ប៉ាឡូ ជាម្ចាស់ហាងលក់សៀវភៅនៅជាប់ផ្ទះខ្ញុំ”។ សំណួរដែលខ្ញុំចង់សួរលោក ខ្ញុំសួរលោកថាតើនៅថ្ងៃជម្លៀសនោះ លោកបានដឹង ឬឮថាមានប្រជាជនធម្មតាត្រូវបានពួកខ្មែរក្រហមបង្ខំ ឬក៏បាញ់សម្លាប់ ប្រសិនបើមិនមានអ្នកណាចេញពីផ្ទះ ឬក៏អ្នករឹងទទឹងបាទ?

**ឆ៖** ខ្ញុំគ្រាន់តែដឹងថា ប្រជារាស្ត្រចេញទាំងអស់ ហើយពីព្រោះថា គេមិនអាចរឹងទទឹងជាមួយពួកខ្មែរក្រហមទេ។ បើរឹងទទឹង មុខជាគេបាញ់ចោលៗ។ ហើយខ្ញុំក៏មិនបានឃើញអ្នកណាមួយដែលខ្មែរក្រហមបាញ់សម្លាប់នៅផ្ទះ ដោយមិនព្រមចេញដែរបាទ។

[០៩:៤៦:២១]

**ស៖** បាទ សូមអរគុណ។ ពាក់ព័ន្ធទៅនឹងការជម្លៀសរបស់លោកផងដែរ ទៅដល់កន្លែងរស់នៅថ្មី គឺភូមិដំរីស្លាប់ ឃុំព្រែកនរិន្ទ ស្រុកដូនទាវ ខេត្តបាត់ដំបង ដែរ។ ខ្ញុំចង់សួរថា ដំបូងនៅពេលដែលគេជម្លៀសលោកទៅដល់ទីនោះ តើលោកមានសង្កេតឃើញមានប្រជាជន១៧មេសា ផ្សេងទៀតដែលត្រូវបានគេជម្លៀសចេញពីភ្នំពេញ ឬក៏ពីទីផ្សេងៗ ខេត្តផ្សេងៗ ក្រៅពីលោកដែលទៅពីបាត់ដំបងទេបាទ?

**ឆ៖** នៅថ្ងៃ១៧ មេសា ៧៥ នេះ អ្នកជម្លៀសចេញ អ្នកជម្លៀសចេញទៅនៅតាមភូមិ គឺសុទ្ធតែជាអ្នកបាត់ដំបងបាទ។ អ្នកភ្នំពេញក្រោយមកទេបានៗគេជម្លៀសពីតាមរទេះភ្លើងមក ហើយបែងចែកទៅតាមភូមិនានា នេះគឺក្រោយមកទៀតបាទ។

**លោក វ៉ែន ពៅ៖**

លោកប្រធាន ខ្ញុំសូមអាននៅក្នុងសៀវភៅគាត់ដដែល គឺERN ជាភាសាខ្មែរ 00678775, និង ERN ជាភាសាអង់គ្លេស 00369693។

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** ខ្ញុំសូមអាន ក្នុងនោះគាត់បានសរសេរថា “ក្រៅពីឈ្លប ពួកខ្មែរក្រហមបានបង្កើតកងឈ្លបបង្កប់ដើម្បីយកការណ៍ពីប្រជារាស្ត្រ ហើយឈ្លបបង្កប់សុទ្ធតែយុវជនទាំងពីរភេទ ដែលបានជ្រើសរើសក្នុងភូមិ។ ពួកនេះ អាចលួចៗ ចូលក្រោមគ្រែយើងនៅពេលយប់ ដើម្បីលួចស្តាប់យើងនិយាយ រួចរាយ-

ការណ៍ទៅថ្នាក់លើ"។ សំណួរដែលខ្ញុំចង់សួរលោក ខ្ញុំសួរលោកថា តើការដែលឈ្លបលួចស្តាប់និយាយគ្នានេះ តើគេលួចស្តាប់តែពួកប្រជាជនថ្មី ឬក៏គេលួចស្តាប់ទាំងពួកមូលដ្ឋានចាស់ដែរ?

**ឆ៖** ខ្ញុំមិនដឹងថា គេលួចស្តាប់អ្នកណាខ្លះទេ ប៉ុន្តែជាឈ្លបបង្កប់។ ខ្ញុំយល់ថា គេអាចស្តាប់ -- លួចស្តាប់នរណាដែលគេសង្ស័យ។ ជាពិសេស ប្រជាជនថ្មី។

[០៩:៤៩:០៤]

**សៈ** តើលោកបានដឹង ឬក៏សង្កេតឃើញថា ប្រសិនបើឃើញអ្នកដែលត្រូវបានគេរាយការណ៍ទៅថ្នាក់លើ តើត្រូវមានទោសយ៉ាងម៉េច? លោកមានដឹងទេបាទ?

**លោក វ៉ែន ពៅ៖**

លោកប្រធាន ខ្ញុំសូមអានដដែល -- ពាក់ព័ន្ធនឹងចម្លើយរបស់គាត់ នៅក្នុងសៀវភៅដដែល គឺ ERN លេខ 0060 --

**ប្រធានអង្គជំនុំ៖**

សំណួរអំមិញ សាក្សីអត់ទាន់បានឆ្លើយទេ ដោយសារក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ។ សាក្សីឆ្លើយសំណួរចុងក្រោយអម្បាញ់មិញ នៅពេលណាដែលក្បាលមីក្រូហ្វូនប្រតិបត្តិការ។

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ខ្ញុំមិនបានដឹងថា តើពួកឈ្លបបង្កប់នោះ គេស្តាប់នៅកន្លែងណា ស្តាប់អ្នកណានោះទេ។ ពីព្រោះគេជាអ្នកបង្កប់។

[០៩:៥០:០០]

**សួរដោយលោក វ៉ែន ពៅ៖**

**សៈ** បាទ សូមៗអរគុណ។ ខ្ញុំសូមអានទៀតគឺលេខ ERN ជាភាសាខ្មែរ 00678777, ERN ជាភាសាអង់គ្លេស 00369695។ នៅក្នុងនេះលោកបានសរសេរថា "ប្រជារាស្ត្រទូទៅមានការប្រុងប្រយ័ត្នក្នុងការនិយាយស្តី គេប្រើពាក្យ "ហូប" ជំនួសពាក្យ "ញុំា" ពាក្យ "គ្រួសារ" ជំនួសពាក្យ "ប្តីឬប្រពន្ធ""។ សំណួរដែលខ្ញុំសួរលោកថាតើលោកដឹងថាគេប្រើពាក្យនេះដោយរបៀបណា? គេណែនាំប្រាប់លោក ឬក៏លោកចេះតែប្រើតៗគ្នាបាទ?

**ឆ៖** ដូចខ្ញុំបានជម្រាបពីម្សិលមិញ គឺអឺចឹងថា "ខ្មែរក្រហមមិនដែលធ្វើការផ្សព្វផ្សាយតាមក្រដាសស្នាម ឬតាមបច្ចេកទេសអីជាផ្លូវការទេ គឺអ្វីៗគឺថាតាមពីមាត់មួយទៅមាត់មួយ ឮតៗគ្នាអឺចឹងបាទ"។

**សៈ** ខ្ញុំចង់ឲ្យលោកបញ្ជាក់ថានៅពេលដែលគេជម្លៀសលោកទៅដំបូងនោះ ថាតើលោកដឹងថាតើសហករណ៍ហូបរួមហ្នឹងចាប់ផ្ដើមមានពីពេលណាមក ឬក៏គេមានស្រាប់ហើយបាទ?

[០៩:៥១:៤១]

**ឆះ** ពេលជម្លៀសមុនដំបូងមិនទាន់បង្កើតសហករណ៍ទេ គឺថាប្រជារាស្ត្រ ដែលថាជម្លៀសទៅហ្នឹងគឺថាមានយកម្ហូប យកអីទៅជាមួយខ្លួន ដូច្នេះមិនទាន់មានការខ្វះខាតប៉ុន្មានទេ។ ហើយសហករណ៍នោះគឺចាប់បង្កើតនៅឆ្នាំ១៩៧៦ គឺបន្ទាប់ពីចូលឆ្នាំ។ បាទ ចូលឆ្នាំខ្មែរ ហ្នឹងគឺហូបរួមអីរួមទាំងអស់។

**សៈ** ដល់ពាក់ -- ខ្ញុំសួរបន្តពាក់ៗព័ន្ធនឹងលោកត្រូវបានទៅធ្វើការនៅមន្ទីរពេទ្យព្រែកហ្លួងវិញម្តង។ ខ្ញុំសូមអានឯកសាររបស់លោកដែរ ERN ជាភាសាខ្មែរគឺ 00678785, ហើយ ERN ជាភាសាអង់គ្លេស 00369702។ នៅក្នុងនោះលោកបានសរសេរថា “អ្នកមកពិនិត្យពិគ្រោះជំងឺភាគច្រើនជាអ្នកមូលដ្ឋានចូលមកទាំងអស់ពេញៗបន្ទប់ ហើយប្រជែងគ្នាសុំឱសថជាជាងប្រជែងគ្នាសុំពិនិត្យជំងឺ”។ សំណួររបស់ខ្ញុំចង់សួរថា លោកមានសង្កេតឃើញទេ តើហេតុអ្វីបាននៅទីនោះភាគច្រើនមានតែអ្នកមូលដ្ឋានមកសុំថ្នាំ ឬក៏ពិនិត្យជំងឺ តើមានពួកប្រជាជនថ្មីមកដែរទេបាទ? មូលហេតុអីបាទ?

[០៩:៥៣:១៩]

**ឆះ** ខ្ញុំអាចនិយាយបានថា នៅពេលនោះគឺ ១ខែបន្ទាប់ពីការជម្លៀសបាទ ដូច្នេះប្រជាជនដែលជម្លៀសមកពីក្រុងហ្នឹងគឺថាមិនទាន់មានការឈឺថ្កាត់អ្វីទេបាទ។ ហើយអ្នកដែលសុំថ្នាំនេះ គឺច្រើនតែអ្នកនៅមូលដ្ឋានដែលគ្នាមិនបាន ស្ទូវបានស្គាល់ៗពេទ្យ។ បាទ ដែលនៅឆ្ងាយគ្នាមកសុំថ្នាំបាទ។

**សៈ** សូមអរគុណ។ ខ្ញុំសូមបញ្ជាក់ផងដែរថា កាលពីម្សិលមិញលោកបានបញ្ជាក់រួចហើយថា “នៅក្នុងសម័យនោះគឺសម័យខ្មែរក្រហមនោះពេទ្យពួកខ្មែរក្រហម គឺថាគេឲ្យរៀនតែរយៈពេល១សប្តាហ៍ទេ រីឯគ្រូពេទ្យដែលមានជំនាញវិជ្ជាជីវៈត្រឹមត្រូវជំនាន់មុន ត្រូវពួកខ្មែរក្រហមយកទៅសម្លាប់ចោល”។ សំណួរខ្ញុំសួរថា តើលោកអាចដឹង ឬមានអ្នកណាប្រាប់លោកទេថា ក្នុងរយៈពេលខ្លី ១សប្តាហ៍បង្រៀនដល់គ្រូពេទ្យខ្មែរក្រហមទាំងនោះ តើគេមានបង្រៀនពីក្រមសីលធម៌វិជ្ជាជីវៈពេទ្យដែរទេបាទ?

**ឆះ** អ្វីដែលខ្ញុំបាននិយាយម្សិលមិញនេះគឺជាពាក្យរបស់ប្រធានតំបន់៤ ឈ្មោះ ខែក ប៉ែន ហៅមិត្តស៊ូ។ គាត់នៅក្នុងសុន្ទរកថាគាត់ដ៏វែងគាត់បាននិយាយថា “អង្គការ –ខ្ញុំសូមរំឭកឡើងវិញចុះ– អង្គការមិនចំណាយពេលឥតប្រយោជន៍៧ឆ្នាំ ដើម្បីបណ្តុះបណ្តាលពេទ្យទេ។ អង្គការបណ្តុះបណ្តាលពេទ្យតែ៧ថ្ងៃ គឺគ្រប់គ្រាន់។ ទី១។ ទី២ ម្សិលមិញខ្ញុំភ្លេចនិយាយៗ ម្សិលមិញ។ ទី២ គឺពលកម្ម នឹងធ្វើ

ឲ្យប្រជារាស្ត្រមានសុខភាពមាំមួន មិនឈឺថ្កាត់ច្រើនទេ។ ហើយចំពោះការបណ្តុះ -- ការអនុវត្តផែនការបណ្តុះបណ្តាលបុគ្គលិកពេទ្យយ៉ាងណានោះខ្ញុំមិនដឹងទេបាទ។ ហើយគេក៏មិនឲ្យ -- គេមិនឲ្យយើងដឹងដែរ។

**ស៖** បាទ សូមអរគុណ។ ហើយកាលពីម្សិលមិញផងដែរ លោកបានបញ្ជាក់ផងដែរថា ពេលដែលលោកធ្វើការនៅមន្ទីរពេទ្យយោធា គឺមន្ទីរពេទ្យ ព-២។ លោកបានបញ្ជាក់ថា នៅពេលដែលមានទាហានខ្មែរក្រហមឈឺធ្ងន់ គេត្រូវការឲ្យលោកទៅជួយពិនិត្យព្យាបាល។ តែនៅពេលដែលលោកទៅធ្វើការនៅមន្ទីរពេទ្យស៊ីវិល គឺមន្ទីរពេទ្យ ព-១ បើទោះបីជាមានប្រជាជនឈឺយ៉ាងណា ក៏គេមិនឲ្យលោករវល់ដែរ។ តើលោកអាចបញ្ជាក់បានទេ តើមូលហេតុអ្វីបានមានលក្ខណៈខុសគ្នាបែបនេះ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

[០៩:៥៦:៣២]

**ប្រធានអង្គជំនុំ៖**

បាទ ក្បាលមីក្រូមិនទាន់ប្រតិបត្តិការទេ។

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បាទ លក្ខណៈខុសគ្នា ខ្ញុំបានជម្រាបយ៉ាងវែងពីម្សិលមិញហើយ រវាងមន្ទីរពេទ្យយោធា និងមន្ទីរពេទ្យស៊ីវិលបាទ។ នៅមន្ទីរពេទ្យយោធា ជាកន្លែងដែលគេបំប៉នយោធារបស់អង្គការ បំប៉នសុខភាពយោធារបស់អង្គការបាទ។ ចំពោះមន្ទីរពេទ្យស៊ីវិលវិញ គឺថា គេមិនរវីរវល់ -- ខ្ញុំធ្វើការបាន២ខែទេបាទ នៅមន្ទីរពេទ្យស៊ីវិល បាទ រួចទៅ ទៅសហករណ៍។ មន្ទីរពេទ្យស៊ីវិលវិញ គឺថាតាំងពីម្ហូប តាំងពីការអង្គុយហូប គឺអង្គុយនៅតាមផ្លូវជាជួរដូចសត្វធាតុអីចឹងបាទ អង្គុយតាមផ្លូវជាជួរ ហើយដាក់ម្ហូបទឹកប្រហុក បន្លែបន្តិចបន្តួចទៅបាទ។ ហើយគេមិនអនុញ្ញាត គេមិន ចំពោះ -- គេមិនរវីរវល់ ចំពោះជំងឺធ្ងន់ ហើយគេមិនអនុញ្ញាតឲ្យខ្ញុំព្យាបាលទេ។ សូម្បីតែខ្ញុំ ខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានប្អូនជីដូនមួយពីរ ពីរនាក់ដេកពេទ្យនៅពេទ្យស៊ីវិល។ គេថា គេមិនឲ្យខ្ញុំចូលមើលប្អូនជីដូនមួយខ្ញុំផង។ ហើយក្រោយមកប្អូនជីដូនមួយខ្ញុំពីរនាក់នោះក៏ស្លាប់ទៅ។ នេះមិន -- អានេះមិនមែនជាចំពោះខ្ញុំ គឺទូទៅអីចឹងបាទ។

[០៩:៥៨:២១]

**ស៖** ពាក់ព័ន្ធនឹងអ្វីដែលលោកបានលើកឡើងហើយថា លោកធ្វើការនៅមន្ទីរពេទ្យស៊ីវិលនោះបានជាង២ខែ។ ខ្ញុំចង់សួរ តើលោកមានសង្កេតឃើញអ្នកជំងឺ ប្រជាជនភាគច្រើនឈឺៗជំងឺប្រភេទ

ណាខ្លះទៅបាទ?

**ឆ៖** បាទនៅមន្ទីរពេទ្យស៊ីវិល ជំងឺភាគច្រើនទាក់ទងនឹងបញ្ហាអនាម័យ គឺរាកមួល ហើយមួយទៀត ជាជំងឺដែលទាក់ទងនឹងកង្វះអាហារូបត្ថម្ភ មានស្គម មានហើម មានស្លេកស្លាំង។

**ស៖** តើក្នុងមន្ទីរពេទ្យ ដែលរយៈពេល២ខែលោកធ្វើនោះ តើលោកសង្កេតឃើញមានអ្នកជំងឺប្រជាជនហ្នឹងប្រហែលជាប៉ុន្មាននាក់ លោកអាចបញ្ជាក់បានទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់!

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ខ្ញុំមិនអាចប៉ាន់ប្រមាណចំនួនអ្នកជំងឺនៅមន្ទីរពេទ្យស៊ីវិលទេ។ ប៉ុន្តែខ្ញុំឃើញថា អគារមួយចំនួនត្រូវបិទ។ ទី១ អគាររដ្ឋបាល អគារកុមារ និងអគារសម្ភព គឺបិទចោលតែម្តង ពីព្រោះគ្មានអ្នកណាមកសម្រាលកូននៅមន្ទីរពេទ្យសម្ភពទេ។ ទី១។ ទី២ នៅតាមភូមិក៏គ្មាននារីមានផ្ទៃពោះ -- តិចតួចណាស់ស្រីដែលមានផ្ទៃពោះបាទ។ ហើយអ្នកជំងឺនោះ គេដាក់លាយឡំគ្នា ជួនកាលគ្រែមួយដាក់អ្នកជំងឺពីរអ៊ីចឹងទៅ។ អ្នកជំងឺខ្លះដេកនៅតាមឥដ្ឋអ៊ីចឹងទៅបាទ ស្រីលាយប្រុស ប្រុសលាយស្រី គ្មានសណ្តាប់ធ្នាប់ទេបាទ។ គេរៀបចំដូចជា។មិនមែនជាមនុស្ស ជាសត្វធាតុបាទ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមងាកមកសួរលោកពាក់ព័ន្ធនឹងការដែលលោកបានដឹងឮនៃការជម្លៀសប្រជាជនមកពីទីក្រុងភ្នំពេញ។

[១០:០០:៤៦]

**លោក វ៉ែន ពៅ៖**

លោកប្រធាន ខ្ញុំសូមអានឯកសារដែលគាត់បានសរសេរដែរគឺ ERN ជាភាសាខ្មែរ 00678805, និង ERN ជាភាសាអង់គ្លេស 00369716។ “ខ្ញុំបានជួបមិត្តម្នាក់ជាវេជ្ជបណ្ឌិតមានឈ្មោះប្រហែលខ្ញុំដែរ ឈិនលី និងវេជ្ជបណ្ឌិតម្នាក់ទៀត ធ្លាប់ធ្វើការនៅភ្នំ -- នៅកំពង់ចាមឈ្មោះ ឡុង ណារ៉េត និងប្រពន្ធគាត់។ គាត់និយាយថាពួកខ្មែរក្រហមដឹកប្រជារាស្ត្រតាមរថភ្លើងពីភ្នំពេញ ហើយទម្លាក់ប្រជារាស្ត្រហូរហែតាមស្ថានីយដូចជានៅស្វាយដូនកែវ ពោធិ៍សាត់ នៅម៉ោងឬស្សី និងនៅភ្នំធិបដេ។ នៅស្ថានីយរថភ្លើងបាត់ដំបង និងស្ថានីយផ្សេងៗទៀតតាមផ្លូវទៅស៊ីសុផុន”។

[១០:០១:៤២]

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** សំណួររបស់ខ្ញុំចង់សួរថាតើក្រៅពីគាត់ប្រាប់ពាក្យទាំងនេះ តើលោកបានឮថានៅតាមស្ថានីយរថភ្លើងមួយៗមានអ្នក ឬក៏កម្មាភិបាលខ្មែរក្រហមទៅចាំទទួលប្រជាជនទាំងនោះទេ នៅពេលដល់ស្ថានីយនីមួយៗបាទ?

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បាទ ខ្ញុំចំពោះរឿងនេះ ខ្ញុំមិនដឹងទេ ខ្ញុំដឹងតែថាអ្នកជំងឺគេយកមកទម្លាក់តាមៗៗដូចជានៅតាមៗស្ថានីយនេះ -- ស្ថានីយរថភ្លើងនីមួយៗ ដូចជានៅភ្នំធិបតី អ្នកដែលនៅភ្នំធិបតី គឺថាកន្លែងនេះជាកន្លែងខ្វះទឹក ហើយកន្លែងក្របំផុតកន្លែងហ្នឹង។ អ្នកខ្លះទៀតបានមករហូតមកដល់បាត់ដំបង រួចទៅបានធ្វើដំណើរខ្លួនឯង គេនាំ -- ខ្ញុំមិនដឹងថាគេនាំ រួចហើយបានឃើញមកដល់ភូមិខ្ញុំបាទ។ ហើយខ្លះទៀតក៏បន្តទៅៗតាមផ្លូវទៅស៊ីសុផុនទៅទៀត។ មានរហូតទៅដល់ស្រុកផ្សេងៗបាទ។ ចំពោះថាខ្មែរក្រហមនៅចាំនៅតាមស្ថានីយ នៅតាមណានោះ ខ្ញុំមិនដឹងទេបាទ។

[១០:០៣:១៧]

**ស៖** ចុះលោកមានបានទទួលព័ត៌មាន ឬក៏ត្រូវបានគាត់ប្រាប់លោកថា តើនៅការធ្វើដំណើររបស់ប្រជាជនតាមរថភ្លើងនោះ តើគេផ្តល់ម្ហូបអាហារ ឬផ្គត់ផ្គង់យ៉ាងណាដែរបាទ?

**ឆ៖** ខ្ញុំមិនបានសួរគេអំពីបញ្ហានេះទេ ហើយគេក៏មិនបានជម្រាបខ្ញុំអំពីបញ្ហានេះដែរ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមងាកមកសំណួរមួយផ្សេងទៀត ពាក់ព័ន្ធនឹងការដែលលោកដឹងឮអំពីថ្នាក់ដឹកនាំនៃកម្ពុជាប្រជាធិបតេយ្យនៅក្នុងរបបខ្មែរក្រហម។

**លោក វ៉ែន ពៅ៖**

លោកប្រធាន ខ្ញុំសូមអានឯកសារនេះ ដែលគាត់បានសរសេរនៅក្នុងសៀវភៅរបស់គាត់ដែរ គឺ ERN ជាភាសាខ្មែរ 00678826, និង ERN ជាភាសាអង់គ្លេស 00369730។ ហើយក្នុងនោះលោកបានសរសេរថា “៣ថ្ងៃក្រោយមក ណាន ជាសមាជិកផ្គត់ផ្គង់បានប្រាប់ខ្ញុំថា អៀង សារី បានធ្វើដំណើរទៅមើលការបង្កបង្កើនផលនៅភ្នំសំពៅ។ ណាន ថា អៀង សារី គ្រាន់តែចុះពីរថយន្តខ្មៅ រួចពិនិត្យមើលការធ្វើការស្រែដោយប្រើកែរឃើត។

[១០:០៤:៤១]

**សួរដោយលោក វ៉េន ពៅ៖**

**ស៖** សំណួររបស់ខ្ញុំសួរថាតើលោកបានដឹង ឬមានគេប្រាប់លោកទេ ថានៅ នៅពេលនោះ លោក អៀង សារី មានតួទីជាអ្វីដែរបាទ?

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ពេលនោះឯងខ្ញុំធ្វើការនៅមន្ទីរពេទ្យយោធា ព-២ បាទ។ ហើយនៅថ្ងៃនោះ គឺគេប្រកាស ប្រធានមន្ទីរពេទ្យប្រកាសថា "ក្រុងគេបិទមួយថ្ងៃ អត់ឲ្យអ្នកណាចេញចូលទេ អត់ឲ្យធ្វើចរាចរទេ ក្រុង"។ ក្រុងខ្មោចហ្នឹង គេបិទមួយថ្ងៃ អត់ឲ្យមានចរាចរទេបាទ។ ហើយដល់ពេលថ្ងៃបន្តិច ខ្ញុំឃើញៗ រថយន្តម៉ាកសីដេសមួយ ម៉ាកសីដេសអមដោយរថយន្តរួមដំណើរ ហើយខ្ញុំមើលមិនច្បាស់ ថាអ្នកណា នៅហ្នឹងរថយន្តហ្នឹងទេ។ គ្រាន់តែដឹងថា ឡានហ្នឹងទៅតាមផ្លូវទៅភ្នំសំពៅ។ ហើយក្រោយមកទៀត បីថ្ងៃបានម្នាក់នេះឈ្មោះ ណន ដែលគាត់ជាអតីតសង្ឃហើយគាត់សឹក ហើយគាត់មកធ្វើការនៅមន្ទីរ ពេទ្យយោធានេះក្នុងឋានៈជាអ្នកផ្គត់ផ្គង់ ជាអ្នកដឹកម្ហូបអាហារបន្លែត្រីសាច់មកមន្ទីរពេទ្យយោធា គ្រាន់ ប្រាប់ខ្ញុំថា អ្នកដែលជិះឡានម្សិលមិញនេះ គឺ អៀង សារី គាត់ទៅមើលគេធ្វើស្រែនៅភ្នំសំពៅ។ គាត់មិន បានដើរទៅណាឆ្ងាយទេ គាត់គ្រាន់តែចេញពីឡានហើយមើលអ្នកធ្វើការតាមកែវយឹត នេះគឺតាមការ ៗ និទានរបស់គាត់បាទ។ តាមការប្រាប់របស់គាត់ចំពោះខ្ញុំ។

**ស៖** បាទ ខ្ញុំចង់បញ្ជាក់បន្ថែមថា តើលោកបានដឹងលើរបៀបប្រាប់ -- គេប្រាប់លោកថានៅ ពេលនោះលោក អៀង សារី មានតួនាទីជាអ្វីទេបាទ?

**ឆ៖** ពេលនោះ ខ្ញុំដឹងថា លោក អៀង សារី ជារដ្ឋមន្ត្រីក្រសួងការបរទេសនៃកម្ពុជាប្រជាធិប-តេយ្យ។

**ស៖** បាទ សូមអរគុណ។ សំណួររបស់ខ្ញុំមួយទៀត ពាក់ព័ន្ធនឹងមេដឹកនាំមួយរូបទៀតដែរ គឺ ខ្ញុំសូមអានលោកប្រធាន គឺERN ជាភាសាខ្មែរ 00678828, ERN ជាភាសាអង់គ្លេស 00369731 ដល់32។ លោកបានសរសេរក្នុងសៀវភៅរបស់លោកថា "នួន ជា ជាប្រធានសភាក្នុងរបបខ្មែរក្រហម ឬកម្ពុជាប្រជាធិបតេយ្យ"។ សំណួររបស់ខ្ញុំចង់ដឹងថា តើលោកដឹងតួនាទីគាត់ជាប្រធានសភាក្នុងរបប កម្ពុជាប្រជាធិបតេយ្យហ្នឹងដោយរបៀបណា អ្នកណាអ្នកប្រាប់លោក?

**ឆ៖** ខ្ញុំសូមជម្រាបដោយត្រង់ គឺថាខ្ញុំបានដឹង ប៉ុន្តែខ្ញុំមិនចាំថា ហេតុអ្វីបានខ្ញុំបានដឹង ខ្ញុំមិនចាំ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមអានលេខឯកសារនៅទំព័រផ្សេងទៀត គឺក្នុងនោះ គឺERN ជាភាសាខ្មែរ 00678830, ERN ជាភាសាអង់គ្លេស 00369732 ដល់33។ នៅក្នុងនេះខ្ញុំសូមអានលោកបានសរសេរថា "ថ្ងៃមួយ ម្តាយ សួន កាសេត និយាយប្រាប់ខ្ញុំថា ម្សិលមិញនេះ នួន ជា មកសួរសុខទុក្ខម្តាយគេ។ បងស្រីខ្ញុំសួរ នួន ជា ថា អានី និងប្តីវានៅឯណា? អានី ជាប្អូនស្រីរបស់ នួន ជា។ ប្តីវាជាមន្ត្រីធ្វើការធ្វើការនៅធនាគារជាតិកម្ពុជា។ កាលពីនៅភ្នំពេញ នួន ជា ទៅដេក និងហូបបាយនៅផ្ទះអានី ជាញឹកញាប់។ នួន ជា បានឆ្លើយនៅចំពោះមុខបងប្អូនថា ម៉ែកុំបារម្ភនៅកន្លែងណាក៏មានបាយហូបដែរ"។ សំណួររបស់ខ្ញុំដែលនឹងសួរលោក តើលោកដឹងថា លោក នួន ជា គាត់ទៅលេងក្រុមគ្រួសារគាត់ញឹកញាប់ទេនៅក្នុងរបបខ្មែរក្រហម មានដែលអ្នកគេប្រាប់ ឬក៏លោកដឹងទេ?

[១០:០៩:៤១]

**ធ៖** ចំពោះផ្នែកៗ ដែលខ្ញុំសរសេរក្នុងសៀវភៅនេះ គឺថាមុននឹងសរសេរ ខ្ញុំបានសួរបញ្ជាក់បងប្អូន នួន ជា ពីរដង។ គឺគាត់និយាយថាអ៊ីចឹងហើយ។ គឺថាខ្ញុំនៅមន្ទីរពេទ្យឃោធាខេត្តហ្នឹងមិនឆ្ងាយពីផ្ទះលោក នួន ជា ប៉ុន្មានទេបាទ។ ហើយខ្ញុំពេលថ្ងៃៗ ប្រហែលម៉ោងមួយ ខ្ញុំ ម៉ោងដប់ពីរកន្លះ ឬម៉ោងមួយ ខ្ញុំឆ្លៀត និយាយថាលួចពេលៗ ជិះកង់ទៅផ្ទះប្អូនលោកយាយជាម្តាយលោក នួន ជា។ ហើយខ្ញុំឧស្សាហ៍ទៅលេងណាស់ ហើយពេលមួយនោះ ម្តាយនួន ជា និយាយប្រាប់ខ្ញុំអ៊ីចឹងបាទ គាត់និយាយប្រាប់ខ្ញុំ គាត់ថា "ម្សិលមិញនោះ នួន ជា មកលេងៗម្តាយគេ ដែលជាបងស្រីគាត់ ហើយបងស្រីគាត់សួរ នួន ជា ថា អានី នៅឯណា?" អានី គឺជាប្អូនស្រីរបស់ នួន ជា ប្តីធ្វើការនៅធនាគារ ប៉ុន្តែត្រូវគេសម្លាប់ ហើយជម្លៀស ក៏មិនដឹងជម្លៀសទៅឯណាដែរ។ ហើយម្តាយ នួន ជា ប្រាប់ខ្ញុំថា "ក្មួយដឹងទេគេឆ្លើយយ៉ាងម៉េច។ គេឆ្លើយថា ម៉ែកុំភ័យ នៅកន្លែងណាក៏មានបាយហូបដែរ។ ម៉ែកុំភ័យ!" ហើយមុនសរសេរខ្ញុំសួរបញ្ជាក់ជីដូនមួយ នួន ជា អំពីពាក្យហ្នឹង។ គាត់ថានិយាយអ៊ីចឹងមែន បាទ។

[១០:១១:២៣]

ហើយអានី នេះ គឺជានៅពេលដែល នួន ជា -- ក្នុងឆ្នាំហុកសិបជាង នៅពេលដែល នួន ជា ធ្វើការនយោបាយសម្ងាត់ នួន ជា តែងតែទៅដេក ទៅស៊ី នៅផ្ទះប្អូនស្រីនោះឯង។ ហើយ អានី នេះ គឺដែលប្អូន នួន ជា ប្រពន្ធខ្ញុំស្គាល់ច្បាស់ បាទប្រពន្ធខ្ញុំស្គាល់ច្បាស់។ ហើយសព្វថ្ងៃនេះ អានី នៅអាមេរិក។

**ស៖** បាទសូមអរគុណ។ ពាក់ព័ន្ធនឹងសំណួរនេះ ខ្ញុំសូមបន្តទៀតថា តើលោកដែលឮគេប្រាប់ ឬក៏លោកដឹងទេ ថាក្រៅពីលោក នួន ជា មកលេងក្រុមគ្រួសារគាត់ ថាតើគាត់មានដែលចុះទៅពិនិត្យការដ្ឋានការងារផ្សេងៗនៅក្នុងខេត្តបាត់ដំបងទេបាទ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ បាទ។

**ស៖** បាទ សូមអរគុណ។ នេះជាសំណួរចុងក្រោយរបស់ខ្ញុំ ខ្ញុំចង់សួរលោកថា លោកបានបញ្ជាក់ក្នុងសៀវភៅរបស់លោកជាច្រើនដងហើយថា នៅជំនាន់ខ្មែរក្រហម លោកមានវិទ្យុដែលលោកលួចស្តាប់ពិសេស គឺលោកលួចស្តាប់វិទ្យុសហរដ្ឋអាមេរិក វី.អូ.អេ។ សំណួរខ្ញុំចង់សួរថា ក្រៅពីលោកស្តាប់ -- លួចស្តាប់វិទ្យុ វី.អូ.អេ តើលោកដែលមានបើក ឬក៏លួចស្តាប់ឮវិទ្យុផ្សាយសំឡេងរបស់កម្ពុជាប្រជាធិបតេយ្យទេ នៅក្នុងជំនាន់នោះ បាទ?

**ឆ៖** នៅជំនាន់ខ្មែរក្រហម ចំពោះខ្ញុំ មិនមែនតែម្ហូបអាហារទេ ដែលខ្ញុំត្រូវការ ដែលខ្ញុំអត់ត្រូវការ ដែលខ្ញុំស្រេកឃ្លាន គឺខ្ញុំស្រេកឃ្លាននូវព័ត៍មានដែរ ហេតុដូច្នេះ បានជាខ្ញុំប្រថុយលួចស្តាប់វិទ្យុអាមេរិកាំង។ ខ្ញុំមាន អេកូតទ័រ -- អាស្តាប់ត្រចៀក ខ្ញុំលួចដាក់ហោប៉ៅ ហើយខ្ញុំពេលយប់ ខ្ញុំលួចស្តាប់។ ខ្ញុំមិនដែលស្តាប់វិទ្យុកម្ពុជាប្រជាធិបតេយ្យទេ ខ្ញុំស្តាប់តែវិទ្យុអាមេរិក វី.អូ.អេ បាទ ហើយពេលស្តាប់ វី.អូ.អេ រួច ខ្ញុំក៏ឆ្លៀតរៀនភាសាអង់គ្លេស ពីព្រោះថាបន្ទាប់ពីនិយាយភាសាខ្មែររួច វិទ្យុ វី.អូ.អេ និយាយជាភាសាអង់គ្លេស ដែលខ្លឹមសារដូចភាសាខ្មែរដែរ។ នេះក៏ជាការចំណេញមួយដល់ខ្ញុំដែរ បាទ។ ចំណេញដោយគ្រោះថ្នាក់ បាទ។

[១០:១៤:១០]

**លោក វ៉ែន ពៅ៖**

សូមអរគុណលោកវេជ្ជបណ្ឌិត ឈុនលី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ ខ្ញុំសូមឱ្យសហភាតាខ្ញុំសួរបន្ត។ សូមអរគុណ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព!

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** បាទ ជម្រាបសួរលោកសាក្សី។ ខ្ញុំជាសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយខ្ញុំមានសំណួរមួយចំនួនដើម្បីចោទសួរទៅលោក។ ខ្ញុំសូមដោះស្រាយបញ្ហាមួយ ព្រោះថាខ្ញុំស្តាប់ឮ

ការបកប្រែជាភាសាអង់គ្លេស ហើយ--

[១០:១៥:០១]

*(មានបញ្ហាបច្ចេកទេស)*

[១០:១៥:១២]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងផ្នែកបកប្រែភាសា។

[១០:១៥:៣០]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំគិតថាបញ្ហានេះដោះស្រាយរួចហើយ ព្រោះឥឡូវខ្ញុំស្ដាប់ឮការបកប្រែវិញហើយ។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** លោកសាក្សី ខ្ញុំសូមចោទសំណួរមួយចំនួនដែលខុសពីសំណួរមុនៗ អម្បាញ់មិញនេះ។ ខ្ញុំសូមអរគុណលោកជាមុនដែលថា អត់ធ្មត់ឆ្លើយនឹងសំណួរបន្ថែមទៀតនេះ។ សំណួរទី១ របស់ខ្ញុំនេះ ទាក់ទងនឹងអ្វីដែលលោកបាននិយាយលើវៀតណាម ដែលលោកបានឆ្លើយទៅខាងសហព្រះរាជអាជ្ញាថា "ចាប់ថ្ងៃទី១៩ មេសា ថាខ្មែរក្រហមបាននិយាយថា វៀតណាមត្រូវតែត្រឡប់ទៅប្រទេសខ្លួនវិញ"។ តើលោកមានដឹងទេ អំពីជោគវាសនារបស់វៀតណាម ដែលស្ថិតនៅប្រទេសកម្ពុជានេះ ក្រោយពីថ្ងៃ១៩ មេសា ហើយហ្នឹងនៅតែបន្តនៅប្រទេសកម្ពុជាទៀត? តើមានរឿងអ្វីកើតឡើងដែរចំពោះវៀតណាម ដែលនៅបន្តនៅស្រុកខ្មែរនេះ? ហើយជាពិសេសតំបន់ដែលលោករស់នៅនោះ?

[១០:១៦:៣៥]

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បាទ នៅក្នុងជំនាន់លន់ នល់ ជនជាតិវៀតណាមត្រូវគេយកមកដាក់កន្លែងប្រមូលផ្ដុំពីរកន្លែងបាទ។ ហើយនៅថ្ងៃទី ប្រហែលជាទី១៩ អ៊ីចឹងបាទៗ ទី១៩ មេសា គឺខ្មែរក្រហមបានបញ្ជាឱ្យវៀតណាមទាំងអស់ត្រឡប់ទៅប្រទេសវៀតណាមវិញបាទ។ កន្លែងនេះគឺមិនឆ្ងាយពីមន្ទីរពេទ្យទេ កន្លែងដែលចេញនេះគេហៅថា "បាំងចាក់" គឺជិតមន្ទីរពេទ្យ។ ខ្ញុំឃើញទូកច្រើន ជាច្រើនដឹកជនជាតិវៀតណាមទាំងក្មេងទាំងចាស់ ទាំងប្រុសទាំងស្រី អមដោយទូកខ្មែរក្រហម ហើយធ្វើដំណើរចុះតាមដងស្ទឹងទៅទន្លេសាបបាទ។ ខ្ញុំ -- ហើយគេនិយាយ -- ខ្ញុំៗដឹងតែប៉ុណ្ណឹងទេបាទ ត្រង់ថាគេទៅដល់

វៀតណាម ឬមិនដល់ខ្ញុំមិនដឹងដែរបាទ។ ទាល់ឥឡូវនេះខ្ញុំសួរគេ ក៏ខ្ញុំ -- ក៏គ្មានចម្លើយអ្វីច្បាស់លាស់ចំពោះខ្ញុំបាទ។

[១០:១៧:៥៦]

**ស៖** តើលោកមានដឹងថា មានអ្នកខ្លះ វៀតណាមមួយចំនួនដែលស្ថិតនៅស្រុកខ្មែរទេ ក្រោយពីថ្ងៃ១៩ មេសាហ្នឹង?

**ឆ៖** ខ្ញុំឃើញថា -- ដឹងថាមានតិចតួចណាស់ ពីព្រោះថាសូម្បីតែបុគ្គលិកពេទ្យម្នាក់ជាធ្មបៗធ្វើការនៅមន្ទីរពេទ្យស៊ីវិលជាមួយខ្ញុំ ឈ្មោះ វ៉ាន់ ណារ៉េត ហ្នឹងឪពុកគាត់ជាខ្មែរ ម្ដាយគាត់ជាវៀតណាម ប្ដីគាត់ជាខ្មែរដែរ។ នៅឆ្នាំ៧៧ គេយកគាត់ទៅសម្លាប់ទាំងអស់។ ឪពុកគាត់ទៅទទួលសម្ដេចឪ ចំពោះគាត់ និងម្ដាយគាត់ បងប្អូនគាត់ត្រូវពួកប៉ុល ពត សម្លាប់ទាំងអស់បាទ។ ហើយនៅតាមភូមិក៏ដូចគ្នាដែរ អ្នកណាដែលមានប្រពន្ធដែលមានដើមកំណើតជាវៀតណាម វៀតណាមកើតហ្នឹងប៉ុន្មានតំណហើយនោះ ក៏គេមិនទុកដែរ នៅតាមភូមិ។

**ស៖** តើលោកមានឮខ្មែរក្រហមកំណត់ប្រភេទបរទេសផ្សេងទៀតដូចជា បារាំង អង់គ្លេស អីជាដើមនេះ តើគេមានកំណត់ការប្រព្រឹត្តទៅលើពួកហ្នឹងខុសដោយឡែកទេ?

**ឆ៖** គេៗមិនដែលនិយាយពីពួកនុំងផងបាទ។ ខ្ញុំអត់ដែរៗ គេនិយាយពីពួកបរទេស បារាំងអង់គ្លេស ខ្ញុំអត់ឮគេនិយាយទេបាទ។ គេនិយាយច្រើនជាងគេគឺអាខ្មាំងយួន ពួកអា កា.ស្សេ.បេ, ពួកអាសេ.អ៊ី.អា អីហ្នឹងបាទ។ គេនិយាយៗអ៊ីចឹងបាទ។

**ស៖** សូមអរគុណ។ លោកបានពន្យល់ថា នៅពេលដែលខ្មែរក្រហមមកដល់ គឺថានៅក្នុងដំណាក់កាលជម្លៀសចេញពីបាត់ដំបងនោះ គឺថាមានការកម្ទេចព្រះវិហារកាតូលិកមួយ។ តើមានការកម្ទេចអគារសាធារណៈ ដែលមិនមែនជាអគារសាសនា ឬក៏អគារសាសនាផ្សេងទៀតដែរឬទេនៅខេត្តបាត់ដំបងនោះ?

**ឆ៖** ខ្ញុំសូមជម្រាបថា អគារកាតូលិកនៅបាត់ដំបងហ្នឹង គឺថាសង់នៅឆ្នាំ -- នៅសតវត្សរ៍ទី១៩ត្រូវខ្មែរក្រហមកម្ទេចនៅពាក់កណ្ដាលឆ្នាំ១៩៧៦ ពុំមែនកម្ទេចភ្លាមៗទេបាទ។ ហើយចំពោះវត្តវិញ គឺថាវត្តមួយចំនួន វត្តព្រះពុទ្ធសាសនាមួយចំនួន គឺថាធ្វើជាគុកៗដាក់អ្នកទោស។ ហើយវត្តមួយទៀត ធ្វើជាកន្លែងឃុំឃាំង ដូចជាវត្តកណ្ដាល នៅក្រុងបាត់ដំបង។ បើវត្តពិភិធវិញ គឺជាកន្លែងដែលគេរៀនស្លូត្រវះកាត់ វត្តពិភិធនៅកណ្ដាលទីក្រុង។ គេត្រូវការយកអ្នកណាវះកាត់លេង ដកពិសោធន៍គេយកទៅវត្ត

ពិភិធហ្នឹងឯងបាទ។ ហើយចំពោះអគារគ្រឹះ អគារសាសនាដទៃទៀត គឺថាមិនមានច្រើនទេ ៗ មាននៅបាត់ដំបងមានតែអគារពុទ្ធសាសនា អគារគ្រិស្ត ប៉ុណ្ណឹងឯង។ ហើយនិងអគារចិនប៉ុណ្ណោះ។

[១០:២២:៤០]

**ស៖** សូមអរគុណ។ សូមបំពេញនឹងសំណួរអម្បាញ់មិញនេះ ទាក់ទងទៅនឹងវត្តដែលត្រូវបានបំលែង បំប្លែងនេះ តើនេះលោកបានពិនិត្យឃើញដោយខ្លួនឯងទេការបំលែងវត្តអារាមទៅជាគុក ឬក៏ជាមន្ទីរឃុំឃាំង ឬក៏ធ្វើជាកន្លែងវះកាត់ពិសោធន៍នេះ លោកបានដឹងរឿងហ្នឹងដោយខ្លួនឯង ឃើញផ្ទាល់នឹងភ្នែក ឬក៏យ៉ាងម៉េច?

**ឆ៖** ចំពោះ ៗវត្តពិភិធ គឺថាខ្ញុំដឹង គឺថាក្រោយពី៧៩ ខ្ញុំទៅមើល ឃើញថានៅមុខកន្លែង ៗឡដុតសពនោះមានតុមួយៗ គឺថាគេវះកាត់អ្នកជំងឺនៅតុនុំងរួចទៅ គេបញ្ចូលអ្នកដែលវះកាត់ គេបញ្ចូលក្នុងឡនុំងបាទ។ នេះចំពោះវត្តពិភិធ គឺខ្ញុំដឹងខ្លួនខ្ញុំក្រោយមកទេ ប៉ុន្តែគេប្រាប់ខ្ញុំមុន ថាកន្លែងហ្នឹង។ ខ្ញុំឮមុន ខ្ញុំឃើញក្រោយបាទចំពោះវត្តហ្នឹង។ ហើយចំពោះវត្តកណ្តាល គឺថាអ្នកណាក៏ដឹងដែរ ជាកន្លែងហៅថាសន្តិសុខ គឺកន្លែងៗឃុំខ្លួនបាទ វត្តកណ្តាល ហើយជាកន្លែងៗឃ្លាំងគ្រាប់ផង វត្តហ្នឹង កណ្តាលនេះ ពីព្រោះនៅឆ្នាំ៧៩ វៀតណាមបានទម្លាក់គ្រាប់បែកលើវត្តកណ្តាលនេះ ពីព្រោះខ្មែរក្រហមមានផ្ទុកឃ្លាំងគ្រាប់នៅវត្តកណ្តាល វត្តកណ្តាលនេះបាទ។ ហើយចំពោះវត្តដទៃទៀត គឺថា ខ្ញុំដឹងដោយសារអ្នកស្រុកប្រាប់ ។ បាទ អ្នកស្រុកថាវត្តជាកន្លែងឃុំឃាំងមនុស្ស។

[១០:២៤:៤០]

**ស៖** សូមអរគុណ។ នៅពេលដែលលោកផ្លាស់ទីនៅក្នុងខេត្តបាត់ដំបងនោះ តើលោកមានបានសង្កេត -- មានបានធ្លាប់ទៅមើលស្រុកផ្សេងទៀតដែលតូចជាងខេត្តបាត់ដំបងទេនៅសម័យនោះ?

**ឆ៖** ខ្ញុំសូមជម្រាបថា នៅជំនាន់ខ្មែរក្រហមយើងខ្ញុំគ្មានសេរីភាពទៅណាស្រេចតែចិត្តទេបាទ។ ទាល់តែមានបញ្ជា បានយើងខ្ញុំទៅបាន។

**ស៖** តាមរយៈវ៉ាដ្យូ ឬក៏កិច្ចប្រជុំនោះ លោកមានដឹងថាមានរឿងអ្វីកើតឡើងទេនៅកន្លែងផ្សេងនោះក្រៅពីខេត្តបាត់ដំបងនៅក្នុងប្រទេសហ្នឹង លោកមានបានដឹងទេ?

**ឆ៖** ខ្ញុំលួចស្តាប់វ៉ាដ្យូដោយលាក់កំបាំង គឺពេលនោះឯង ខ្ញុំបានឮព័ត៌មានតិចតួចណាស់ពីស្រុកខ្មែរ តិចតួចណាស់។ ខ្ញុំឮតែម្តងពីស្រុកខ្មែរ គឺការជម្លៀសប្រជារាស្ត្រពីភ្នំពេញមកបាត់ដំបងតាមរទេះភ្លើង។ នេះខ្ញុំឮតាមវិទ្យុ វិទ្យុលួចលាក់ដែលខ្ញុំស្តាប់។ ហើយក្រោយមកទៀត នៅពេលខ្ញុំឃ្វាលគោបាទ

ពេលខ្ញុំចេញពីមន្ទីរពេទ្យ គេឲ្យខ្ញុំទៅឃ្វាលគោ។ ពេលនោះឯង ខ្ញុំពេលនោះខ្ញុំលួចស្តាប់ ខ្ញុំឮសូរព័ត៌មានក្រៅប្រទេសទៅវិញ ដែលខ្ញុំ -- ជាពិសេសព័ត៌មានពីប្រធានាធិបតីអាមេរិក ហ្សេមីខាតទ័រ។ ហើយដែលគាត់ចុះទៅនាវាមុជទឹកបរិមាណូ ទៅបើកនាវាមុជទឹកបរិមាណូ។ ហើយប្រធាននាវានេះ គឺជាអតីតប្រធានគាត់នៅពេលសង្គ្រាមលោកលើកទី២។

[១០:២៧:២២]

ហើយក្រោយមកទៀត ខ្ញុំស្តាប់វ៉ាដ្យូឮថា នាវិក -- អ្នកបើកយន្តហោះចិនម្នាក់ពាក់ស័ក្តិ៤ បានបើក *មិច*-២៧ រត់ចុះទៅតៃវ៉ាន់។ ហើយខ្ញុំឮ ជាដំណឹងចុងក្រោយដែលខ្ញុំឮ។ ហើយដល់ក្រោយមកដោយខ្ញុំអត់លទ្ធភាពរកថ្នាំពិល ពីព្រោះថ្នាំពិលត្រូវការមាសដើម្បី -- ថ្នាំពិលបីដុំ ខ្ញុំត្រូវចំណាយមាសពីរជី ខ្ញុំសុខចិត្តចំណាយមាសពីរជី ដើម្បីបានថ្នាំពិលបីដុំ។ ដល់អស់ថ្នាំពិលទៅ អស់ទាំង--

**ស៖** លោកសាក្សី ខ្ញុំមានពេលវេលាខ្លី ខ្ញុំសូមអភ័យទោស។ ឥឡូវខ្ញុំសូមឲ្យលោកឆ្លើយដោយសង្ខេបទៅនឹងសំណួរខ្ញុំ ហើយសូមអនុញ្ញាតលោកប្រធាន សូមសួរ១០សំណួរទៀត ហើយខ្ញុំសុំ១០នាទីទៀត។ លោកសាក្សី ខ្ញុំសូមអភ័យទោសដែលកាត់ផ្តាច់លោកយ៉ាងដូច្នេះ។ នៅពេលដែលលោកត្រឡប់មកមន្ទីរពេទ្យយោធានៅខែកក្កដា ឆ្នាំ១៩៧៥ តើស្ថានភាពមន្ទីរពេទ្យនេះយ៉ាងម៉េចដែរ? ខ្ញុំនិយាយពីសម្ភារៈពេទ្យ គឺថាវះកាត់អីជាដើមនោះ តើលោកសង្កេតឃើញស្ថានភាពពេទ្យនេះយ៉ាងម៉េចដែរ?

**ឆ៖** នៅពេលដែលខ្ញុំចូលមកមន្ទីរពេទ្យយោធា ព-២ គឺថាអ្វីៗ គឺថារប៉ាត់រប៉ាយទាំងអស់។ ទី១ ប្រធានមន្ទីរពេទ្យចាត់តាំងខ្ញុំឲ្យរៀបចំឱសថស្ថាន ហើយដាក់ថ្នាំតាមសណ្តាប់ធ្នាប់។ ទី២ ឲ្យខ្ញុំរៀបចំប្រដាប់ថតឆ្អឹងឡើងវិញ ពីព្រោះថាមុនពេល -- មុននេះគេបានដោះផ្នែកទាំងបីនៃគ្រឿងវិទ្យុនោះយកចេញទៅក្រៅ រួចទៅគេនាំអាប្រដាប់ទាំងបីនេះមកចូលមន្ទីរពេទ្យវិញ ហើយគេឲ្យខ្ញុំរៀបចំឡើងវិញ បាទ។ ខ្ញុំមិនដែលរៀបចំគ្រឿងវិទ្យុទេ ប៉ុន្តែចេះតែធ្វើទៅៗ ធ្វើបានៗ ហើយសមខ្ញុំរៀបចំសម្ភារៈវះកាត់ទុកជាបីប្រអប់។ ដូច្នេះ សម្ភារៈនៅកន្លែងនោះ គឺថាបានដំណើរការបាន ប៉ុន្តែការវះកាត់នៅមន្ទីរយោធាពុំធ្វើនៅមន្ទីរពេទ្យយោធាទេ គឺទៅធ្វើនៅមន្ទីរស៊ីវិលបាត់ដំបងវិញ ព្រោះបុគ្គលិកនៅមន្ទីរយោធាពុំមានសមត្ថភាពធ្វើការវះកាត់ទេ បាទ។

**ស៖** បាទសូមអរគុណ ខ្ញុំមានសំណួរមួយចំនួនទៀត។ លោកបានពន្យល់ថា គោលនយោបាយដែលខ្មែរក្រហមបានរៀបរាប់នោះ គឺថាលោក និងអ្នកផ្សេងនោះ ត្រូវតែធ្វើការនៅតាមស្រែ ហើយធ្វើកសិកម្ម ហើយនិងបង្អត់អាហារ ឬក៏ហូបចុករួម ហើយធ្វើការធ្ងន់ធ្ងរនៅតាមស្រែ។ តើបើតាមលោក

ដឹង ឬក៏តាមអ្វីដែលលោកបានសង្កេតឃើញ តើកម្មាភិបាលខ្មែរក្រហម ដែលថាពីតូចទៅធំនោះ មានអនុវត្តគោលនយោបាយនោះ ខ្លួនឯងដែរទេ សម្រាប់ខ្លួនឯងទេ ឬក៏គេទទួលអភ័យឯកសិទ្ធិពិសេសណាមួយខុសពីគេ ទាក់ទងនឹងការហូបចុក ឬការធ្វើការងារទាំងអស់នេះ?

[១០:៣១:៤៩]

**ផ៖** ខ្ញុំសូមជម្រាបថា កម្មាភិបាលខ្មែរក្រហម គេអនុវត្តនយោបាយមួយ គេហៅថា លាក់-ការណ៍ៗ គឺបានសេចក្ដីថា គេហូបគ្រប់គ្រាន់ឲ្យស្ងាត់ មិនឲ្យអ្នកណាដឹង។ ហើយចំពោះប្រជារាស្ត្រ គឺថាហូបមិនគ្រប់គ្រាន់។

**សៈ** សូមអរគុណលោកស្រី។ កាលពីព្រឹកមិញ ហើយនិងម្សិលមិញ លោកបានពន្យល់ថា "នៅក្នុងភូមិរបស់លោកនោះ មានអ្នកដែលគេជម្លៀសមកពីភ្នំពេញ មកដល់ភូមិហ្នឹង"។ តើលោកបានពិភាក្សាជាមួយអ្នកដែលមកពីភ្នំពេញហ្នឹងដែរឬទេ អ្នកដែលគេជម្លៀសមកហ្នឹង?

**ផ៖** បាទ ពេលដែលនៅក្រោយពេលដែលប្រជារាស្ត្រជម្លៀសមកពីភ្នំពេញមកភូមិខ្ញុំនេះ ខ្ញុំហើយនិងម្ដាយខ្ញុំដើរៗ ទៅមើលពួកគេក្នុងបំណងក្រែងជួបបងប្អូនមកពីភ្នំពេញ ហើយក៏បានពិភាក្សាជាមួយគេ បាទ។ បាននិយាយៗ យើងមិនបានិយាយច្រើនទេ បាទ គ្រាន់តែនិយាយសួរសុខទុក្ខគេប៉ុណ្ណឹងឯង។ ប៉ុន្តែពេលនោះ ខ្ញុំសង្កេតឃើញថា អ្នកទាំងអស់នោះ បានធ្វើដំណើរយ៉ាងវែងឆ្ងាយ មានការហត់នឿយ ប៉ុន្តែខ្ញុំឃើញថា ពួកគេនៅមានស្បៀងនៅជាប់ខ្លួននៅឡើយ បាទ។ ប៉ុន្តែអ្វីដែលគួរកត់សម្គាល់ គឺយើងឃើញថា កុមារៗ អ្នកជម្លៀសអត់លេងទេ អត់សើចអត់អីទេ បាទ មិនរត់លេងដូចក្មេងធម្មតាទេ បាទ។

**សៈ** តើអ្នកដែលគេជម្លៀសទាំងអស់នោះ មានបានរៀបរាប់ពីការជម្លៀសចេញពីភ្នំពេញប្រាប់លោកដែរឬទេ? ហើយការជម្លៀសហ្នឹង តើដូចជាការជម្លៀសចេញពីបាត់ដំបងដែរឬទេ ហើយការណែនាំរបស់ខ្មែរក្រហមនោះ វាដូចគ្នានឹងការណែនាំដែលពួកគេបានធ្វើទៅកាន់លោកដែរឬទេ? តើលក្ខខណ្ឌនៃការជម្លៀសហ្នឹង ដែលជម្លៀសចេញពីក្រុងភ្នំពេញទៅហ្នឹង ដូចលក្ខខណ្ឌនៃការជម្លៀសចេញពីទីក្រុងបាត់ដំបងដែរឬទេ?

[១០:៣៤:៥៧]

**ផ៖** ចំពោះខ្ញុំ ខ្ញុំយល់ឃើញថា ការជម្លៀសនៅក្រុងបាត់ដំបង មិនដូចនៅភ្នំពេញទេ បាទ។ ពីព្រោះបាត់ដំបងប្រជារាស្ត្រតិចជាងភ្នំពេញ។ ដូច្នេះខ្ញុំយល់ថាអ្នកដែលជម្លៀសពីភ្នំពេញមក គឺថាមាន

ការលំបាកច្រើន។ លំបាកដោយមនុស្សច្រើនផង ដោយដំណើរវែងឆ្ងាយផង ដូច្នេះមិនអាចប្រៀបធៀបគ្នាបានទេបាទ។

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតបទៅនឹងសំណួរនូវអ្វីដែលលោកដឹង ប្រសិនបើលោកមិនដឹងទេ លោកឆ្លើយថាលោកមិនដឹងទេ ជៀសវាងលោកប្រើការយល់ឃើញរបស់លោកអត្តនោម័តិឆ្លើយតបទៅនឹងសំណួរ។ ធ្វើដូច្នេះមិនបានទេ មិនមានប្រយោជន៍អ្វីនៅក្នុងការស្វែងរកការពិតទេ។ ការពិតបញ្ហាផ្សេងទៀតគឺជារឿងបទពិសោធន៍ លុះត្រាតែឃើញ ដឹង ឮ ជាញឹកញាប់ជារៀងរាល់ថ្ងៃ ទើបជាបទពិសោធន៍ ឬក៏ជាការសង្កេតរបស់លោក។

[១០:៣៦:៣១]

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ខ្ញុំអម្បាញ់មិញនេះ ខ្ញុំនិយាយថាៗ តើលោកមានឮគេប្រាប់លោកដែរឬទេ លោកជាមនុស្សមានបទពិសោធន៍ ហើយនៅឆ្នាំ៧៥នេះ ក្នុងរយៈពេលពីរបីខែ ហើយក្រោយមកទៀតនោះពីខែមីនា ឆ្នាំ១៩៧៧ ខ្មែរក្រហមសុំឲ្យលោកទៅធ្វើការនៅតាមស្រែ ហើយដូចមិនឲ្យលោកប្រើជំនាញរបស់លោកជាពេទ្យនោះទេ។ តើគោលបំណងគេនោះយ៉ាងម៉េចបានជា -- ចំពោះគេនោះបានជាការសំខាន់ជាងដែលលោកនៅតាមស្រែ វាជាសំខាន់ជាងធ្វើការជាគ្រូពេទ្យនោះ? គេមានបានពន្យល់មូលហេតុទេថាម៉េចបានបញ្ជូនលោកទៅធ្វើការនៅតាមស្រែ ហើយក្នុងខណៈដែលជាគ្រូពេទ្យសោះនេះ?

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បាទ រឿងនេះខ្ញុំមិនយល់ដែរបាទ។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាតឲ្យមួយសំណួរទៀត។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធានជាការប្រសើរហើយ ព្រោះនេះជាសំណួរចុងក្រោយរបស់ខ្ញុំហើយ។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ដោយមានការជម្លៀសចេញពីបាត់ដំបង និងជម្លៀសប្រជាជនទៅតាមស្រុកស្រែ ហើយនិងការជម្លៀសបងប្អូនរបស់លោកនោះ តើបងប្អូនរបស់លោក ក្រុមគ្រួសាររបស់ទាំងអស់នោះទទួល

ផលវិបាកអ្វីដែរអំពីការជម្លៀសទាំងអស់នេះ?

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បងប្អូនរបស់ខ្ញុំគឺថាទៅធ្វើស្រែដូចគេដូចឯងអ៊ីចឹងដែរបាទ។

[១០:៣៨:៥៧]

*(សម្រាករយៈពេលខ្លី)*

[១០:៣៩:១៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅក្នុងរយៈសម្រាកដល់សាក្សីរូបនេះ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញនៅវេលាម៉ោងដប់មួយ។

សម្រាកចុះ!

បាទ យើងឲ្យមួយៗសំណួរ លោកស្រីពេញចិត្តហើយ ហើយសួររួច សាក្សីឆ្លើយរួចហើយ។ យើងមិនអនុញ្ញាតឲ្យលោកស្រីសួរទៀតទេ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤០ នាទី ដល់ម៉ោង ១១:០០ នាទី)*

[១១:០០:៥៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោកនួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ! សូមគោរពលោកប្រធាន!

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សុន អរុណ៖**

**ស៖** សូមជម្រាបសួរលោកវេជ្ជបណ្ឌិត ហ៊ិន ឈុនលី។ ខ្ញុំឈ្មោះ សុន អរុណ មេធាវីការពារលោក នួន ជា។ ថ្ងៃនេះ ខ្ញុំមានសំណួរមួយចំនួនសួរប្រហែលកន្លះម៉ោង រួចពីហ្នឹងមានសហភាតាខ្ញុំនឹងសួរបន្ត។ ជាដំបូង ខ្ញុំសូមសួរប្រវត្តិរបស់លោកខ្លះ ដែលខ្ញុំក្តាប់មិនបាននៅក្នុងសៀវភៅរបស់លោក។ ពេលដែលលោកវេជ្ជបណ្ឌិតបានរៀនចប់វេជ្ជបណ្ឌិត ពេលហ្នឹងនៅឆ្នាំណា? ហើយលោកពេលហ្នឹងលោក -- រាជរដ្ឋាភិបាលបានបញ្ជូនលោកទៅកាន់ការនៅខេត្តបាត់ដំបងតែម្តង ឬក៏យ៉ាងម៉េច?

[១១:០២:៤១]

**លោក ហ៊ិន ឈុនលី៖**

**ឆ៖** បាទ ខ្ញុំចេញជាវេជ្ជបណ្ឌិតនៅឆ្នាំ១៩៦៧ ហើយខ្ញុំក៏បានទទួលការអនុញ្ញាតឲ្យទៅធ្វើការជាគ្រូពេទ្យនៅមន្ទីរពេទ្យខេត្តបាត់ដំ -- មន្ទីរពេទ្យស៊ីវិលខេត្តបាត់ដំបង។

**ស៖** លុះដល់ឆ្នាំណាបានលោកចេញផុតពីខេត្តបាត់ដំបងវិញ?

**ឆ៖** ធ្វើការនៅមន្ទីរពេទ្យខេត្តបាត់ដំបងពីឆ្នាំ១៩៦៧ ដល់ពាក់កណ្តាលឆ្នាំ១៩៧៣។ បន្ទាប់មកនៅឆ្នាំ១៩៧៣នេះ ខ្ញុំត្រូវកំណែនធ្វើជាទាហានចូលទៅធ្វើការនៅមន្ទីរពេទ្យយោធាខេត្តបាត់ដំបង ហៅថាមន្ទីរពេទ្យ៤០៣ ពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៥។

**ស៖** អរគុណ។ បន្ទាប់ពីឆ្នាំ១៩៧៥ លោកបានផ្លាស់ទៅណាទៀត?

**ប្រធានអង្គជំនុំ៖**

កុំអាលៗទាន់ឆ្លើយ!

**លោក ហ៊ិន ឈុនលី៖**

**ឆ៖** បន្ទាប់ពីឆ្នាំ១៩៧៥ ខ្ញុំៗធ្វើការ ខ្ញុំនៅបាត់ដំបងៗ រហូតដល់ឆ្នាំ៨២ បានខ្ញុំមកភ្នំពេញ។

**សួរដោយលោក សុន អរុណ៖**

**ស៖** បើដូច្នោះមួយរយៈពេលកម្ពុជាប្រជាធិតេយ្យលោកនៅបាត់ដំបងរហូត?

**ឆ៖** បាទ ខ្ញុំនៅបាត់ដំបងរហូត។

[១១:០៥:០៤]

**ស៖** ខ្ញុំមានសំណួរមួយបន្ត។ នៅឆ្នាំ១៩៧៥ ខ្ញុំព្រឹកមិញ ឬក៏ពីម្សិលមិញខ្ញុំស្ដាប់មិនច្បាស់ក៏មិនដឹង ឬក៏ៗខ្ញុំច្រឡំក៏មិនដឹង ឬក៏ -- ខ្ញុំឮថា លោកឆ្លើយប្រាប់ជម្រាបលោកព្រះរាជអាជ្ញាថា ថ្ងៃ១៧ មីនា ឆ្នាំ១៩៧៥ ពេលហ្នឹងបាត់ដំបងបានធ្លាក់ចូលក្នុងកណ្ដាប់ដៃខ្មែរក្រហម។ អ៊ីចឹងមែនទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ឆ្លើយបាទ! ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការសិន។

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បាទ គឺនៅឆ្នាំមួយពាន់-- នៅថ្ងៃ១៧ មេសា ១៩៧៥ គឺថាដោយគោរពតាមការផ្សព្វផ្សាយរបស់វិទ្យុភ្នំពេញ គឺថាកងទ័ពបានដាក់អាវុធចុះ គឺចុះចាញ់របបខ្មែរក្រហមបាទ។

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំសូមសួរបញ្ជាក់ម្ដងទៀត។ សូមឲ្យលោកវេជ្ជបណ្ឌិតរំឭកឡើងវិញ បើសិនជាអាចធ្វើបាន។ ក្រុងបាត់ដំបងទាំងមូលធ្លាក់ចូលក្នុងកងទ័ពរបស់ខ្មែរក្រហម នៅថ្ងៃណាខែណាពិតប្រាកដ?

[១១:០៧:១៣]

**ឆ៖** គឺបើនិយាយចំទៅ គឺនៅថ្ងៃ១៧ មេសា ១៩៧៥ ដោយទទួលបទបញ្ជាតាមរយៈវិទ្យុក្រុងភ្នំពេញ ដែលប្រកាសដោយ ដូចខ្ញុំបាននិយាយកាលពីម្សិលមិញអ៊ីចឹង ប្រកាសដោយឧត្ដមសេនីយ៍ ម៉ី ស៊ីចន និងឧត្ដមសេនីយ៍ លន់ ណុន។

**ស៖** នៅពេលនុ៎ង ពីព្រឹកមិញលោកបានបញ្ជាក់ម្ដងហើយថា លោកអភិបាលខេត្ត សេក សំអៀត បានភៀសខ្លួននៅថ្ងៃដែលខ្មែរក្រហមចូលក្រុងបាត់ដំបងអ៊ីចឹង។ មែន អ៊ីចឹងទេ?

**ឆ៖** នៅថ្ងៃ១៧ មេសា ១៩៧៥ នៅពេលព្រឹកខ្មែរក្រហមអត់មានចូលមកក្រុងបាត់ដំបងទេ។ អត់មានចូលទេ គឺស្ងាត់ឈឹង មិនដឹង -- ខ្ញុំមិនដឹងមូលហេតុដែរ។ អត់មានទ័ពខ្មែរក្រហមណាមួយចូលទេបាទ។ ហេតុដូច្នេះបានជាម៉ោងមួយ បានជាលោក សេក សំអៀត ដែលជាអភិបាលខេត្តហ្នឹងគាត់បើកឡាន ហើយឡើងអេឡេកូទៅៗថៃ បាទ។ ដល់ម៉ោងបីៗថ្ងៃបានទាហានខ្មែរក្រហមក្មេងៗជាក្រុមតូចៗបានចូលមកក្រុងបណ្ដាក់គ្នា។

[១១:០៩:០១]

**សៈ** អរគុណ។ លោកឧត្តមសេនីយ ម៉ី ស៊ីចន និងលោកឧត្តមសេនីយ៍ លន់ ណុន ជាប្អូន លន់ នល់ បានប្រកាសឲ្យដាក់អាវុធ។ ហេតុអីបានជាលោកដឹងទេថា ហេតុអ្វីបានជាឧត្តមសេនីយ៍ទាំងពីរនាក់ហ្នឹងប្រកាសដាក់អាវុធបើខ្លួនជាសត្រូវរបស់ខ្មែរក្រហមសោះ? លោកយល់រឿងហ្នឹងទេ? លោកដឹងរឿងហ្នឹង ឬក៏លោកបានព័ត៌មានហ្នឹងពីណាមកទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ លោក លោកស្រី ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ដែលមានលក្ខណៈឲ្យសាក្សីធ្វើការសន្និដ្ឋានដោយស្មានៗ។ សូមអរគុណ។

[១១:០៩:៥៥]

**លោក សុន អរុណ៖**

នេះមិនមែនការសន្និដ្ឋានទេ។ ខ្ញុំសួរថា លោកដឹងទេ? លោកបានព័ត៌មានហ្នឹងពីណា? ឬកលោកយល់ លោកបានព័ត៌មានហ្នឹងពីណា? ឬលោកដឹងដោយខ្លួនឯង? អានេះមិនមែនជាការស្មានទេ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី សុន អរុណ រៀបចំសំណួរឡើងវិញ!

សំណួរលោកពិតជាពិបាកក្នុងការយល់ ហើយយើងគិតថា ពិបាកយល់ វាអាចនាំឲ្យពិបាកឆ្លើយ។ សួរឲ្យច្បាស់លាស់ អំមិញគឺមានពាក្យដែលនាំឲ្យមានការជំទាស់តវ៉ា លោកកែសម្រួលឡើងវិញឲ្យច្បាស់ ចុងក្រោយ ដើម្បីឲ្យសាក្សីស្តាប់យល់ ហើយនិងឆ្លើយតបនឹងសំណួររបស់លោកបាន។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក សុន អរុណ៖**

**សៈ** ខ្ញុំសូមសួរឡើងវិញនូវសំណួររបស់ខ្ញុំ។ លោកវេជ្ជបណ្ឌិត លោកបានជម្រាបទៅខាងព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីរួចហើយថា ពេលដែលថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលនុំងមានឧត្តមសេនីយ៍ពីរនាក់ ឈ្មោះ ម៉ី ស៊ីចន និង លន់ ណុន ប្រកាសឲ្យខ្មែរ -- ឲ្យសាធារណរដ្ឋ ទាហាន

សាធារណរដ្ឋដាក់អាវុធ។ តើលោកដឹងរឿងហ្នឹងពិតថា ឲ្យដាក់អាវុធមែនទែន ឈ្មោះ ម៉ី ស៊ីចន និង លន់ ណុន ហ្នឹងអ្នកបញ្ជាអ៊ីចឹង ឬក៏លោកឮពាក្យចចាមអារ៉ាមទេពេលនុ៎ង? ពីព្រោះអីពីរនាក់ហ្នឹងជាសត្រូវរបស់ខ្មែរក្រហម។

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បាទ ខ្ញុំឮដោយផ្ទាល់តាមវិទ្យុ គឺគាត់ប្រកាសនូវការចុះចាញ់នៃរបបសាធារណរដ្ឋ ហើយអំពាវនាវឲ្យនាយទាហាន ពលទាហានទាំងអស់ទូទាំងប្រទេសដាក់អាវុធចុះ។

**ស៖** អរគុណ។ លោកវេជ្ជបណ្ឌិតបានជម្រាបព្រះរាជអាជ្ញាថា ចំពោះពេទ្យស៊ីវិលខ្មែរក្រហមបានសម្លាប់បន្តបន្ទាប់ ជាពិសេសពីឆ្នាំ១៩៧៧ ទៅ។ តើលោកដឹងដោយរបៀបណា ពេលនោះ ដោយគេប្រាប់លោក ឬក៏ដោយបានឃើញនឹងភ្នែកផ្ទាល់?

[១១:១៣:០៥]

**ឆ៖** ខ្ញុំបានជម្រាបម្សិលមិញ គឺថាចំពោះពេទ្យទាហាន។ ខ្ញុំសូមនិយាយពេទ្យទាហានបាទ ចាប់ពីស័ក្តិ១ ឡើងទៅ គឺគេចាប់សម្លាប់មុនគេបាទ។ ហើយចំពោះពេទ្យស៊ីវិល គឺគេយកទៅឲ្យធ្វើការនៅមន្ទីរពេទ្យស្រុក ដែលគេយកវិទ្យាល័យធ្វើជាអគារពេទ្យបាទ។ ហើយដល់ នៅថ្ងៃ៣១ ខែមករា ឆ្នាំ១៩៧៧ គឺថាពេទ្យស៊ីវិលទាំងអស់ គេឲ្យចេញមកធ្វើស្រែ។ ពេលចេញនោះឯង គឺថាពួកពេទ្យទាំងអស់នេះត្រូវបាត់ខ្លួនម្តងមួយៗបាទ។ ហើយអ្នកបាត់ខ្លួនដែលខ្ញុំបានដឹងមុនគេ គឺដូចខ្ញុំបានជម្រាបអំមិញមុនហ្នឹង គឺថាលោក ពឹង គឹមស៊ា ហើយនិងលោក ឃឹម គឹមសាន ដែលមានឈ្មោះនៅទួលស្លែង។ ហើយចំពោះអ្នកប៉ុន្មាននាក់ទៀតនោះ គឺថាគេនាំទៅ គេថានាំទៅព្យាបាលអ្នកនេះ នាំទៅព្យាបាលអ្នកនោះ ហើយក៏បាត់ខ្លួនទៅ។ នេះគឺការ -- ខ្ញុំមិនបានឃើញទេ ប៉ុន្តែតាមការនិយាយប្រាប់របស់ប្រពន្ធរបស់គាត់ ដែលជាភរិយាមេម៉ាយ។

[១១:១៤:៤០]

**ស៖** អរគុណ។ លោកវេជ្ជបណ្ឌិតបានឆ្លើយជម្រាបទៅព្រះរាជអាជ្ញាកាលពីម្សិលមិញថា ប្រពន្ធលោក ស៊ីវ ហេង ជាបងរបស់ប្រពន្ធ នួន ជា។ រឿងនេះពិតជាអ៊ីចឹងទេ បើលោកស្គាល់ច្បាស់?

**ប្រធានអង្គជំនុំ៖**

កុំអាលៗទាន់ឆ្លើយ!

មន្ត្រីរដ្ឋបាលតុលាការរៀបចំនូវក្បាលមីក្រូហ្វូនដាក់បញ្ឆិតបន្តិចទៅ ដើម្បីអាចឲ្យគាត់មើលឃើញ

ភ្លើងក្រហម។ ដាក់សង្កត់ទៅក្រោមក៏បាន ឬលើកងាកបន្តិច កុំឲ្យគាត់ -- ចំអ៊ីចឹង មើលមិនឃើញ។

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បាទ ប្រពន្ធលោក ស៊ីវ ហេង មិនមែនជាបងម្ដាយលោក នួន ជា ទេ។ ប្រពន្ធលោក ស៊ីវ ហេង ជាប្អូនស្រីរបស់លោក នួន ជា។ គាត់ទើបនឹងស្លាប់ជាង១ឆ្នាំមុននេះបាទ។

**ស៖** លោកបានជម្រាបបន្តទៅទៀត ពីម្សិលមិញ លោកមានប្រសាសន៍ថា "គ្រួសារលោក នួន ជា ក៏ខ្ញុំស្គាល់ដែរ។ គ្រួសារលោក នួន ជា ជាគ្រួសារមួយល្អ"។ នេះជាសម្ដីលោកមានប្រសាសន៍ពីម្សិល "ខ្ញុំធ្លាប់ព្យាបាលគ្រួសារគាត់។ បើភូមិណាអត់ឃ្លាន ឯភូមិវត្តគរ មិនដែលអត់ឃ្លានទេ។ អ្នកផ្គត់ផ្គង់ម្ហូបម្ហា ម្ដាយ នួន ជា ខ្ញុំស្គាល់។ ឯម្ដាយ នួន ជា ជាអ្នកផ្គត់ផ្គង់ម្ហូបដល់ពេទ្យ ព-២ ដែរ"

ខ្ញុំសូមថា តើលោកស្គាល់លោក នួន ជា បានច្បាស់លាស់ទេ? ឬក៏ស្គាល់តែគ្រួសារគាត់ទេ?

[១១:១៧:១៦]

**ឆ៖** ខ្ញុំសូមកែតម្រូវសំណួរលោក គឺថាម្ដាយលោក នួន ជា ពុំមែនជាអ្នកផ្គត់ផ្គង់ម្ហូបអាហារដល់មន្ទីរពេទ្យទេបាទ។ គឺខ្ញុំចង់និយាយថា អ្នកផ្គត់ផ្គង់ម្ហូបអាហារមន្ទីរពេទ្យ ព-១, ព-២ ឬមួយគេហៅថា ប្រធានសេដ្ឋកិច្ចៗតំបន់នោះ គឺថាជាអ្នកផ្ដល់ម្ហូប -- ជាអ្នកផ្គត់ផ្គង់ម្ហូបអាហារដល់មន្ទីរពេទ្យ ព-១ និងមន្ទីរពេទ្យ ព-២ ហើយក៏គាត់ផ្ដល់ម្ហូបអាហារដល់ម្ដាយលោក នួន ជា ដែរ។

**ស៖** សូមទោស ខ្ញុំច្រឡំ ខ្ញុំសូមកែសម្រួលត្រង់ហ្នឹង បើខ្ញុំសួរលោកខុស។ ប៉ុន្តែខ្ញុំសួរ នូវសំណួរខ្ញុំនៅបន្តដដែល គឺត្រង់ថា លោកបាននិយាយពីម្សិលមិញថា លោកស្គាល់គ្រួសារលោក នួន ជា ច្បាស់លាស់។ ចុះលោក នួន ជា លោកស្គាល់ច្បាស់លាស់ដែរឬទេ?

**ឆ៖** គ្រួសារលោក នួន ជា ទាំងជីដូនមួយគាត់ អ្វីៗ ខ្ញុំស្គាល់ ភាគីច្រើនខ្ញុំស្គាល់ ខ្ញុំរាប់អានសុទ្ធតែជាមនុស្សល្អ។ ម្ដាយលោក នួន ជា ក៏ជាមនុស្សដែលគេគោរព ប៉ុន្តែខ្ញុំមិនដែលជួប ខ្ញុំមិនដែលស្គាល់លោក នួន ជា ទេ បាទ។

[១១:១៩:០៦]

**ស៖** លោកមានប្រសាសន៍ថា លោកមិនដែលស្គាល់លោក នួន ជា ទេ ប៉ុន្តែដល់ពេលខ្មែរក្រហម -- កម្ពុជាប្រជាធិបតេយ្យ ដល់ពេលកម្ពុជាប្រជាធិបតេយ្យ តើលោកដែលឮឈ្មោះគាត់ទេ?

**ឆ៖** នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំធ្លាប់សួរឈ្មោះលោក នួន ជា ជាប្រធានរដ្ឋសភា ប៉ុន្តែខ្ញុំមិនចាំថា ខ្ញុំដឹងៗនៅពេលណា ខ្ញុំមិនចាំបាទ។

**សៈ** លោកវេជ្ជបណ្ឌិតមានបានឮ ក្រៅពីលោក នួន ជា ធ្វើជាប្រធានរដ្ឋសភា លោកមានឮថា លោក នួន ជា មានមុខងារអ្វីផ្សេងទៀតទេ នៅក្នុងកម្ពុជាប្រជាធិបតេយ្យ?

**ធៈ** ខ្ញុំអត់ដឹងទេបាទ។

**សៈ** បើសិនជាខ្ញុំសួរលោក ហើយលោកមិនដឹងអាហ្នឹងឆ្លើយមិនដឹងដូចអំមិញចឹង បើលោកដឹង សូមលោករាយរាប់ជម្រាបតុលាការផង។ លោកបានធ្លាប់ឮឈ្មោះ នួន ជា ធ្វើជាប្រធានរដ្ឋសភានៃរបប កម្ពុជាប្រជាធិបតេយ្យ លោកដែលឮថាលោក នួន ជា ហ្នឹងមានអំណាច និងបញ្ជាទៅខាងរដ្ឋាភិបាលឲ្យ ចាប់មនុស្សយកទៅឃុំឃាំង ឲ្យចាប់មនុស្សយកទៅសម្លាប់ចោល បង្អត់បាយប្រជាពលរដ្ឋអីចឹងទេ?

[១១:២១:១៩]

**ធៈ** ចំពោះរឿងនេះ ខ្ញុំមិនដឹងទេបាទ។

**សៈ** សូមអរគុណ។ នៅក្នុងសៀវភៅលោកសរសេរដដែល លោកសរសេរថា "បុរសម្នាក់ ដែលជាអតីតបុគ្គលិកគយនៅក្រុងបាត់ដំបង និងជាប្អូនបង្កើតរបស់លោក នួន ជា –បងធំទី២ បន្ទាប់ពី ប៉ុល ពត– មិនត្រូវបានពួកខ្មែរក្រហមនាំយកទៅណាទេ"។ ខ្ញុំសួរចំណុចមួយខ្លី គឺត្រង់បងធំទី២ តើ លោកសរសេរក្នុងសៀវភៅរបស់លោកហ្នឹង លោកយកពាក្យហ្នឹងយកមកដាក់សរសេរ ឬក៏លោក បង្កើតខ្លួនឯង ឬក៏លោកឮគេថា?

**ធៈ** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**សៈ** ចាំៗ ក្រហមសិន។

**ធៈ** ខ្ញុំប្រើពាក្យ "បងទី២" នេះគឺឮតាមគេតៗមក ប៉ុន្តែខ្ញុំមិនច្បាស់ថាខ្ញុំឮពេលណាទេ។ នេះខ្ញុំ និយាយដោយត្រង់បាទ។

**សៈ** ខ្ញុំសួរតទៅទៀត។ ក្នុងសៀវភៅរបស់លោកដដែលត្រង់ ERN 00678759 ជាខ្មែរ, ជា អង់គ្លេស 00369682។ ចំពោះលោក ស៊ីវ ហេង ដែលលោកវេជ្ជបណ្ឌិតជម្រាបទៅព្រះរាជអាជ្ញា ពីម្សិលថា និងតាមសៀវភៅដែលលោកសរសេរថា "ស៊ីវ ហេង បានចុះចូលជាមួយព្រះមហាក្សត្រ នរោត្តម សីហនុ នៅក្រោយឆ្នាំ១៩៥៤ ក្រោយសន្និសីទហ្សឺណែវ"។ តើលោកអានបញ្ជាក់បានទេ លោក (សូមទោស) តើលោកអាចបញ្ជាក់បានទេថាលោក ស៊ីវ ហេង បានចុះចូលសម្តេច នរោត្តម សីហនុ នៅឆ្នាំណា? ដើម្បីជាឯកសារ និងដើម្បីជាប្រវត្តិសាស្ត្រ។

[១១:២៤:៣៣]

**ឆ៖** ចំពោះករណីលោក ស៊ីវ ហេង គឺថាខ្ញុំគ្រាន់តែដឹងច្បាស់ថា បន្ទាប់ពីសន្និសីទទីក្រុងហ្សឺណែវ គាត់បានមកសុំចុះចូលសម្តេច សីហនុ មកបម្រើកងទ័ពខេមរភូមិន្ទ ហើយសម្តេចប្រទានងារលោកជា "វរសេនីយ៍ឯក"។ នេះខ្ញុំដឹងប៉ុណ្ណឹងបាទ ដល់ក្រោយមកទៀតគាត់ឈឺ ពិការមួយជំហៀងខ្លួន ហើយគាត់ទៅសម្រាកនៅផ្ទះប្រពន្ធគាត់នៅភូមិវត្តគរបាត់ដំបង រហូតដល់ឆ្នាំ៧៥។

**លោក សុន អរុណ៖**

ខ្ញុំមានសំណួរតែប៉ុណ្ណេះ។ សូមអរគុណលោកវេជ្ជបណ្ឌិត អរគុណលោកប្រធាន។ សហភាតាខ្ញុំនឹងបន្ត។

**ប្រធានអង្គជំនុំ៖**

អរគុណ។ អញ្ជើញ!

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រីទាំងអស់ ទាំងក្នុង និងក្រៅសវនាការ។

[១១:២៦:១០]

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

សូមជម្រាបសួរលោកវេជ្ជបណ្ឌិត ឈុនលី។ ខ្ញុំឈ្មោះ ហ្សាស្តើ ប៉ោ។ ខ្ញុំជាមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ហើយខ្ញុំមានសំណួរដើម្បីធ្វើការចោទសួរលោកនៅថ្ងៃនេះ គឺជាសំណួរដែលបន្តពីអ្វីដែលបានសួរដោយព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីព្រមទាំងបន្តពីលោក អរុណ ផងដែរ។ ខ្ញុំព្យាយាមតាំងសំណួរឲ្យច្បាស់លាស់ ប្រសិនបើលោកមានបញ្ហា ឬក៏មិនច្បាស់អំពីសំណួររបស់ខ្ញុំ សូមលោកសួរខ្ញុំ ដើម្បីឲ្យខ្ញុំបញ្ជាក់បំភ្លឺ។

**ស៖** កាលពីម្សិលមិញលោកបានពណ៌នាដោយសង្ខេបអំពីមូលហេតុដែលលោកចាប់ផ្តើមសរសេរសៀវភៅ។ ហើយលោកបានរៀបរាប់ពីអ្វីដែលកើតឡើងនៅក្នុងរបបខ្មែរក្រហម ការកត់ត្រាកំណត់ត្រានៅក្នុងរបបខ្មែរក្រហម ហើយក្រោយមកលោកបានបំផ្លាញកំណត់ត្រានោះចោល។ សំណួរទី១ របស់ខ្ញុំគឺថា ហេតុអ្វីនៅក្នុងរបបខ្មែរក្រហមហ្នឹង លោកធ្វើការកត់ត្រានោះ?

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ចំពោះខ្ញុំដែលជាបញ្ញវន្តម្នាក់ ខ្ញុំយល់ថាការកត់ត្រា ការសរសេរជាផ្នែកមួយដ៏សំខាន់នៃ

ជីវិតមនុស្ស។ ប៉ុន្តែនៅក្នុងរបបខ្មែរក្រហម ខ្មែរក្រហមៗឆែកឆេរផ្ទះច្រើនណាស់ ច្រើនដង ច្រើនណាស់។ ដូច្នេះបើគេប្រទះឯកសារដែលខ្ញុំកត់ត្រា គេនឹងយកខ្ញុំទៅសម្លាប់ចោល។ ហេតុដូច្នេះហើយបានជាខ្ញុំសម្រេចថា ខ្ញុំបំផ្លាញចោលនូវកំណត់ហេតុដែលខ្ញុំបានកត់ត្រានោះ ហើយខ្ញុំខិតខំប្រើខួរក្បាលខ្ញុំរកប្រើ រកគន្លឹះពិសេសសំខាន់ៗ ដើម្បីចងចាំនូវព្រឹត្តិការណ៍សំខាន់ៗ។

[១១:២៨:៤៩]

**ស៖** តើនៅក្រោយរបបខ្មែរក្រហមហ្នឹង តើរយៈពេលប្រហែលប៉ុន្មានដែរ ក្រោយរបបខ្មែរក្រហមដែលលោកចាប់ផ្តើមសរសេរឡើងវិញនូវបទពិសោធន៍របស់លោកក្នុងសម័យខ្មែរក្រហមនោះ?

**ឆ៖** ខ្ញុំចាប់ផ្តើមសរសេរសៀវភៅនេះនៅឆ្នាំ២០០៦ បាទ ២០០៦។ ខ្ញុំប្រើរយៈពេលយូរពីព្រោះថាលោកដឹងស្រាប់ហើយថា ចូលមក៧៩ ម្នាក់ៗខិតខំធ្វើម៉េចៗផ្គត់ផ្គង់ជីវភាពប្រចាំគ្រួសារ ហើយទន្ទឹមនឹងនោះក៏មិនភ្លេចដែរនូវគោលបំណងក្នុងការសរសេរនេះ។ ខ្ញុំចាប់ផ្តើមសរសេរនៅ -- តាមពិតខ្ញុំចាប់ផ្តើមសរសេរនៅឆ្នាំ២០០៤បាទ។ ប៉ុន្តែ ដោយពេលខ្ញុំសរសេរទៅ ពេលយប់ខ្ញុំទទួលដំណេកមិនបានចេះ តែយល់សប្តិឃើញអាក្រក់។ ខ្ញុំសាកចោល១ខែ ខ្ញុំចាប់ផ្តើមសរសេរទៀត មានព្រឹត្តិការណ៍មកវាយលុកខួរក្បាលខ្ញុំនៅពេលយប់ទៀត។ ខ្ញុំសរសេរមិនបាន ទើបនៅឆ្នាំ២០០៦ ខ្ញុំសម្រេចសរសេរបាទសរសេរទាល់តែចប់សៀវភៅនេះ។ ២០០៦ នេះជាសៀវភៅបោះពុម្ពលើកទី១ ហើយទី២ គឺ២០១០បាទ។

**ស៖** ដូច្នេះនៅក្នុងឆ្នាំ២០០៤ គឺជាពេលដំបូងដែលលោកចាប់ផ្តើមសរសេរនូវបទពិសោធន៍របស់លោកចូលទៅក្នុងសៀវភៅ តើអ៊ីចឹងមែនដែរឬទេ?

**ឆ៖** បាទ ខ្ញុំចាប់ផ្តើមសរសេរ ២០០៤មក ប៉ុន្តែសរសេរទៅពេលយប់ឡើងខ្ញុំដេកមិនលក់ ហើយខ្ញុំក៏ផ្អាកទៅ សាក១ខែ សាកសរសេរម្តងទៀត ដេកមិនលក់ទៀត។ ទាល់តែ២០០៦ ខ្ញុំខំថាសរសេរឲ្យទាល់តែបាន។

[១១:៣១:៤២]

**ស៖** សៀវភៅគឺមាននូវកាលបរិច្ឆេទជាក់លាក់ ក៏ដូចជាព្រឹត្តិការណ៍ជាក់លាក់ជាច្រើន។ ខ្ញុំឆ្ងល់ថា តើលោកពឹងផ្អែកទៅលើមូលដ្ឋាន ឬក៏ពឹងផ្អែកទៅលើប្រភពព័ត៌មានដទៃទៀត ដើម្បីសរសេរដែរឬទេ គឺខ្ញុំចង់និយាយថា តើលោកពឹងផ្អែកទៅលើសៀវភៅប្រវត្តិសាស្ត្រ ឬក៏សៀវភៅឯកសារនានាដើម្បីធ្វើឲ្យលោកនឹកឃើញអំពីព្រឹត្តិការណ៍នោះដែរឬទេ?

**ឆ៖** សៀវភៅខ្ញុំនេះ គឺជាអនុសារណាផ្ទាល់របស់ខ្ញុំបាទ។ អត់មានពឹងផ្អែកទៅលើឯកសារដទៃទៀតទេបាទ។ ថ្វីបើខ្ញុំដកស្រង់ព្រឹត្តិការណ៍ពីក្រៅខ្លះដូចជា លោក ស៊ីវ ហេង ចុះចូលក្រោយហ្សីណែវអីអ៊ីចឹង។ បាទ អាហ្នឹងជាការចងចាំរបស់ខ្ញុំបាទ។ ប៉ុន្តែសឹងទាំងអស់ គឺជាបទពិសោធន៍ដែលខ្ញុំឆ្លងកាត់ក្នុងសម័យខ្មែរក្រហម។

[១១:៣៣:០២]

**សៈ** តើលោកធ្លាប់អានសៀវភៅប្រវត្តិសាស្ត្រ ឬក៏អត្ថបទប្រវត្តិសាស្ត្រ ដែលនិយាយពាក់ព័ន្ធទៅនឹងរបបខ្មែរក្រហមដែរឬទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់។ នៅឆ្នាំ១៩៨០ ក្នុងឆ្នាំ១៩៩០ ពេលបន្តបន្ទាប់មកខ្ញុំអានសៀវភៅ។

**សៈ** តើលោកចាំចំណងជើង ឬក៏ឈ្មោះសៀវភៅ ឬក៏អត្ថបទប្រវត្តិសាស្ត្រទាំងអស់ដែលលោកបានអាននោះដែរឬទេ?

**ឆ៖** ខ្ញុំចាំខ្លះដូចជា សៀវភៅ១សរសេរដោយស្រីបារាំងម្នាក់ដែលជាប្រពន្ធ ស៊ីគឿន ឈ្មោះជាបារាំងថា “អូ ដឺ ឡា ឌុយ សែល” បាទ។ ខ្ញុំអាននៅឆ្នាំ រវាងឆ្នាំ៨០ ហើយក្រោយមកទៀត ខ្ញុំអានសៀវភៅសម្តេច សីហនុ ឈ្មោះ *“ព្រីហ្សង់ញេ ដឺ ខ្មែរ រូស្ស៍”* ឬ “អ្នកទោសរបស់ខ្មែរក្រហម”។

**សៈ** តើលោកអាន -- ធ្លាប់អានសៀវភៅប្រវត្តិសាស្ត្របែបនេះជាភាសាអង់គ្លេសដែរឬទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ឆ្លើយបាទ!

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** សៀវភៅដែលខ្ញុំទទួល គឺជាសៀវភៅដែលសរសេរជាភាសាបារាំងបាទ។

**សៈ** ប្រហែលជាខ្ញុំសួរមិនច្បាស់។ ខ្ញុំចង់និយាយពីសៀវភៅប្រវត្តិសាស្ត្រ ឬក៏អត្ថបទប្រវត្តិសាស្ត្រ ដែលនិយាយនៅក្នុងរបបខ្មែរក្រហមហ្នឹង តើលោកធ្លាប់អានសៀវភៅ ឬក៏ឯកសារជាទូទៅនៅក្នុងរបប -- ទាក់ទងនឹងរបបខ្មែរក្រហមជាភាសាអង់គ្លេសដែរឬទេ?

**ឆ៖** ខ្ញុំគ្រាន់តែបានឃើញសៀវភៅប្រវត្តិសាស្ត្រទាំងនោះ ប៉ុន្តែខ្ញុំមិនបានអានចប់ចុងចប់ដើមទេ។

[១១:៣៥:៥៥]

**សៈ** នៅពេលព្រឹកនេះ នៅពេលដែលលោក អរុណ បានសាកសួរលោកនូវសំណួរមួយចំនួន

លោកបានបញ្ជាក់ថា “លោកមិនបានចាំថានៅពេលណាលោកបានឮឈ្មោះបងទី២ នោះទេ”។ តើវាអាចដែរឬទេ ដែលថាលោកឮឈ្មោះបងធំទី២ហ្នឹង គឺឈ្មោះបងធំទី២ហ្នឹងក្រោយឆ្នាំ៧៩ តើវាអាចទេ?

**ឆ៖** ខ្ញុំ ខ្ញុំមិនចាំបាទ ខ្ញុំមិនចាំ។

**ស៖** លោកជាវេជ្ជបណ្ឌិត គឺជាអ្នកបញ្ញាជន ហើយលោកតែងតែកត់ត្រា ព្រោះលោកឲ្យតម្លៃទៅលើការកត់ត្រាហ្នឹងថាជាសកម្មភាពរបស់បញ្ញាជន តើវាអាចដែរឬទេ ដែលថាលោកធ្វើកត់ត្រាដើម្បីបញ្ជាក់ ឬក៏ដើម្បីធានាថា ការចងចាំរបស់លោកហ្នឹង ខ្ញុំចង់ដឹងថាតើលោកប្រើការកត់ត្រាហ្នឹងដើម្បីជាការចងចាំ ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** បាទ សូមលោកតាំងសំណួរម្តងទៀតបាទ។

[១១:៣៧:៤១]

**ស៖** ខ្ញុំនឹងសួរលោកមួយសាទៀត។ លោកនិយាយពីមុននេះថា លោកផ្តល់តម្លៃទៅលើការកត់ត្រាហ្នឹងថាជារបស់បញ្ញាជន។ ដូច្នេះខ្ញុំគិតថា លោកតែងតែធ្វើការកត់ត្រា ដើម្បីធានាថា ការចងចាំរបស់លោកហ្នឹង គឺត្រឹមត្រូវ គឺធ្វើការកត់ត្រាដើម្បីធ្វើការបញ្ជាក់ថា ការចងចាំរបស់លោកហ្នឹងវាត្រឹមត្រូវ តើអ៊ីចឹងមែនដែរឬទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ ប៉ុន្តែចំពោះពាក្យ “បងធំទី២” នេះ គឺថាខ្ញុំមិនបានកត់ត្រាថា នៅពេលណាដែលខ្ញុំបានឮពាក្យនេះទេ។ ខ្ញុំមិនបានចាំទេ មិនបានកត់ត្រាទេ ហើយខ្ញុំក៏មិនដែលបានចាំដែរ។

**ស៖** ខ្ញុំយល់អំពីបញ្ហានេះ។ ខ្ញុំបានឮលោកនិយាយថា លោកសរសេរសៀវភៅដោយផ្អែកទៅលើការចងចាំរបស់លោកផ្ទាល់ គឺថាលោកមិនពឹងផ្អែកទៅលើប្រភពព័ត៌មានពីខាងក្រៅនោះឡើយនៅពេលដែលលោកសរសេរសៀវភៅនេះ។ តើអាចដែរឬទេ ថានៅពេលដែលលោកកំពុងសរសេរសៀវភៅហ្នឹង ការចងចាំរបស់លោកហ្នឹងគឺត្រូវជះឥទ្ធិពលដោយអត្ថបទនានា ដែលលោកបានអានអំពីរបបខ្មែរក្រហមចាប់ពីដើមឆ្នាំ៨០ រហូតមកដល់ក្រោយៗមកទៀតនោះ? ព្រោះលោកបានបញ្ជាក់រួចហើយអំពីសៀវភៅដែលថា ឈ្មោះថា “ឆ្ងាយហួសជើងមេឃ ឬក៏អ្នកទោសខ្មែរក្រហមជាដើមហ្នឹង” តើវាអាចដែរឬទេ ដែលថាការចងចាំរបស់លោកហ្នឹង គឺលោកទទួលឥទ្ធិពលផងដែរអំពីសៀវភៅនានាដែលលោកបានអាននៅពេលក្រោយមកនោះទេ?

[១១:៣៩:៤៧]

**ឆ៖** ពិតជាគ្មានឥត -- ពិតជាសៀវភៅទាំងអស់នោះ គ្មានឥទ្ធិពលលើសៀវភៅរបស់ខ្ញុំទេ។

**ស៖** សូមអរគុណលោក។ ខ្ញុំនឹងសួរសំណួរទាក់ទងបញ្ហានេះនៅពេលក្រោយបន្តិចទៀត ប៉ុន្តែឥឡូវនេះខ្ញុំសូមបន្តទៅចំណុចមួយផ្សេងទៀត។ ចំណុចនេះគឺពាក់ព័ន្ធទៅនឹងបទពិសោធន៍របស់លោកទាក់ទងទៅនឹងការជម្លៀសនៅបាត់ដំបង។ ខ្ញុំសូមសួរលោកបន្តិច គឺមុនថ្ងៃ១៧ មេសា ៧៥នោះ នៅពេលនោះលោកធ្វើការនៅពេទ្យយោធា តើលោកធ្លាប់ព្យាបាលទាហានខ្មែរក្រហមដែលគេយក មកបញ្ជូនមកមន្ទីរពេទ្យដើម្បីទទួលការព្យាបាលដែរឬទេ? គឺខ្ញុំចង់និយាយពីទាហានខ្មែរក្រហមដែលត្រូវរបួសក្នុងពេលប្រយុទ្ធជាមួយទាហាន លន់ នល់ តើលោកធ្លាប់ព្យាបាលទាហានខ្មែរក្រហមដែរឬទេ?

**ឆ៖** នៅរយៈពេលដែលខ្ញុំធ្វើការនៅមន្ទីរពេទ្យយោធា មន្ទីរពេទ្យខ្មែរក្រហម គឺថាមិនដែលបានទទួលអ្នករបួសខ្មែរក្រហមនៅក្នុងមន្ទីរពេទ្យទេបាទ។

[១១:៤១:៤៦]

**ស៖** តើលោកធ្លាប់ឮគេនិយាយថា ទាហានខ្មែរក្រហមភាគច្រើនត្រូវបានគេសម្លាប់ក្រោយពេលត្រូវបានទាហាន លន់ នល់ ចាប់ខ្លួន ទោះបីថាទាហានខ្មែរក្រហមទាំងនោះត្រូវរបួសឬក៏អត់? តើលោកធ្លាប់ឮគេនិយាយបែបនេះដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលឮទេបាទ។

**ស៖** ឥឡូវនេះយើងបន្តទៅលើចំណុចមួយទៀត គឺបទពិសោធន៍របស់លោកនៅបាត់ដំបង គឺនៅពេលដែលមានការបញ្ជូនទាហាន លន់ នល់ តាមឡានក្រុង។ លោកបានបញ្ជាក់ថា -- ឥឡូវនេះ ខ្ញុំនិយាយពីថ្ងៃ១៩ មេសា ហើយខ្ញុំយោងឯកសារមួយដែលមានលេខ 00369682, ហើយភាសាខ្មែរគឺមានឯកសារលេខ 00678758 នេះគឺជាឯកសារដែលខ្ញុំដកស្រង់ចេញពីសៀវភៅរបស់លោក។

ខ្ញុំសូមអាន "នៅថ្ងៃដែលមានបញ្ជាពីថ្នាក់លើឲ្យគ្រប់ទាហាន លន់ នល់ ចាប់ពីអ្នកដែលមានឋានៈអនុសេនីយ៍ត្រីឡើងទៅត្រូវមកប្រមូលផ្តុំនៅសាលាចិនកណ្តាលក្រុង។ ចំណែកទាហានមានឋានៈក្រោមអនុសេនីយ៍ត្រីបានមកប្រមូលផ្តុំនៅសាលាបឋមសិក្សាសោហ៊ី ជិតស្ពានថ្មថ្មី។ ទាហានទាំងអស់សុទ្ធតែមកដៃទទេ គ្មានអាវុធជាប់ខ្លួន ហើយស្នាក់នៅទាំងថ្ងៃ ទាំងយប់នៅកន្លែងប្រមូលផ្តុំ"។ សំណួរទី១របស់ខ្ញុំ តើលោកខ្លួនលោកផ្ទាល់បានឃើញដោយផ្ទាល់អំពីព្រឹត្តិការណ៍ដែលកើតឡើងនេះដោយផ្ទាល់ខ្លួនលោកដែរឬទេ?

**ឆ៖** ចំពោះការប្រមូលផ្តុំនាយទាហាន និងទាហាន នៅសាលារៀននោះ ខ្ញុំបាននិយាយពីម្សិលមិញហើយបាទ។ ខ្ញុំបានឃើញផ្ទាល់ មិនមែនគ្រាន់តែឃើញផ្ទាល់ ខ្ញុំបានទៅសួរសុខទុក្ខនាយទាហាន

នៅ -- ដែលប្រមូលផ្តុំនៅសាលាចិនកណ្តាលទីក្រុងផងបាទ។

[១១:៤៤:៤០]

**សៈ** នៅក្នុងឃ្លានេះ លោកបានបញ្ជាក់ថា គឺធ្វើឡើងដោយទទួលបញ្ជាពីថ្នាក់លើ។ ហើយខ្ញុំគិតថា លោកបានផ្តល់សក្ខីកម្មរួចហើយអំពីបញ្ហានេះកាលពីម្សិលមិញ។ ប៉ុន្តែខ្ញុំគ្រាន់តែចង់លើកយកបញ្ហានេះមកដើម្បីបញ្ជាក់ឲ្យបានច្បាស់ ខ្ញុំចង់ដឹងថាតើលោកដឹងអំពីហេតុការណ៍នេះដោយរបៀបណាថាជាបទបញ្ជាពីថ្នាក់លើ តើលោកដឹងដោយរបៀបណាដែរ?

**ឆៈ** នៅក្នុងរបបខ្មែរក្រហម អ្វីៗសុទ្ធតែជាការសម្ងាត់ទាំងអស់ គេនិយាយតែ "ថ្នាក់លើៗ" នេះឯងបាទ។ នេះជាពាក្យទូទៅ "ថ្នាក់លើៗ"។ ខ្ញុំមិនអាចកំណត់ថាអ្នកណាជាអ្នក -- ជាថ្នាក់លើ ខ្ញុំមិនអាចកំណត់បានទេ។ ប៉ុន្តែគ្រាន់តែឮ ហើយខ្លាច។

[១១:៤៦:១៣]

**សៈ** លោកបានបញ្ជាក់ថា "ការសម្ងាត់ គឺជាការសំខាន់បំផុត"។ តើលោកដឹងដែរឬទេថានៅកម្រិតណា ដែលបញ្ជាឲ្យមានការប្រមូលទាហានបែបនេះ? តើលោកដឹងថានៅកម្រិតណាដែរ ដែលគេបញ្ជាមកនេះ?

**ឆៈ** ខ្ញុំសូមរៀបរាប់បន្តិច គឺថានៅថ្ងៃ១៧ គ្មាន -- មានតែកងទ័ពបន្តិចបន្តួចទេ កងទ័ពខ្មែរក្រហមបន្តិចបន្តួចទេចូលមកក្រុងបាត់ដំបង។ ហើយគេយប់គេបញ្ចេញឫក បញ្ចេញៗភាពគំរាមកំហែងរបស់គេ ហើយបើកម៉ូតូស្រែកហ៊ោកញ្ជៀវទាំងយប់បាទ ដល់ព្រឹកឡើងក៏មិនទាន់ឃើញទាហានខ្មែរក្រហមដែរ។ ពេលនោះឯងបានមានប្រតិភូខេត្តមួយទៅកន្លែងមួយហៅថា "អន្លង់វិល" គឺប្រហែលប្រាំគីឡូម៉ែត្រពីសាលាខេត្ត ទៅទទួលថ្នាក់ដឹកនាំខ្មែរក្រហមបាទ។ ហើយដឹងក្នុងចំណោមថ្នាក់ដឹកនាំខ្មែរក្រហមនោះគឺថាអ្នកដែលចេញមុខ ចេញមាត់ឲ្យប្រជារាស្ត្រឃើញ គឺមានតែម្នាក់គត់ គឺខ្ញុំ -- គឺជា -- គឺខ្ញុំនិយាយម្សិលមិញគឺលោក ខែក ប៉ែន ដែលជាអតីតសាស្ត្រាចារ្យធ្លាប់បង្រៀននៅមហាវិទ្យាល័យនៅតាមខេត្តបាទ។ ហើយបន្ទាប់មកបានចេញបទបញ្ជាផ្សេងៗហ្នឹងបាទ ដែលមិនមែនជាលាយលក្ខណ៍អក្សរទេ គ្រាន់តែឮថា "ថ្នាក់លើៗ" អ៊ីចឹងបាទ។ ហើយក៏យើងមិនដឹងថាកម្មាភិបាលខ្មែរក្រហមអ្នកដឹកនាំខ្មែរក្រហមនោះ គេស្នាក់នៅកន្លែងណា គេដេកនៅកន្លែងណា គេធ្វើនៅកន្លែងណាក៏គេគ្មានអ្នកណាដឹងដែរ។

[១១:៤៨:៤១]

**ស៖** តើលោកនៅទីណាដែរនៅក្នុងការប្រជុំ ដែលមាន -- នៅការប្រមូលផ្ដុំដែលមានចម្ងាយរាប់សិបគីឡូពីទីរួមខេត្តបាត់ដំបងនោះ?

**ឆ៖** មិនមែនប្រជុំនៅបាត់ដំបង គឺថា ប្រតិភូខេត្តមួយទៅទទួលពួកខ្មែរក្រហម អញ្ជើញគេមកសាលាខេត្តៗ ប្រជុំបាទ។

**ស៖** តើលោកចូលរួមផ្ទាល់នៅក្នុងការប្រជុំនោះដែរឬទេ?

**ឆ៖** អត់ទេ ប៉ុន្តែប្រធានខ្ញុំគឺស័ក្តិ៥ ប្រធានមន្ទីរពេទ្យគាត់ចូលរួមបាទ។

**ស៖** តើលោកស្ដាប់ឮដោយផ្ទាល់ ឬក៏ឃើញដោយផ្ទាល់ អំពីការបញ្ជាទាក់ទងទៅនឹងហេតុ-ការណ៍ពាក់ព័ន្ធទៅនឹងទាហាន លន់ នល់ នោះដែរឬទេ? ឬមួយលោកគ្រាន់តែនិយាយអំពីអ្វីដែលលោកបានឮពីអ្នកដទៃតែប៉ុណ្ណោះទេ?

**ឆ៖** ខ្ញុំសូមលោកមានប្រសាសន៍ឲ្យច្បាស់ជាងហ្នឹងទៀត។

**ស៖** មុននេះលោកបាននិយាយអំពីការបញ្ជា ដែលបញ្ជាពីថ្នាក់លើមកក្រោមពាក់ព័ន្ធទៅនឹងហេតុការណ៍ ទាក់ទងទៅហ្នឹងទាហាន លន់ នល់។ សំណួរដែលខ្ញុំចង់សួរលោកគឺថា តើលោកបានឮទាហានខ្មែរក្រហម និយាយអំពីការចេញបញ្ជាដោយផ្ទាល់ ឬក៏ចេញជាលាយលក្ខណ៍អក្សរ ឬមួយក៏លោកពឹងផ្អែកទៅលើអ្វីដែលលោកបានស្ដាប់ឮពីអ្នកដទៃតែប៉ុណ្ណោះទេ? តើលោកឮដោយផ្ទាល់ ឬក៏លោកស្ដាប់ឮគេទេ?

**ឆ៖** បាទ នៅក្នុងរបបខ្មែរក្រហមគេមិនប្រើក្រដាសស្នាមទេ គេប្រើតែមាត់ ប៉ុន្តែមាត់ហ្នឹងគឺថា មានប្រសិទ្ធភាពរបស់គេបាទ។ ហើយទាហានដែលទទួលការប្រមូលផ្ដុំនោះ គឺខ្ញុំមិនបានឮពាក្យថាឲ្យគេប្រមូលផ្ដុំទេ ប៉ុន្តែខ្ញុំឃើញទាហាន -- នាយទាហានមកប្រមូលផ្ដុំនៅសាលាចិនកណ្ដាលទីក្រុង។ ហើយចំពោះកូន -- ចាប់ពីក្រោមស័ក្តិ១ ទៅប្រមូលផ្ដុំនៅសាលាមួយទៀតបាទ ឃើញអ៊ីចឹងបាទ។ ឲ្យថាខ្ញុំបានឮ ហើយឃើញក្រដាសស្នាមអី គឺគ្មានទេបាទ។

[១១:៥២:០៦]

**ស៖** ដូច្នេះ តើជាការត្រឹមត្រូវដែរឬទេ ដែលខ្ញុំនិយាយថា ដោយសារលោក -- ដោយខ្ញុំនិយាយថា លោកមិនបានឮដោយផ្ទាល់ ហើយក៏មិនបានឃើញការបញ្ជាហ្នឹង ជាលាយលក្ខណ៍អក្សរនោះដែរ។ ដូច្នេះ គឺលោកសន្និដ្ឋាន ឬក៏លោកស្មានថា វាមានបទបញ្ជាបែបនោះ តើវាជាការត្រឹមត្រូវដែរឬទេ ដែលខ្ញុំនិយាយបែបនោះ?

**ឆ៖** ខ្ញុំចង់និយាយពីការអនុវត្តវិញ គឺថាខ្ញុំមិនបានឃើញ មិនបាន--

**ស៖** លោកសាក្សី ខ្ញុំសូមអភ័យទោស ដែលខ្ញុំត្រូវកាត់លោក។ ខ្ញុំឃើញថាលោកកំពុងតែពិនិត្យទៅអ្វីដែលលោកបានដឹង។ ប៉ុន្តែអ្វីដែលខ្ញុំចង់សួរគឺថា តើអ្វីដែលលោកដឹងពិតប្រាកដនោះយ៉ាងម៉េចដែរ។ លោកបានបញ្ជាក់ថា លោកឃើញគេប្រមូលផ្តុំទាហានទាំងនោះ -- ខ្ញុំសុំសួរលោក ថាតើវាជាការត្រឹមត្រូវដែរឬទេ ផ្អែកទៅលើអ្វីដែលលោកបានឃើញនៅក្នុងអគារនោះ លោកធ្វើការសន្និដ្ឋានថា វាជាបញ្ជាផ្ទាល់ វាមានការបញ្ជាពីខាងលើបែបនេះ តើវាជាការត្រឹមត្រូវដែរឬទេ ដែលខ្ញុំនិយាយបែបនេះ?

**ឆ៖** បាទ ទាហានដែលប្រមូលផ្តុំនៅពីរកន្លែងនោះ គឺគេមកតាមបញ្ជាពីថ្នាក់លើ ប៉ុន្តែខ្ញុំមិនអាចនិយាយក្រៅពីហ្នឹងទេ។

[១១:៥៤:០៧]

**ស៖** ខ្ញុំនឹងបន្តទៅមុខទៀត។ លោកបានបញ្ជាក់ថា ទាហានទាំងអស់នេះត្រូវបានគេយកចេញតាមឡានចំនួនប្រាំ តើលោកឃើញឡានទាំងប្រាំនោះ ដោយផ្ទាល់នៅថ្ងៃនោះ ឬមួយក៏យ៉ាងម៉េចដែរ?

**ឆ៖** មិនបានឃើញផ្ទាល់ឡានទាំងអស់នោះទេ ប៉ុន្តែអ្នកបើកបររថយន្តប្រាប់ខ្ញុំពេលក្រោយបាទ។ ថាមិនមែនគ្រាន់តែដឹកទាហានទេ ដឹកមកភ្នំពេញ ដឹកមកតាមផ្លូវភ្នំពេញនេះ គឺដឹកនាយទាហានអ្នកមុខអ្នកការ គឺអ្នកមានមុខមានមាត់នៅបាត់ដំបង ហើយនិងដឹកប្រធានអង្គភាពរដ្ឋ។ ហើយមួយទៀតនៅព្រឹកនោះឯងគឺសាលាចិន សាលាដែលប្រមូល -- កន្លែងប្រមូលទាហានផ្តុំនោះគឺទទេ គឺអស់ គឺថាបានចេញទៅអស់ហើយ។

**ស៖** ដូច្នេះ គឺថាគេប្រាប់លោកថា មានឡានប្រាំ ដែលដឹកមន្ត្រីទាំងអស់នេះចេញ។ តើអ៊ីចឹងមែនដែរឬទេ?

**ឆ៖** បាទ មែនបាទ។

**ស៖** ឥឡូវនេះ ខ្ញុំលើកសំណួរទូទៅមួយ ដែលពាក់ព័ន្ធទៅនឹងប្រធានបទនេះ។ នៅក្នុងរបបខ្មែរក្រហមតើលោកធ្លាប់ឃើញដោយផ្ទាល់នូវការសម្លាប់មនុស្សដែរឬទេ? ខ្ញុំចង់និយាយថា លោកធ្លាប់ឃើញការកាប់សម្លាប់មនុស្សដោយផ្ទាល់ដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលបានឃើញ ការសម្លាប់ផ្ទាល់មនុស្សទេបាទ។

**ស៖** ដូច្នេះ ខ្ញុំមិនចង់សួរឲ្យវាជាក់លាក់នោះទេ ប៉ុន្តែដោយសារលោកមិនដែលឃើញការសម្លាប់ទាហាន លន់ នល់ ដូច្នេះ លោកក៏មិនដែលឃើញការសម្លាប់ទាហាន លន់ នល់ នេះដោយផ្ទាល់ដែរ

តើអ៊ីចឹងដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលឃើញទេបាទ។

**ស៖** ឥឡូវនេះ ខ្ញុំនឹងបន្តទៅមុខទៀត។ ទៅប្រធានបទដែលពាក់ព័ន្ធគ្នាមួយទៀត ដែលលោកបានបញ្ជាក់នៅថ្ងៃនេះ អំពីទីតាំងជាក់លាក់មួយនៅក្នុងទីរួមខេត្តបាត់ដំបង ដែលត្រូវបានគេរៀបចំសម្រាប់ជនជាតិវៀតណាមនៅក្នុងរបប លន់ នល់។ តើលោកដឹងដែរឬទេថា ហេតុអ្វីបានជារដ្ឋបាល លន់ នល់ បង្កើតជាជំរំពិសេស ជំរំបែងចែកដាច់ដោយឡែកសម្រាប់ជនជាតិវៀតណាមដែរឬទេ?

**ឆ៖** ខ្ញុំដឹងថា លោក លន់ នល់ គាត់មិនទុកចិត្តវៀតណាម ដោយខ្លាចវៀតណាមថា យកការណ៍ឲ្យពួកវៀតកុង។ ហេតុដូច្នេះហើយបានជាគាត់ប្រមូលផ្ដុំជនជាតិវៀតណាម ប្រមូលជនជាតិវៀតណាមនៅៗជំរំបាទ។ ប៉ុន្តែប្រមូលផ្ដុំនេះតែពេលយប់ទេបាទ ពេលយប់ទេ ពេលថ្ងៃគឺ គាត់រកស៊ីធម្មតា ពេលយប់គាត់មកដេកនៅកន្លែងជំរំប្រមូលផ្ដុំ។

[១១:៥៨:៥៧]

**ស៖** តើលោកធ្លាប់ឮ ឬក៏ធ្លាប់ដឹងថាតើជនជាតិវៀតណាមហ្នឹង គេប្រមូលផ្ដុំគឺការប្រមូលផ្ដុំជនជាតិវៀតណាមនោះ តើលោកធ្លាប់ឮគេនិយាយ ឬក៏ឃើញយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំឃើញផ្ទាល់។ ធ្លាប់ដើរទៅមើលទៀតបាទ ពីព្រោះមិននៅឆ្ងាយពីមន្ទីរពេទ្យប៉ុន្មានទេបាទ។

**ស៖** តើលោកអាចរៀបរាប់ពីស្ថានភាព របស់ជនជាតិវៀតណាមនោះបានដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមធ្វើការជំទាស់ ទាក់ទងទៅនឹងអ្វីដែលបានលើកឡើង។ ដូចដែលសហភាគាខ្ញុំបានជំទាស់ជាមួយខ្ញុំកាលពីម្សិលមិញដែរ។ ឥឡូវនេះ គឺនិយាយអំពីវិសាលភាពដែលគាត់និយាយអំពីគោលនយោបាយរបស់រដ្ឋាភិបាល លន់ នល់ ទៅវិញ គឺមុនខែមេសា ឆ្នាំ៧៥ ទៅវិញ។ ដូច្នេះ តាមការយល់ឃើញរបស់ខ្ញុំ គឺថាវិសាលភាពហ្នឹងគឺវាខុសពីវិសាលភាពរបស់យើង ហើយវាជាសំណួរទាក់ទងទៅនឹងបរិបទប៉ុណ្ណោះ។ ដូច្នេះ គួរតែលើកយកនូវសំណួរទាក់ទងនឹងបរិបទ ហើយកុំឲ្យលើកខុសពីវិសាលភាពបែបនេះតទៅទៀត។

[១២:០០:២៨]

**លោក ហ្សាស្តើ ប៉ោះ**

ខ្ញុំគិតថា យើងគួរតែមានសំណួរជាក់លាក់ទៅលើបញ្ហាជាក់លាក់ ឬក៏ព្រឹត្តិការណ៍ជាក់លាក់ គឺថា ខ្ញុំនិយាយអំពីជំរំដែលប្រមូលផ្តុំ ដែលបង្កើតឡើងដោយ លន់ នល់ ដើម្បីប្រមូលផ្តុំជនជាតិវៀតណាម។ ហេតុអ្វីបានវាជាបញ្ហាពាក់ព័ន្ធ។ ការពិតទៅ គឺវាពាក់ព័ន្ធទាក់ទងទៅនឹងបរិបទ ពីព្រោះថា វាកើតឡើងនៅមុនពេលដែលខ្មែរក្រហមកគ្រប់គ្រង។ ដូច្នេះ ហើយគឺវាមានបញ្ហាពាក់ព័ន្ធទៅនឹងជនជាតិវៀតណាម ដែលវាចាំបាច់ ហើយដោយជាកត្តាពាក់ព័ន្ធដោយផ្ទាល់ក្នុងការផ្តល់នូវប្រវត្តិ ក៏ដូចជាភាគរយ ឬក៏មធ្យមភាគនៃអ្វីដែលបានកើតឡើង។ ប្រសិនបើយើងមើលទៅលើសំណុំរឿង ថាឌីកអាកាយេស៊្វ បញ្ហានេះត្រូវបានលើកឡើងមកផងដែរ។ ដោយសារតែខ្ញុំមិនមានពេលវេលាច្រើន ហើយដោយសារតែខ្ញុំមិនអាចសួរអំពីសំណួរទាំងអស់នេះឲ្យបានលម្អិត។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតបន្តទៅមុខទៀត។

**ប្រធានអង្គជំនុំ៖**

មេធាវីឥឡូវនេះដល់ពេលសមល្មមសម្រាកដើម្បីពិសាថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាកពិសាអាហារថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវី!

**លោក ហ្សាស្តើ ប៉ោះ**

លោក នួន ជា គាត់ទទួលរងនូវការឈឺខ្នង ឈឺចង្កេះ មិនអាចផ្តង់អារម្មណ៍បាន។ ដូច្នេះគាត់ស្នើសុំអនុញ្ញាតតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោម ហើយយើងទើបនឹងដាក់ជូននូវលិខិតលះបង់សិទ្ធិជូនទៅអង្គជំនុំជម្រះ។ សូមអរគុណ។

[១២:០២:៥០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់លោក នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវី

ការពារក្តីរបស់គាត់ ស្នើសុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ ដោយមូលហេតុបញ្ហាសុខភាព មិនអាចអង្គុយយូរតាមដានក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការបាន។ សំណើសុំរបស់លោក នួន ជា ធ្វើឡើងមានមូលហេតុសមស្រប អង្គជំនុំជម្រះយល់ព្រមនិងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយនៅខាងក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះ។

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តី នួន ជា ប្រគល់ជូនមកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមដោយផ្ទាល់ នៅក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃយ៉ាងជាក់ច្បាស់របស់លោក នួន ជា។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលនៃដំណើរការសវនាការនៅរសៀលថ្ងៃនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ហើយនៅរសៀលនេះទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញឲ្យបានមុនម៉ោងមួយសាមសិបនាទី។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៤ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:១០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក ហ្សាស្តេ ប៉ោះ**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រីទាំងអស់គ្នា ទាំងនៅក្នុង និងខាងក្រៅសាលសវនាការ។ ឥឡូវនេះ ខ្ញុំចង់ជម្រាប អំពីផែនការខាងមេធាវីការពារក្តីរបស់យើងខ្ញុំ។ ខ្ញុំបានពិភាក្សាជាមួយសហការីរបស់ខ្ញុំ ហើយខ្ញុំគ្រោងនឹងបន្តសួរសំណួររហូតដល់ម៉ោងបី ឬក៏អាចដល់បីដប់ប្រាំនាទី ហើយបន្ទាប់មក ខ្ញុំនឹងប្រគល់វេទិកាជូនទៅសហការីរបស់ខ្ញុំ ហើយយើងមាន -- ហើយយើងស្នើសុំថា មេធាវីខាងលោក ខៀវ សំផន នឹងបន្តពីខ្ញុំ ហើយចុងក្រោយគឺខាង អៀង សារី ដែលយើងបានស្នើសុំទៅអង្គជំនុំជម្រះ ហើយអង្គជំនុំជម្រះបានយល់ព្រមរួចទៅហើយ។ នេះគឺជា គម្រោង ឬក៏ជាផែនការរបស់យើង ដែលយើងនឹងគ្រោងធ្វើនៅរសៀលនេះ។ ខ្ញុំសូមបន្តជាមួយសំណួររបស់ខ្ញុំទៅលើសាក្សីបន្តទៅទៀត។

[១៣:៣៤:៤៦]

**សួរដោយលោក ហ្សាស្តេ ប៉ោះ**

**ស៖** លោក ហ៊ុន ឈុនលី មុននឹងខ្ញុំចាប់ផ្តើមសួរលោក។ ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ ជម្រាបជូនលោកថា សំណួររបស់ខ្ញុំពេលខ្លះអាចស្តាប់ទៅពិបាកឆ្លើយ ប៉ុន្តែអ្វីដែលខ្ញុំព្យាយាមចង់រកឲ្យឃើញគឺចង់ឲ្យដឹងអំពីប្រភពនៃការដឹងរបស់លោក ថាតើលោកដឹងដោយរបៀបណា លោកដឹងពីវិធីសាស្ត្របែបណា? ដូច្នេះ ខ្ញុំមិនមែនចង់សួរ ដើម្បីបង្ហាញថា ខ្ញុំមិនជឿលោកនោះទេ ខ្ញុំគ្រាន់តែចង់ដឹងថាតើលោកផ្អែកទៅលើមូលដ្ឋានអ្វី ដែលលោកបានទទួលព័ត៌មានទាំងអស់នេះ។ យើងបាននិយាយអំពីការជម្លៀសពីទីក្រុងបាត់ដំបង ហើយយើងក៏បាននិយាយអំពីទាហាន លន់ នល់ ហើយលោកក៏បានផ្តល់សក្ខីកម្មទាក់ទងទៅនឹងមន្ត្រី ឬក៏បុគ្គលិកពេទ្យនៅមន្ទីរពេទ្យយោធា។ លោកបានបញ្ជាក់ថា តាមការដឹងរបស់លោក គឺមានគោលនយោបាយរបស់ខ្មែរក្រហម ក្នុងការសម្លាប់បុគ្គលិកពេទ្យយោធា នៅឋានៈ នៅតាមឋានន្តរស័ក្តិមួយចំនួន។ ដូច្នេះ ខ្ញុំចង់បញ្ជាក់ថាតើអានេះ ថាតើអ្វីដែលខ្ញុំនិយាយហ្នឹងគឺជាអ្វីដែលលោកបានផ្តល់សក្ខីកម្មពីមុន ដែលថាគេមានផែនការនយោបាយមាននយោបាយ ដើម្បីសម្លាប់បុគ្គលិកពេទ្យនៅមន្ទីរពេទ្យយោធាដែរឬទេ?

[១៣:៣៦:៤៧]

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** នៅក្រុងបាត់ដំបង បន្ទាប់ពីខ្មែរក្រហមចូលក្រុងបាត់ដំបង គឺខ្មែរក្រហមបានសម្លាប់មន្ត្រីយោធា មន្ត្រីទាហានយោធា១៣នាក់មុនគេបាទ។

**ស៖** សូមអរគុណលោក។ តាមពិតទៅមន្ត្រីទាហានខ្មែរក្រហម ឬក៏មន្ត្រីណាមួយ ថាតើជាគោលនយោបាយរបស់ខ្មែរក្រហម ដែលថាត្រូវសម្លាប់បុគ្គលិកពេទ្យយោធា ឬមួយក៏យ៉ាងដូចម្តេចដែរ?

**ឆ៖** តាមការឆ្លងបទពិសោធន៍របស់ខ្ញុំ ខ្មែរក្រហមមិនមែន -- មិនគ្រាន់តែសម្លាប់មន្ត្រីពេទ្យយោធាទេ មន្ត្រីពេទ្យស៊ីវិល ក៏វាសម្លាប់ដែរ គ្រាន់តែលើកក្រោយ ហើយជាបន្តបន្ទាប់។

**ស៖** ខ្ញុំបានឮលោកនិយាយថា ដំបូងគេសម្លាប់ពេទ្យយោធា បន្ទាប់មកសម្លាប់ពេទ្យស៊ីវិល ប៉ុន្តែសំណួររបស់ខ្ញុំគឺផ្សេងពីនេះទេ។ ខ្ញុំចង់ដឹងថា អ្នកណាប្រាប់លោក ឬក៏លោកឮពីអ្នកណា ដែលថាវាជាគោលនយោបាយរបស់ខ្មែរក្រហម ក្នុងការសម្លាប់បុគ្គលិកពេទ្យយោធា។ តើមានអ្នកណាម្នាក់ដែលធ្លាប់ប្រាប់លោកអំពីគោលនយោបាយនេះដែរឬទេ?

**ឆ៖** គោលនយោបាយនេះគឺមិនបាននិយាយលើកឡើងទេ ប៉ុន្តែការអនុវត្តជាក់ស្តែងគឺគេធ្វើយ៉ាងដូច្នេះ។

[១៣:៣៩:០៥]

**ស៖** ដូច្នេះ តើខ្ញុំអាចនិយាយបានដែរឬទេ ថាជាការត្រឹមត្រូវដែរឬទេ ផ្អែកទៅលើអ្វីដែលលោកបានឃើញនៅជុំវិញខ្លួនលោក លោកក៏ធ្វើការស្មាន ឬក៏សន្និដ្ឋានថា វាជាគោលនយោបាយ។ តើខ្ញុំនិយាយបែបនេះត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំនិយាយ ខ្ញុំអាចនិយាយថា អាហ្នឹងជាគោលនយោបាយរបស់ខ្មែរក្រហម ក្នុងការសម្លាប់មន្ត្រីយោធា មន្ត្រីពេទ្យយោធា មន្ត្រីពេទ្យស៊ីវិល ហើយនិងអ្នកចេះដឹង និងបញ្ញវន្ត ដែលអ្នកទាំងអស់គ្នាបានឆ្លងកាត់ ឬបានដឹង។

**ស៖** តាមការបកប្រែគឺថា លោកនិយាយថា ការសម្លាប់នេះគឺជាផ្នែកមួយ នៃគោលនយោបាយរបស់ខ្មែរក្រហម។ សំណួររបស់ខ្ញុំគឺនៅដដែល តើជាការត្រឹមត្រូវដែរឬទេ ដែលនិយាយថាលោកធ្វើការស្មានថាវាជាគោលនយោបាយ ហើយលោកស្មានហ្នឹងដោយផ្អែកទៅលើអ្វីដែលលោកបានឃើញកើតឡើងនៅចំពោះមុខ ឬក៏កើតឡើងនៅជុំវិញខ្លួនលោក។ តើខ្ញុំនិយាយបែបនេះត្រឹមត្រូវដែរឬទេ?

**ផ៖** លោកនិយាយបែបនេះខុស ពីព្រោះខ្ញុំនិយាយផ្អែកទៅលើការជាក់ស្ដែង។ អត់មានការស្មាន ការ -- អត់លើការស្មានទេបាទ។ ផ្អែកលើការជាក់ស្ដែងឃើញដឹងថាវាសម្លាប់ដូច្នេះឯងបាទ។ ទូទៅ ទូទាំងកម្ពុជា។

[១៣:៤០:៥៨]

**សៈ** ខ្ញុំទុកចំណុចនេះមួយអន្លើសិន ដោយសារតែមានពេលវេលាកំណត់។ លោកបានបញ្ជាក់នេះគឺជាអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា គឺថានៅទូទាំងប្រទេសកម្ពុជានៅពេលនោះ។ ខ្ញុំចង់ធ្វើការដកស្រង់ នូវសម្រង់មួយនៃសៀវភៅរបស់លោក ដែលមានភាសាអង់គ្លេសមានលេខ 003696 75, ភាសាខ្មែរគឺមានលេខ 00678751។ ហើយនេះគឺជាការដកស្រង់ពីសៀវភៅរបស់លោក ដែលលោកសរសេរថា ខ្ញុំសូមដកស្រង់ "សៀវភៅខ្ញុំគ្របដណ្ដប់តែក្រុងបាត់ដំបង និងស្រុកពីរក្នុងខេត្តបាត់ដំបង។ នៅក្នុងក្រុងបាត់ដំបង ខ្ញុំបានធ្វើការនៅមន្ទីរពេទ្យខ្មែរក្រហមថ្នាក់តំបន់២ គឺមន្ទីរពេទ្យយោធា និងមន្ទីរពេទ្យស៊ីវិល។ ខ្ញុំមិនដឹងថា នៅខេត្តឯទៀត ពួកខ្មែរក្រហមហៅពេទ្យសង្គមចាស់ទៅធ្វើការនៅមន្ទីរពេទ្យរបស់វា រួចសម្លាប់ពេទ្យទាំងនោះ ឬយ៉ាងណាទេ"។ ខ្ញុំសូមបញ្ចប់ការដកស្រង់របស់ខ្ញុំ។ នៅត្រង់ចំណុចនេះ លោកនិយាយថា លោកមិនដឹងថានៅខេត្តឯទៀត ពួកខ្មែរក្រហមហៅពេទ្យសង្គមចាស់ទៅធ្វើការនៅមន្ទីរពេទ្យរបស់វា រួចសម្លាប់ពេទ្យទាំងនោះ ឬយ៉ាងណាទេ។ តើត្រឹមត្រូវដែរឬទេ ដែលខ្ញុំនិយាយថា លោកមិនដឹង ឬក៏មិនអាចនឹងបញ្ជាក់អំពីគោលនយោបាយរបស់ខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា គឺទូទាំងប្រទេសកម្ពុជាជារួមនៅពេលនេះ? តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

[១៣:៤២:៥៧]

**ផ៖** ខ្ញុំចង់និយាយថា នៅខេត្តបាត់ដំបង ខ្មែរក្រហមបានហៅបុគ្គលិកពេទ្យទៅធ្វើការរួចហើយសម្លាប់។ ចំពោះខេត្តដទៃទៀត ខ្ញុំមិនដឹងថាតើគេសម្លាប់តែម្ដង ឬមួយហៅមកធ្វើការសិន។ ខ្ញុំមិនទាន់ដឹង ប៉ុន្តែការសម្លាប់ គឺៗសម្លាប់។

**សៈ** ខ្ញុំមិននិយាយអំពីការសម្លាប់នៅក្នុងខេត្តបាត់ដំបងពេលនោះទេ គឺខ្ញុំនិយាយអំពីអ្វីមួយផ្សេងពីនេះ។ ប៉ុន្មាននាទីមុន លោកបានបញ្ជាក់ថា "ទាំងអស់នេះគឺជាផ្នែកនៃគោលនយោបាយមួយ ដែលគេអនុវត្តន៍នៅក្នុងប្រទេសកម្ពុជា ទូទាំងប្រទេសតែម្ដង"។ ប៉ុន្តែឥឡូវនេះ ខ្ញុំអាននូវអត្ថបទក្នុងសៀវភៅរបស់លោក ដែលលោកខ្លួនឯងសរសេរថា លោកមិនដឹងថានៅខេត្តដទៃទៀតហ្នឹង ខ្មែរក្រហមបានហៅពេទ្យ បុគ្គលិកពេទ្យចាស់ ពេទ្យសង្គមចាស់ទៅធ្វើការ ឬសម្លាប់ ឬយ៉ាងណានោះទេ។ តើត្រឹមត្រូវដែរ

ឬទេលោកសាក្សី ដែលខ្ញុំនិយាយថា លោកមិនអាចផ្តល់មតិយោបល់ ទាក់ទងទៅនឹងគោល នយោបាយ ដែលធ្វើនៅក្នុងប្រទេសកម្ពុជានៅពេលនេះ ព្រោះថាលោកមិនមានបទពិសោធន៍ លោកមិន ដែលឃើញ ព្រោះថាលោកនៅតែក្នុងខេត្តបាត់ដំបង គឺថានៅតែក្រុងបាត់ដំបង និងស្រុកពីរក្នុងខេត្តបាត់ដំបងនោះ។ តើខ្ញុំនិយាយបែបនេះត្រឹមត្រូវដែរឬទេ?

[១៣:៤៤:៥១]

**ឆ៖** បាទ លោក -- ខ្ញុំ -- លោកនិយាយត្រឹមត្រូវហើយ គឺថាដូចខ្ញុំសរសេរក្នុងសៀវភៅអ៊ីចឹង គឺថាខ្ញុំដឹងថាចំពោះខេត្តបាត់ដំបង គេហៅពេទ្យមកៗបម្រើការរួចទៅគេស្លាប់ ហើយខ្ញុំមិនដឹងថា តើនៅខេត្តដទៃទៀត គេធ្វើដូចនៅខេត្តបាត់ដំបងដែរ ឬយ៉ាងណា ក៏ខ្ញុំមិនដឹងបាទ។

**ស៖** សូមអរគុណ។ កាលពីម្សិលមិញលោកបាននិយាយអំពីបុគ្គលិកពេទ្យស៊ីវិល ហើយលោកបានបញ្ជាក់តាំងពីម្សិលមិញ ហើយក៏ដូចជាថ្ងៃនេះដែរថា បុគ្គលិកពេទ្យនៅពេទ្យស៊ីវិលត្រូវបានគេសម្លាប់ចាប់ពីឆ្នាំ៧៧មក លោកក៏បានបញ្ជាក់ផងដែរថា លោកមិនដែលឃើញដោយផ្ទាល់នូវការសម្លាប់។ ថ្ងៃនេះផ្ទាល់លោកក៏បាននិយាយអំពីបុគ្គលិកពេទ្យមួយចំនួន ដែលត្រូវគេបញ្ជូនទៅធ្វើការនៅវាលស្រែ ឬមួយក៏បាត់ខ្លួន។ តើវាអាចដែរឬទេ ដែលថាបុគ្គលិកពេទ្យមួយចំនួនត្រូវបានគេនាំយកទៅ ឬក៏ត្រូវបានគេដកចេញពីមន្ទីរពេទ្យក្រោយឆ្នាំ១៩៧៧ ប្រហែលជាមិនត្រូវបានគេសម្លាប់នោះទេ ប៉ុន្តែប្រហែលជាគ្រាន់តែផ្លាស់ ឬក៏ប្តូរទៅធ្វើការនៅតាមវាលស្រែ ឬមួយក៏អាចថា រត់គេចចេញពីប្រទេសក្រោយពេលរបបខ្មែរក្រហមដួលរលំ? តើវាអាចដែរឬទេ?

[១៣:៤៦:៥៨]

**ឆ៖** ខ្ញុំសូមជម្រាបលោកថា ចំពោះបុគ្គលិកពេទ្យស៊ីវិលគេឲ្យធ្វើ -- គេបែងវំលែក បែងចែកឲ្យធ្វើការនៅតាមមន្ទីរពេទ្យស្រុក ហើយខ្មែរក្រហមបានបង្កើតមន្ទីរពេទ្យស្រុកចំនួនបួន បាទនៅបាត់ដំបង ហើយដល់ចេញ គឺចេញថ្ងៃតែមួយ ទាំងអស់គ្នា ទាំងខ្ញុំទាំងអីនេះ។ ពេលចេញ គឺចេញនៅថ្ងៃ៣០ បញ្ជាឲ្យចេញថ្ងៃ៣០ ថ្ងៃ៣១ មករា ១៩៧៧ យើងចេញទាំងអស់គ្នាទៅសហករណ៍រៀងៗខ្លួនបាទ។ ហើយបន្ទាប់មកចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៧ ទៅ គឺថាបាត់ខ្លួនម្តងមួយៗ ដែលក្នុងនោះលោកឃើញស្រាប់ហើយមានពីរនាក់ដែលនៅទួលស្ពែង ហើយប៉ុន្មាននាក់ទៀតគឺថា គេហៅៗទៅថាទៅព្យាបាល *(ឮមិនច្បាស់)* ហើយបាត់តែម្តង។ អ្នកទាំងអស់នោះ សុទ្ធតែគេយកទៅសម្លាប់ពីព្រោះខ្ញុំជួបប្រពន្ធ នៅម្នាក់ឯងមេម៉ាយបាទ។ ខ្លះនៅបរទេស ខ្លះនៅស្រុកខ្មែរ។ អត់មានសល់ទេបាទ។

[១៣:៤៨:២៨]

**សៈ** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមបន្តទៅនិយាយអំពីការបាត់ខ្លួនរបស់លោក ស៊ីវ ហេង។ នៅក្នុងសៀវភៅរបស់លោក លោកនិយាយអំពីលោក ស៊ីវ ហេង នៅទំព័រ ខ្មែរ ERN មានលេខ 00678758, ភាសាអង់គ្លេសគឺមានលេខ 00369682។ លោកបាននិយាយថា "យើងមិនបានទទួលព័ត៌មានអ្វី -- យើងគ្មានទទួលបានព័ត៌មានអ្វីក្រៅពីព័ត៌មានដែលឮតៗគ្នាពីមាត់មួយទៅមាត់មួយនៅក្នុងរង្វង់ទីក្រុងប៉ុណ្ណោះ។ គេបានដឹងថា ពួកខ្មែរក្រហមបានយករថយន្តមួយគ្រឿងមកដឹកលោក ស៊ីវ ហេង ដែលពិការមួយចំហៀងខ្លួនចេញពីផ្ទះទៅតាមផ្លូវទៅប៉ៃលិន"។ នៅក្នុងនេះលោកនិយាយព័ត៌មានដែលឮតៗគ្នាពីមាត់មួយទៅមាត់មួយ ហើយដូចគ្នានេះដែរ ក៏និយាយអំពីការបាត់ខ្លួនរបស់លោកអាចារ្យ សាង ហើយលោកក៏មិនមាន ហើយក៏មិនដឹងថា អ្នកណាជាអ្នកបញ្ជាឲ្យនាំខ្លួនអាចារ្យ សាង នោះដែរ។ តើវាជាការត្រឹមត្រូវដែរឬទេ អ្វីដែលលោកបានដឹងទាក់ទងទៅនឹងការបាត់ខ្លួនបុគ្គលពីរនាក់នេះ លោកដឹងព្រោះថាលោកឮពីមាត់មួយ ទៅមាត់មួយប៉ុណ្ណោះ វាគ្រាន់តែជាពាក្យចចាមអារ៉ាម ឬក៏ការនិយាយតៗគ្នានោះ?

**ឆៈ** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំៈ**

ឈប់កុំអាលទាន់ឆ្លើយ!

**លោក ហ៊ុន ឈុនលីៈ**

**ឆៈ** សូមជម្រាបថា នៅថ្ងៃទី១៧ មេសា វិទ្យុភ្នំពេញផ្សាយ មានផ្សព្វផ្សាយ ហើយយើងឮសួរអ្វីៗដែលគេនិយាយពីភ្នំពេញទៅ។ ដល់ចាប់ពីថ្ងៃទី២ទៅ គឺវិទ្យុដាច់ៗ អត់មាននិយាយមួយម៉ាត់ អត់ គឺថាបើកវិទ្យុភ្នំពេញ អត់ អត់ឮសួរទេបាទ គឺផ្តាច់បាទ។ ដូច្នេះ ព័ត៌មានតែងតែឮហើយពីមាត់មួយទៅមាត់មួយ ហើយព័ត៌មានពីមាត់មួយទៅមាត់នោះ ក៏មិនមែនខុសទាំងអស់ដែរបាទ។ ដូចជាប្រពន្ធលោក ស៊ីវ ហេង អីចឹង។ លោក ស៊ីវ ហេង បានគេដឹកគាត់ទៅបាត់ ហើយនៅឆ្នាំ ពេលដែលខ្ញុំទៅធ្វើការ ដែលខ្មែរក្រហមហៅខ្ញុំទៅធ្វើការនៅមន្ទីរពេទ្យ ព-២ ហ្នឹង ខ្ញុំក៏ពេលថ្ងៃត្រង់យូរៗម្តង ខ្ញុំលួចទៅលេងគ្រួសារបងប្អូនលោក ស៊ីវ ហេង ហ្នឹង។ ខ្ញុំជួបទាំងប្រពន្ធលោក ស៊ីវ ហេងទៀត។ គាត់មេម៉ាយនៅៗនៅផ្ទះម្នាក់ឯងជាមួយកូនហ្នឹង។ អាហ្នឹងចំពោះលោក ស៊ីវ ហេង។

[១៣:៥១:៥៤]

ហើយចំពោះអាចារ្យ សាង ក៏ដូច្នេះដែរ ក៏គេដឹកយកទៅដែរ ប៉ុន្តែគ្រាន់តែថាអ្នកណាបញ្ជាឲ្យយកទៅណាបញ្ជា យកទៅ ខ្ញុំពុំអាចដឹងបានទេ។

**ស៖** លោកនិយាយថា លោកមិនដឹងថា អ្នកណាជាអ្នកបញ្ជាឲ្យនាំខ្លួនគាត់នោះទេ។ ហើយកាលពីម្សិលមិញលោកបានបញ្ជាក់នៅពេលក្រោយថា លោកដឹងនៅពេលក្រោយថា វាជាបញ្ជាចេញមកពីថ្នាក់លើ។ តើត្រឹមត្រូវដែរឬទេ ដែលខ្ញុំនិយាយថា ដោយសារតែលោកមិនដឹងថាបញ្ជាដក ឬក៏បញ្ជានាំខ្លួនអាចារ្យ សាង ហ្នឹង ដោយសារតែលោកមិនដឹងថា បញ្ជាហ្នឹងមកពីណា លោកក៏ធ្វើការស្មានឬក៏ទាយថា វាជាបញ្ជា វាមានបញ្ជាឲ្យមានការដកខ្លួន ឬក៏នាំខ្លួនគាត់? តើជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំមិនស្មានទេ។ គ្រាន់តែថា បញ្ជាពីថ្នាក់លើ។ នៅជំនាន់នោះគេអាចនិយាយថា គេមិនដឹងឬក៏បញ្ជាពីថ្នាក់លើប៉ុណ្ណឹង។

**ស៖** លោកនិយាយថា លោកមិនមែនស្មាននោះទេ។ លោកនិយាយថា បញ្ជាហ្នឹងគឺចេញមកពីថ្នាក់លើ។ ដូច្នេះខ្ញុំសួរថា តើអ្នកណាជាអ្នកចេញបញ្ជាហ្នឹង ថាតើអ្នកណានៅថ្នាក់លើដែលចេញបញ្ជានោះ លោកអាចប្រាប់បានទេ?

[១៣:៥៤:០៦]

**ឆ៖** ខ្ញុំមិនដឹងទេ លុះត្រាតែសួរពួកខ្មែរក្រហមបានដឹងបាទ។ ខ្ញុំមិនដឹងទេ។ ព្រោះភាសានេះជាភាសាខ្មែរក្រហម។

**ស៖** ដូច្នេះ ប្រសិនបើលោកមិនដឹងអ្នកណាជាអ្នកបញ្ជានោះទេ គឺបញ្ជាឲ្យដកអាចារ្យ សាង ចេញនោះទេ តើលោកនៅតែនិយាយថាលោកមិនស្មានថា វាជាបញ្ជាពីថ្នាក់លើតទៀត ឬមួយក៏យ៉ាងដូចម្តេចដែរ?

**ឆ៖** ខ្ញុំយល់ថា អាហ្នឹងជាបញ្ជាពីថ្នាក់លើរបស់ខ្មែរក្រហម។ បាទ ដឹងតែប៉ុណ្ណឹង។ ដូចថាបើនិយាយពីថ្នាក់ គឺថាខ្មែរក្រហមទេ និយាយនេះ។ ថ្នាក់លើ គឺភាសាខ្មែរក្រហម គឺថាខ្មែរក្រហមគេចង់ធ្វើអ្វីមួយ គេចង់យករួចខ្លួន គេថ្នាក់លើបញ្ជា។ អ៊ីចឹង ជាភាសាខ្មែរក្រហមបាទ។ ហើយប្រជារាស្ត្រដែលមិនដឹង អត់ដឹង ឮតៗមកថា ថ្នាក់លើៗ អ៊ីចឹង។ ហ្នឹងជាភាសារបស់ខ្មែរក្រហមប្រើនៅក្នុងស្រុកខ្មែរ។

**ស៖** អ៊ីចឹង តើខ្ញុំនិយាយត្រឹមត្រូវដែរឬទេ ដែលថាផ្អែកតាមចម្លើយរបស់លោក និងការដឹងរបស់លោកអំពីប្រព័ន្ធដែលគេអនុវត្តនៅក្នុងរបបខ្មែរក្រហម តើអាចដែរឬទេ?

[១៣:៥៦:០៦]

**ឆ៖** នេះគឺជា -- គឺជាប្រព័ន្ធដែលគេអនុវត្តនៅក្នុងរបបខ្មែរក្រហម។

**ស៖** ខ្ញុំសូមទុកប្រធានបទនេះមួយអន្លើសិន ហើយខ្ញុំសូមបន្តទៅប្រធានបទថ្មីមួយទៀត ដែលនៅពេលនេះ ខ្ញុំនិយាយអំពី -- ពេលលោកធ្វើការនៅព្រែកហ្លួងក្នុងខែកក្កដា នៅខែកក្កដា ហើយនៅទីនោះ លោកពិពណ៌នា ហើយខ្ញុំសូមដកស្រង់ "ថា មិត្តស៊ូ បានបញ្ជាឲ្យពេទ្យ ហើយនិងគិលានុបដ្ឋាយិកា ព្រមទាំងឆ្មបដែលធ្វើការនៅមន្ទីរពេទ្យនោះ ហើយមិត្តភក្តិរបស់លោកឈ្មោះ គាត់ វេ បានស្នើសុំឲ្យលោកត្រឡប់ ហើយមកជាមួយគាត់ទៅទីក្រុងបាត់ដំបង ហើយក៏នាំទៅជាមួយលោកវេជ្ជបណ្ឌិត នី ចាន់"។ តើវាជាត្រឹមត្រូវដែរឬទេ ដែលថា មិត្តស៊ូ ចេញបញ្ជាឲ្យហៅវេជ្ជបណ្ឌិត ព្រមទាំងគិលានុបដ្ឋាយិកា និងឆ្មបមួយចំនួនតូចមកធ្វើការនៅមន្ទីរពេទ្យ តើជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ។ បាទ គឺហៅមកធ្វើការនៅព្រែកហ្លួង នៅមន្ទីរពេទ្យហ្លួង គឺមានសំបុត្រពី មិត្តស៊ូ ឲ្យខ្ញុំទៅធ្វើការនៅមន្ទីរព្រែកហ្លួង ប៉ុន្តែមុនហ្នឹង រួចទៅ ប៉ុន្តែមុនចូលព្រែកហ្លួង ឲ្យខ្ញុំទៅយកគ្រូពេទ្យម្នាក់ទៀត ដែលនៅឃុំផ្សេងបាទ ឈ្មោះពេទ្យ នី ឆម បាទ។

[១៣:៥៨:១៩]

**ស៖** ដូច្នេះ នៅពេលដែលលោកនិយាយថា មនុស្សត្រូវបានគេហៅឲ្យទៅធ្វើការនៅមន្ទីរព្រែកហ្លួង តើលោកចង់សំដៅទៅលើពេទ្យដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ ដែលគេកោះហៅទៅធ្វើការនៅមន្ទីរពេទ្យនោះ តើមែនដែរឬទេ?

**ឆ៖** មន្ទីរព្រែកហ្លួងនេះ គឺជាទីតាំងជាវិទ្យាល័យៗទេ ជាសាលារៀនទេ បើនិយាយឲ្យចំទៅ។ ដោយគេបិទសាលារៀនទាំងអស់ ហើយគេយកមន្ទីរពេទ្យ យកអគារសាលារៀននេះ ធ្វើជាមន្ទីរ ហើយសម្ភារៈមានការខ្វះខាត ឱសថ ក៏មានការខ្វះខាត។

**ស៖** សំណួររបស់ខ្ញុំគឺខុសពីនេះបន្តិច។ មិត្តស៊ូ បញ្ជាឲ្យហៅគ្រូពេទ្យ និងបុគ្គលិកពេទ្យមួយចំនួនចូលធ្វើការវិញ នៅមន្ទីរពេទ្យនោះ។ លោកទៅមន្ទីរពេទ្យព្រែកហ្លួងជាមួយគ្រូពេទ្យ នី ឆម ទៅធ្វើការនៅមន្ទីរពេទ្យនោះដែរ។ តើមានពេទ្យដទៃដែលមកធ្វើការជាមួយលោកនៅមន្ទីរពេទ្យនោះដែរឬទេ?

[១៤:០០:០០]

**ឆ៖** បាទ នៅមន្ទីរពេទ្យព្រែកហ្លួងនោះ គឺថាមានវេជ្ជបណ្ឌិតម្នាក់ទៀត ឈ្មោះ យឹម គឹមសាន ដែលក្រោយមកមានៗឈ្មោះនៅទួលស្លែង។ ខ្ញុំ គ្រូពេទ្យ នី ឆម និងទន្តពេទ្យម្នាក់ទៀត ហើយនិង

គិលានុបដ្ឋាយិកាម្នាក់ទៀត ទាំងអស់ ៤នាក់បាទ។ ហើយក្រៅពីនោះសុទ្ធតែជាបុគ្គលិកពេទ្យខ្មែរក្រហមបាទ។

**ស៖** នៅពេលដែលយើងនិយាយអំពីមន្ទីរពេទ្យព្រែកហ្លួង នេះគឺជាមន្ទីរពេទ្យដែលគេប្រើប្រាស់សម្រាប់ព្យាបាលប្រជាជន តើត្រឹមត្រូវដែរឬទេ?

**ផ៖** មន្ទីរពេទ្យព្រែកហ្លួងនេះជាមន្ទីរពេទ្យដែលខ្មែរក្រហមហៅថា "មន្ទីរពេទ្យថ្នាក់ៗស្រុក" បាទ មន្ទីរពេទ្យថ្នាក់ស្រុក ដែលគេទទួលព្យាបាលប្រជារាស្ត្រ។

[១៤:០១:១២]

**ស៖** លោកបាននិយាយនៅក្នុងសៀវភៅរបស់លោកថា "សម្រាប់អ្នកជំងឺទាំងអស់ដែលឈឺធ្ងន់លោកបញ្ជា បង្គាប់ឲ្យមានថ្នាំពេទ្យព្យាបាល" តើលោកបានថ្នាំពេទ្យហ្នឹងមកពីកន្លែងណាដែរ ឬក៏លោកទទួលបានពីណាមកដែរថ្នាំពេទ្យទាំងអស់នេះ?

**ផ៖** ថ្នាំពេទ្យទាំងអស់នេះគឺថា ប្រធានមន្ទីរពេទ្យគេបានពីណាមក ខ្ញុំមិនដឹងទេ ប៉ុន្តែនៅឃ្លាំងមានឃ្លាំងឱសថមួយដែលប្រធានមន្ទីរពេទ្យកាន់កាប់បាទ។ ខ្ញុំមិនដឹងថាគេបានពីណាមកទេ។

**ស៖** ដូច្នេះនៅក្នុងមន្ទីរពេទ្យខ្មែរក្រហមមួយនោះ លោកធ្វើការព្យាបាលអ្នកជំងឺ ហើយលោកចេញវេជ្ជបញ្ជាឲ្យបើកថ្នាំសម្រាប់ប្រជាជនស៊ីវិលដែរ។ តើខ្ញុំនិយាយបែបនេះត្រឹមត្រូវដែរឬទេពាក់ព័ន្ធទៅនឹងមន្ទីរពេទ្យព្រែកហ្លួងនោះ?

**ផ៖** បាទ ត្រឹមត្រូវបាទ។

[១៤:០៣:០១]

**ស៖** ខ្ញុំសូមបន្តទៅមុខបន្តិចទៀតទាក់ទងទៅនឹងពេលវេលា ដែលលោកធ្វើការនៅមន្ទីរពេទ្យយោធា ព-២ លោកនៅទីនោះនៅខែកក្កដា ឆ្នាំ១៩៧៥ ដល់តុលា ១៩៧៦។ តើលោកចាំឈ្មោះរបស់វេជ្ជបណ្ឌិតដែលនៅធ្វើការនៅទីនោះដែរឬទេ គឺវេជ្ជបណ្ឌិតដែលធ្វើការជាមួយលោក តើលោកចាំឈ្មោះពួកគាត់ដែរឬទេ?

**ផ៖** បន្ទាប់ពីធ្វើការនៅមន្ទីរពេទ្យព្រែកហ្លួងបានជាង ២ខែ ខ្ញុំទទួលសំបុត្រពីប្រធាន -- អនុប្រធានតំបន់៣ ឲ្យទៅធ្វើការនៅមន្ទីរពេទ្យយោធា ព-២។ នៅមន្ទីរពេទ្យយោធា ព-២ នេះគឺមានតែខ្ញុំទេដែលជាវេជ្ជបណ្ឌិត ក្រៅពីហ្នឹងគឺជាបុគ្គលិកពេទ្យខ្មែរក្រហមទាំងអស់។ ប៉ុន្តែបុគ្គលិកបែងចែកដូច្នេះមានបុគ្គលិកស្រីពីរក្រុម បុគ្គលិកប្រុសពីរក្រុម។ បុគ្គលិកប្រុសមួយក្រុម ជាកូនអ្នកមូលដ្ឋាន ឬមួយកូន

ចៅពួកខ្មែរក្រហម។ កូនបុគ្គលិកប្រុសមួយក្រុមទៀតជាកូនប្រជាជនធម្មតា ឬមួយអតីតសិស្សវិទ្យាល័យដែលគេជ្រើសរើសមកធ្វើការជាពេទ្យនៅមន្ទីរពេទ្យយោធានេះ។ បាទ ហើយខាងស្រីក៏ដូចគ្នាដែរបាទ។ ហើយខ្ញុំគេ -- ត្រូវគេបញ្ជូនក្នុងក្រុមៗប្រជា -- កូនប្រជារាស្ត្រដែលចូលមកធ្វើការនៅមន្ទីរពេទ្យយោធានេះបាទ។ ខ្ញុំមកធ្វើការនៅមន្ទីរពេទ្យយោធានេះពុំមានតួនាទីជាប្រធានអ្វីទេ គឺថា បើនិយាយសាមញ្ញ និយាយសាមញ្ញទៅគេថា បុគ្គលិកទាបបំផុត ឬមួយថាជាអ្នកទោសមួយដែល អ្នកទោសម្នាក់ប៉ុណ្ណឹងបាទ។ ប៉ុន្តែគ្រាន់តែថា បើមានបញ្ហាបច្ចេកទេស អាហ្នឹងគេហៅខ្ញុំទៅជួយព្យាបាលអ្នកជំងឺ និងជួយបង្ហាត់បង្រៀនអំពីរបៀបព្យាបាល របៀបថែទាំអ្នកជំងឺ ប៉ុណ្ណឹងទេបាទ ប៉ុណ្ណឹង។ ហើយខ្ញុំនេះនៅក្នុងក្រុម--

[១៤:០៥:៥៤]

**ស៖** លោកសាក្សី ខ្ញុំនឹង -- ខ្ញុំសូមអនុញ្ញាតលោកមេត្តាឆ្លើយឲ្យបានខ្លីបន្តិច។ ដូច្នេះ ខ្ញុំសូមបន្តទៅប្រធានបទថ្មីមួយទៀត ដែលលោកបានពិភាក្សា ដែលបានសរសេរដោយសង្ខេបនៅក្នុងសៀវភៅរបស់លោក ហើយលោកក៏បាននិយាយដោយសង្ខេបកាលពីថ្ងៃចន្ទ ផងដែរ នោះគឺការនិយាយអំពីការវះកាត់ពិសោធន៍។ លោកបាននិយាយនូវបញ្ហាមួយចំនួន ទាក់ទងនឹងប្រធានបទនេះកាលពីម្សិលមិញ។ ប៉ុន្តែ សំណួររបស់ខ្ញុំនៅថ្ងៃនេះ គឺចង់សួរលោកថា តើលោក ខ្លួនលោកផ្ទាល់មានបានឃើញដោយផ្ទាល់នូវការវះកាត់ពិសោធន៍ ដែលធ្វើដោយមន្ត្រីខ្មែរក្រហម ឬក៏បុគ្គលិកពេទ្យខ្មែរក្រហមនោះទេ? ខ្ញុំមិនចង់និយាយអំពី អ្វីដែលលោកបានឮ អ្វីដែលគេប្រាប់លោក ឬក៏ការអានរបស់លោកនោះទេ ខ្ញុំចង់និយាយដោយផ្ទាល់ ថាតើខ្លួនលោកផ្ទាល់បានឃើញដោយផ្ទាល់ភ្នែក អំពីការវះកាត់ពិសោធន៍ ដែលធ្វើឡើងដោយពួកខ្មែរក្រហម ឬក៏ថាអាចខ្លួនលោកផ្ទាល់ហ្នឹងចូលរួម នៅក្នុងការវះកាត់នោះផ្ទាល់ដែរ តើលោកដែលឃើញដែរឬទេ?

[១៤:០៧:២៦]

**ឆ៖** ខ្ញុំបាននិយាយម្សិលមិញហើយ អំពីការដែលគេចាក់ថ្នាំនាងស្រីម្នាក់ឲ្យដេកលក់ទៅ--

**ស៖** លោកសាក្សី ខ្ញុំសូមកាត់លោកត្រង់ចំណុចនេះ យើងបានស្តាប់ឮចំណុចនេះកាលពីម្សិលមិញហើយ។ សំណួររបស់ខ្ញុំគឺសាមញ្ញទេ គឺថាតើលោកបានឃើញផ្ទាល់ទេ ឃើញការវះកាត់ផ្ទាល់ភ្នែកដែរឬទេ? ឬក៏លោកនេះ ជាអ្នកធ្លាប់ចូលរួមក្នុងការវះកាត់ដោយផ្ទាល់ដែរឬទេ?

**ឆ៖** ខ្ញុំសួរលោកវិញថា លោកសួរថាខ្ញុំបានឃើញការវះកាត់ជំងឺណា? អ្នកនាងដែលខ្ញុំនិយាយ

ពីម្សិលមិញហ្នឹង ឬយ៉ាងណា? លោកចង់និយាយពីនាងៗដែលខ្ញុំនិយាយម្សិលមិញហ្នឹង ឬមួយអ្នកផ្សេងទៀត?

**សៈ** សំណួរគឺថា ការវះកាត់ពិសោធន៍ដែលធ្វើឡើងដោយខ្មែរក្រហម លោកបាននិយាយអំពីចំណុចនេះនៅក្នុងសៀវភៅរបស់លោក។ ការវះកាត់ពិសោធន៍ -- ការពិសោធការវះកាត់នេះ គឺត្រូវបានគេចោទ ប្រកាន់ថា បានធ្វើឡើងចំពោះអ្នកដែលមានជីវិតរស់តែម្តង គឺគេវះកាត់មនុស្ស ពិសោធន៍មនុស្សរស់តែម្តង តើលោកធ្លាប់បានឃើញ ឬចូលរួមដោយផ្ទាល់ដែរឬទេ?

**ឆៈ** ខ្ញុំមិនដែលបានឃើញទេ ហើយសំខាន់ទៅទៀត ខ្ញុំមិនដែលបានចូលរួមទេ ពីព្រោះខ្ញុំមិនមែនពេទ្យណាហ្នឹទេ។

[១៤:១០:០០]

**សៈ** សូមអរគុណ។ ខ្ញុំសូមសួរលោកលើប្រធានបទមួយទៀត។ គឺហេតុការណ៍ ឧប្បត្តិហេតុដែលបានលើកឡើងដោយខាងសហព្រះរាជអាជ្ញា គឺឧប្បត្តិហេតុដែលបានកើតឡើងក្នុងពេលដែលលោកទៅជាមួយនឹង ចាន់ -- ទៅជាមួយនឹង ឆោម ដែលគាត់ជាអ្នកដែលធ្វើការនៅសាលាវិចិត្រសិល្បៈ។ ខ្ញុំសូមអធ្យាស្រ័យ ដោយសារតែខ្ញុំនិយាយឈ្មោះនេះមិនច្បាស់។ ដូច្នេះ ខ្ញុំសូមអានត្រង់ផ្នែកនេះតែម្តងគឺ 00269705 ជាភាសាអង់គ្លេស, ខ្មែរគឺ 00678789 "ក្រោយពេលអាហារថ្ងៃត្រង់ខ្ញុំអញ្ជើញ ឆោម (ស៊ីក) នេះទៅដើរតាម -- បន្ទាប់ពីហូបបាយថ្ងៃត្រង់ ខ្ញុំបបួលគ្រូសិល្បៈដើរតាមដងស្ទឹង គ្រប់ផ្ទះមានសភាពស្ងប់ ហើយគឺថា លោកគ្រូខ្ញុំបាន -- ខ្ញុំបានសួរគាត់ថា លោកគ្រូមកធ្វើអ្វី? ខ្ញុំមកតាមក្រុមសិល្បៈ។ ខ្ញុំឆ្លើយ"។ គឺយើងបន្ទាប់មក គឺយើងនិយាយ -- លោកបានសរសេរថា "យើងលាគាត់ ហើយបន្តដំណើរមកដល់ផ្លូវជាតិលេខ៥ ឃើញអ្នកបើកបររថយន្ត យើង ដែលខ្ញុំធ្លាប់ស្គាល់អង្គុយនៅលើដុំមួយយ៉ាងធំនៅគល់ស្ពានឈើ នៃស្ទឹងមោងឫស្សី។ ខ្ញុំហាក់ដូចជាមានធុំក្លិនខ្មោចនៅមិនឆ្ងាយពីយើង។ នៅមុនថ្ងៃ១៧ មេសា ទីផ្សារមោងឫស្សី ជាកន្លែងប្រយុទ្ធទាំងធំ យល់ពីអាការៈខ្ញុំអ្នកបើកបររថយន្តនិយាយថា នៅទីនោះមានមនុស្សស្លាប់ច្រើនណាស់ ហើយខ្មោចជុំវិញហ្នឹង គ្មានអ្នកណាយកចេញទេ"។

[១៤:១២:១២]

ខ្ញុំហាក់ដូចជាយល់មិនសូវច្បាស់សោះ នៅត្រង់អ្វីដែលលោកបានសរសេរនៅក្នុងនេះ។ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេថា នៅថ្ងៃនោះគឺថា សពដែលលោកធុំក្លិននោះគឺថា ធុំក្លិនស្អុយណាស់ ហើយគឺ

ជាសពទាហានដែលត្រូវបានគេសម្លាប់ក្នុងពេលវាយប្រយុទ្ធគ្នា មុនថ្ងៃទី១៧ ខែមេសា។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ជាការពិត។ នៅមោងឫស្សី មានបន្ទាយមួយឈ្មោះបន្ទាយព្រៃស្វាយ ហើយមុនវៃមុនចូលក្រុងបាត់ដំបង ទាហានខ្មែរក្រហមបានវាយកម្ទេចបន្ទាយនៅជិតមោងនោះបាទ។ ហើយការប្រយុទ្ធហ្នឹងគឺប្រយុទ្ធខ្លាំង នៅសូម្បីតែផ្ទះថ្មនៅមោងឫស្សី ក៏មានស្នាមធ្លុះដោយគ្រាប់កាំភ្លើងដែរបាទ។ ហើយការប្រយុទ្ធគ្នា ប្រយុទ្ធខ្លាំងណាស់គឺមានស្លាប់ច្រើនបាទ។ បន្ទាប់មកបានខ្មែរក្រហមរុលៗរហូតទៅដល់បាត់ដំបងបាទ។ ហើយពេលដែលខ្ញុំដើរទៅដល់ជិតស្ទឹងនោះ ខ្ញុំមានធុំក្លិន ដូចថា មិនមែនស្អុយណាស់ណា ប៉ុន្តែធុំដូចជាមិនធម្មតាបាទ។ ហើយសូហ្វ៊ រគាត់ប្រាប់ខ្ញុំគាត់ថា ខ្មោចនៅនេះយកចេញមិនទាន់អស់ទេ គឺថានៅមានសល់។ ហេតុដូច្នេះបានជាមានធុំ អាហ្នឹងគឺអ៊ីចឹង សភាពការណ៍បាទ។

**ស៖** តើសពទាំងអស់នោះ ជាសពទាហានសម័យ លន់ នល់ និង សពរបស់ទាហានខ្មែរក្រហមផងដែរ ឬក៏យ៉ាងម៉េចដែរ? សព គឺសពរបស់ខ្មែរក្រហម និងសពទាហាន លន់ នល់ មែនដែរឬទេ?

[១៤:១៤:១២]

**ឆ៖** ខ្ញុំមិនអាចថា អ្វីដែលខ្ញុំអាចនិយាយបានគឺថា អាចថា សពទាហានខ្មែរក្រហមផង សពទាហាន លន់ នល់ ផង សពប្រជារាស្ត្រផង។ ពីព្រោះការដែលវាយនៅមោងនោះ ប្រជារាស្ត្រក៏មានការរងគ្រោះដែរបាទ។

**ស៖** តើលោកដឹងទេថា មានអ្វីកើតឡើងដែរចំពោះសពទាំងអស់នោះ តើគេយកសពទាំងអស់នោះទៅកប់ចោល ឬក៏គេធ្វើអ្វីដែរចំពោះសពទាំងអស់នុ៎ង?

[១៤:១៥:០០]

**ឆ៖** ខ្ញុំមិនដឹងទេបាទ ខ្ញុំមិនដឹង។

**ស៖** តើលោកធ្លាប់ឃើញ ឬក៏ធ្លាប់ឆ្លងកាត់ដែរឬទេ ក្នុងនាមជាគ្រូពេទ្យម្នាក់? តើលោកធ្លាប់ឃើញទេថា គេធ្វើអ្វីដែរចំពោះសពទាហានដែលបានស្លាប់នៅក្នុងការវាយប្រយុទ្ធគ្នាមុនថ្ងៃ១៧ មេសានោះ? ថាតើគេកប់នៅក្នុងផ្នូរខ្មោចនីមួយៗ ឬក៏គេប្រមូលផ្តុំគ្នា ហើយកប់ក្នុងផ្នូររួមតែងម្តង? តើលោកធ្លាប់ឆ្លងកាប់ ធ្លាប់ឃើញទេ ថាមានអ្វីកើតឡើងដែរចំពោះសព្វទាំងហ្នឹង?

**ឆ៖** ខ្ញុំមិនបានដែលបាទឃើញទេ ប៉ុន្តែខ្ញុំដឹងថាតាមប្រពៃណីខ្មែរ គឺសពនីមួយៗយកទៅបូជា។ នៅ -- បូជានៅៗប៉ាឆាក្នុងវត្ត។

[១៤:១៦:៣៥]

**ស៖** តើលោកដឹងថាគេបានធ្វើអ្វីចឹងចំពោះសពទាហានដែលចាស់ៗដែលត្រូវបានគេ ដែលត្រូវបានស្លាប់នៅក្នុងពេលវាយប្រយុទ្ធនោះដែរឬទេ?

**ឆ៖** ខ្ញុំមិនអាចដឹងអស់ទេបាទ។ មិនអាចដឹងអស់ មិនអាចឃើញអស់។

**ស៖** នៅក្នុងសៀវភៅរបស់លោក លោកក៏បានលើកឡើងអំពីហេតុការណ៍មួយទៀត។ ត្រង់អង់គ្លេស 00369813, ខ្មែរគឺ 00678932។ លោកបានលើកឡើងអំពីហេតុការណ៍សោកនាដកម្មមួយនៅក្នុងឆ្នាំ១៩៨២ ដែលលោកបានឃើញថា នៅកន្លែងនោះគឺមានការកប់នៅ -- គឺគេបានបំផុសកម្មាភិបាលបុគ្គលិកឲ្យសម្លាប់ជនជាតិចិន ហើយក៏មានបញ្ហាកើតឡើងជាពិសេសហេតុការណ៍ ក៥ នោះ។ តើលោកបានដឹងទេ តើគេមានបានកប់មនុស្សរាប់សែននៅពេលនោះដែរឬទេ?

**ឆ៖** សំណួរលោកដូចជាចាកប្រធាន ពីព្រោះថាសំណួរលោកត្រូវនៅក្នុងក្របខ័ណ្ឌ៧៥ ដល់៧៩។ លោកសួរនេះចូលដល់ឆ្នាំ៨២ ហើយ។

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ សំណួរក្រៅអង្គហេតុ មិនពាក់ព័ន្ធទេ។

[១៤:១៨:៥២]

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** លោកសាក្សី តើនរណាគេជាអ្នកប្រាប់លោកថា ឲ្យលោកនេះឆ្លើយតែលើសក្ខីកម្ម ឬអង្គហេតុនៅក្នុងចន្លោះឆ្នាំ៧៥ ដល់៧៩ នោះ?

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ខ្ញុំដឹងថា តុលាការនេះកាត់សេចក្តីតែអំពីហេតុការណ៍ដែលកើតរវាង៧៥ ដល់ឆ្នាំ៧៩។ នេះខ្ញុំដឹងអ៊ីចឹងបាទ។ ប៉ុន្តែបើលោកប្រធានតុលាការយល់ថា ខ្ញុំត្រូវឆ្លើយលើសពីហ្នឹងទៀត អាហ្នឹងខ្ញុំឆ្លើយ។ បើលោកប្រធានយល់ថា ខុសៗវិសាលភាពតុលាការ ខ្ញុំក៏មិនឆ្លើយដែរ។

**ប្រធានអង្គជំនុំ៖**

យើងសម្រេចរួចហើយអំមិញថា មិនចាំបាច់ឆ្លើយតបទេ។ សំណួរគឺមិនពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ឲ្យធ្វើសវនាការ។

[១៤:២០:០០]

**លោក ហ្សាស្តេី ប៉ោ៖**

ឯកសារ D នៅក្នុងឯកសារ D140/1/1 គឺជាស្ថិតិប្រជា -- ស្តីអំពីចំនួនប្រជាជន នៅក្នុងនោះ បាននិយាយថា ទិន្នន័យទាក់ទងទៅនឹងការកំណត់ផ្នូររួមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានោះ គឺបង្ហាញអំពីជនរងគ្រោះនៅក្នុងសម័យខ្មែរក្រហម ហើយទិន្នន័យទាំងអស់នេះ គឺមិនមាន -- មិនត្រឹមតែមានប្រយោជន៍ផងដែរនោះទេ គឺត្រូវតែធ្វើឡើងផងដែរ។ វាបង្ហាញយ៉ាងច្បាស់ថា ជនរងគ្រោះភាគច្រើននៅក្នុងផ្នូររួមនោះទោះបីមិនទាំងអស់ក៏ដោយ គឺជាជនរងគ្រោះខ្មែរក្រហម។ នៅក្នុងរបាយការណ៍នោះផងដែរ ក៏បានលើកឡើងផងដែរ គេមិនបានដឹងថា មានហេតុការណ៍ណាផ្សេងកើតនៅក្នុងប្រវត្តិសាស្ត្រកម្ពុជាដែលនាំឲ្យមានការកាប់សម្លាប់ ឬការស្លាប់មនុស្សច្រើនដូចនេះផងដែរ។ ដូច្នេះវាគឺពាក់ព័ន្ធទៅនឹងបញ្ហាផែនការ ក៥ ដែលមានមនុស្សស្លាប់រាប់ពាន់នាក់។

[១៤:២១:២៩]

ក៥ ជាពិសេសកើតឡើងនៅម្តុំបាត់ដំបង ដោយសារហេតុនេះហើយវាទំនងដែលថា ប្រជាជនដែលបានស្លាប់នៅក្នុងគម្រោងផែនការក៥ នោះក៏ត្រូវបានគេយកទៅកប់ក្នុងផ្នូររួមនោះផងដែរ។ ដោយសារតែមានមនុស្សរាប់រយរាប់ពាន់នាក់នៅក្នុងពេលនោះ បានស្លាប់។ គឺវាជាសំណួរមួយពាក់ព័ន្ធផងដែរថាតើសាក្សីនោះមានបានដឹងថាជនរងគ្រោះនៅក្នុងគម្រោងផែនការ ក៥ នោះត្រូវបានគេយកទៅកប់នៅក្នុងផ្នូររួមនោះ រួមជាមួយគ្នាដែរឬទេ? ជាពិសេសនៅម្តុំតំបន់ទីក្រុងបាត់ដំបង។ ហេតុដូច្នេះហើយវាជាសំណួរមួយដែលវាមានសំខាន់ ទោះបីវាជានៅក្រៅវិសាលភាពនៃយុត្តាធិការរបស់អង្គជំនុំជម្រះក៏ដោយជាពិសេសដោយសារតែវាមានហេតុផល--

**ប្រធានអង្គជំនុំ៖**

អត់បាច់ឆ្លើយតបទេសាក្សី ពីព្រោះមេធាវីបានបញ្ជាក់ខ្លួនឯងច្បាស់ហើយជាសំណួរក្រៅវិសាលភាពនៃអង្គជំនុំជម្រះកំណត់ធ្វើសវនាការ គឺវិសាលភាពនៃដែលសមត្ថកិច្ច អ.វ.ត.ក រួចទៅហើយ។

[១៤:២៣:០៩]

**លោក ហ្សាស្តេី ប៉ោ៖**

ខ្ញុំសូមឲ្យអង្គជំនុំជម្រះបង្ហាញនូវហេតុផលមួយឲ្យបានច្បាស់លាស់ ដែលខ្ញុំនៅពេលនេះអះអាងថា មានជនរងគ្រោះរាប់រយនាក់នោះ មិនត្រូវបានសម្លាប់ដោយខ្មែរក្រហមនោះទេ។ ក៏ប៉ុន្តែមានជនរងគ្រោះរាប់សែននាក់ដែលត្រូវបានគេសម្លាប់នៅក្នុងគម្រោងផែនការ ក៥។ ដូច្នេះ វាជាភស្តុតាងមួយដោះ

បន្ទុកដែលយើងខ្ញុំចង់សួរជជីកទៅលើបញ្ហានេះ។ ហើយទោះបីជាវាមិនស្ថិតនៅក្នុងយុត្តាធិការពេលវេលាក៏ដោយខ្ញុំសូមលើកឡើងចំណុចនេះ ដោយគោរពអង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

យើងបានស្តាប់លោកនិយាយដោយខ្លួនឯង។ បង្ហាញដោយខ្លួនឯងថា វាក្រៅវិសាលភាពនៃដែនសមត្ថកិច្ចរបស់ អ.វ.ត.ក។ នេះជាការបញ្ហាយ៉ាងច្បាស់លាស់រួចទៅហើយ ហើយអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យតាំងសំណួរដេញដោលឯណា ដែលក្រៅវិសាលភាពនៃអង្គហេតុអង្គជំនុំជម្រះកំណត់ឲ្យធ្វើសវនាការទេ។ នៅក្នុងនោះ គឺអង្គជំនុំជម្រះបានកំណត់ធ្វើសវនាការដេញដោលទៅលើអង្គហេតុលើវិសាលភាពក្នុងសំណុំរឿង ០០២/០១។ ដោយឡែកសាក្សីនេះ គឺមានការពាក់ព័ន្ធទៅលើអង្គហេតុពីរសំខាន់គឺ អនុវត្តគោលនយោបាយជម្លៀស ហើយនិងរចនាសម្ព័ន្ធរដ្ឋបាលមូលដ្ឋាន។

[១៤:២៤:២៧]

យើងបានប្រាប់តាំងពីព្រឹក តាំងពីដើមដំបូងនៃការដំណើរការស្តាប់សក្ខីកម្មដើម -- ប្រគល់វេទិកាទៅតាំងសំណួរដេញដោល គឺយើងបានកំណត់អំពីវិសាលភាពនៃការដែលដឹង ដែលអង្គហេតុដែលអាចពាក់ព័ន្ធ ហើយនិងដំណើរការប្រព្រឹត្តទៅនៃការដេញដោលចំពោះសាក្សីនេះ។ អ៊ីចឹងវាមានទាំងពីរ ទាំងវិសាលភាពនៅក្នុង អ.វ.ត.ក ទាំងវិសាលភាពនៅក្នុងសំណុំរឿង ០០២/០១ ទាំងវិសាលភាពនៃសាក្សីដែលកំណត់ឲ្យធ្វើសវនាការនេះបានដឹងនូវអង្គហេតុដែលខ្លួនមានសមត្ថភាពអាចឆ្លើយបំភ្លឺចំពោះមុខអង្គសវនាការបាន។

**លោក ហ្វាស្តើ ប៉ោ៖**

លោកប្រធាន ខ្ញុំនឹងបន្តទៅមុខទៀត ខ្ញុំគ្រាន់តែចង់លើកឡើងនៅក្នុងប្រតិចារិកថា គឺសាក្សីរូបនេះក៏បានដឹងអំពីហេតុការណ៍នេះផងដែរ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

បើសិនជាអស់សំណួរលោកអាចប្រគល់វេទិកាទៅឲ្យមេធាវីផ្សេងទៀតបាន។

**លោក ហ្វាស្តើ ប៉ោ៖**

ខ្ញុំនឹងចូលសួរទៅដល់ប្រធានបទមួយផ្សេងទៀត ទោះបីជាខ្ញុំមិនអាចមានឱកាសសួរអំពីភស្តុតាងដោះបន្ទុកនេះក៏ដោយ។

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** លោកសាក្សី លោកបានលើកឡើងថា មាន -- កន្លែងដែលលោករស់នៅនោះ វានៅឆ្ងាយពីស្រុក ហើយគឺលោកបានបង្ហាញអំពីរចនាសម្ព័ន្ធរដ្ឋបាលរបស់របបកម្ពុជាប្រជាធិបតេយ្យ។ សូមឱ្យលោកជួយពន្យល់ទៅមើល៍ថា នៅពេលដែលលោកនិយាយថា ស្រុកនោះនៅឆ្ងាយពីកន្លែងដែលលោកនៅនោះ គឺចង់បានន័យយ៉ាងម៉េចដែរ?

[១៤:២៦:៣៥]

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** រចនាសម្ព័ន្ធរដ្ឋបាលរបស់ខ្មែរក្រហម គឺមានគេហៅថា ភូមិ មានឃុំ មានស្រុក មានតំបន់ និងមានភូមិភាគ។ ស្រុកនេះ ខ្ញុំចង់និយាយថា ស្រុកហ្នឹងនៅឆ្ងាយពីកន្លែង ពីភូមិខ្ញុំ នៅឆ្ងាយពីភូមិខ្ញុំ ស្រុកហ្នឹង ឆ្ងាយពីភូមិខ្ញុំ។ ចង់និយាយអ៊ីចឹង ស្រុក។ មិនឆ្ងាយប៉ុន្មាន ប៉ុន្តែថា អើ! វាប្រហែលឆ្ងាយជាងភូមិខ្ញុំ ហើយប៉ុន្តែគ្រាន់ថារចនាសម្ព័ន្ធដែលនៅជាប់ជិតដិតនឹងប្រជារាស្ត្រជាងគេ គឺគណៈឃុំហ្នឹងឯងឃុំ។

**ស៖** ដូច្នេះ តើលោកដឹងដែរទេ អំពីហេតុការទាំងឡាយដែលកើតឡើងនៅមន្ទីរស្រុកឯណោះនោះ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ?

[១៤:២៧:៥៣]

**ឆ៖** ខ្ញុំមិនអាចដឹងបានទេ ពីព្រោះទាំងខ្ញុំទាំងគេ ពុំអាចដើរទៅណាបានដោយស្រេចតែចិត្តយើងទេបាទ។ គឺថាការដើរ គឺថាការដើរចេញពីភូមិជាការគ្រោះថ្នាក់។ ទាល់តែមានច្បាប់អនុញ្ញាតបានដើរបាន។

**ស៖** សូមអរគុណ។ នៅក្នុងសៀវភៅរបស់លោក លោកលើកឡើងអំពីការសម្អាត សម្រិតសម្រាំង ឬក៏ការលាងនូវខួរក្បាលស្មារតី ជាពិសេសគឺលោកបាននិយាយអំពីការការលាងជុសខាត់ស្មារតីសតិអារម្មណ៍ ហើយលោកក៏បានលើកឡើងថា លោកបានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល សម្រិតសម្រាំងខួរក្បាលនោះផងដែរ។ អង់គ្លេសគឺ 00369--

**អ្នកបកប្រែ៖**

សូមអធ្យាស្រ័យលោកប្រធាន។ អាចសូមឱ្យមេធាវីបញ្ជាក់លេខ ERN ជាភាសាអង់គ្លេសឡើងវិញ។

**លោក ហ្សាស្តេី ប៉ោ៖**

--គឺឯកសារជាភាសាខ្មែរ លេខ 00678926។ ខ្មែរ សូមកែតម្រូវ គឺ ERN ជាភាសាខ្មែរ គឺ 00678933 ហើយខ្ញុំចង់សួរទៅកាន់សាក្សី តើលោកអាចជួយពន្យល់ទេ វគ្គបណ្តុះបណ្តាលដុសខាត់ខួរក្បាលនោះចង់បានន័យយ៉ាងម៉េចដែរ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

[១៤:៣០:០៥]

**ប្រធានអង្គជំនុំ៖**

កុំៗអាលទាន់ឆ្លើយតប។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

ខាងមេធាវីការពារក្តីនោះគឺហាក់ដូចជាមិនបានបង្ហាញផងសោះ ឯកសារនៅត្រង់ចំណុចណាឲ្យបានច្បាស់លាស់។ ថាតើវានៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ ឬនៅក្រៅរង្វង់កម្ពុជាប្រជាធិបតេយ្យ ដូច្នេះសំណួរនេះប្រសិនបើលើកឡើងច្បាស់លាស់ទៅថា មិនពាក់ព័ន្ធខ្ញុំសូមជំទាស់។

[១៤:៣០:៣៣]

**លោក ហ្សាស្តេី ប៉ោ៖**

លោកប្រធានជាទីគោរព ខ្ញុំនឹង -- ដើម្បីជាប្រយោជន៍ទៅដល់ខាងព្រះរាជអាជ្ញានោះ គឺថាខ្ញុំនឹងសុំអាននូវចំណុចដែកពាក់ព័ន្ធនៅក្នុងនេះ។ ERN ជាភាសាអង់គ្លេសគឺ 00369814 គឺនៅក្នុងឆ្នាំ១៩៨៦ ក្រោយពីគាត់មកពីប្រទេសវៀតណាមវិញចូលរួមវគ្គបណ្តុះបណ្តាលដុសខាត់ខួរក្បាលនោះ។ គឺចំណុចនេះគឺបានលើកឡើងដោយសាក្សីនៅក្នុងសៀវភៅ។ ខ្ញុំគិតថាវាពាក់ព័ន្ធ ហើយវាអាចជាប់ទាក់ទងទៅនឹងភាពទុកចិត្តបានរបស់សាក្សីនេះ។ ហើយគាត់ក៏បានលើកឡើងថា "វៀតណាមចូលរួមក្នុងវគ្គបណ្តុះបណ្តាលដុសខាត់ខួរក្បាលនៅពេលនោះ"។ ដូច្នេះហើយខ្ញុំគិតថា គឺយើងក៏ចង់លើកឡើងចំណុចនេះគឺថា វាពាក់ព័ន្ធទៅនឹងវៀតណាម ដែលថាជាអ្នកមានបំណងចូលរួមនៅក្នុងបញ្ហាការងារទាំងអស់នេះ ដូច្នេះក៏អាចជាអ្នកទទួលខុសត្រូវផងដែរ។ វៀតណាមគឺមានរបៀបវារៈរបស់គេ ហើយរបៀបវារៈនេះគឺវាជះឥទ្ធិពលទៅដល់សកម្មភាពនានា។ ដេវីដ ឆេនដ៍ល័រ បានលើកឡើង និងទទួលស្គាល់ចំណុចនេះផងដែរ។ ហើយនៅពេលនេះ គឺយើងឃើញនៅក្នុងស្នាដៃសៀវភៅរបស់សាក្សីរូបនេះបង្ហាញថា វៀតណាមនោះ

ក៏ចូលរួមក្នុងការវគ្គបណ្ដុះបណ្ដាលនយោបាយផងដែរ។ ដូច្នេះហើយវាពាក់ព័ន្ធ ហើយវាទុក -- វាជាប់ទាក់ទងទៅនឹងភាពទុកចិត្តបាននៃសាក្សីនេះ ហើយសាក្សីនេះដឹងមកពីណាដែរ។ ដូច្នេះហើយខ្ញុំគ្រាន់តែចង់សួរទៅកាន់សាក្សីថា តើវៀតណាមមានចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលនយោបាយដែរឬទេ? ហើយថាតើខ្ញុំចង់ដឹងព័ត៌មានទាំងអស់នេះ គឺជាព័ត៌មានដែលគាត់យកមកពីប្រភពផ្សេង ហើយដាក់បញ្ចូលនៅក្នុងនេះ ឬក៏គាត់ដឹងដោយផ្ទាល់? ហើយខ្ញុំក៏ចង់ដឹងផងដែរ ថាតើវគ្គនយោបាយនោះគឺគាត់ចង់បានន័យយ៉ាងម៉េច? ហើយវាមានសមាសភាព និងវាទាក់ទងយ៉ាងម៉េចផងដែរ?

[១៤:៣២:៥០]

ហើយគឺគ្មានសាក្សី ឬបុគ្គលណាមួយដែលបាន -- ធ្លាប់បានលើកឡើងអំពីវគ្គអប់រំនយោបាយនេះនោះទេ ដូច្នេះហើយវាអាចជាប់ទាក់ទងទៅនឹងភាពទុកចិត្តបាននៃសាក្សីរូបនេះ។ ប្រសិនបើមេធាវីការពារក្ដីមិនអាចទទួលបានសិទ្ធិក្នុងការជជីកសួរអំពីបញ្ហានៃវគ្គបណ្ដុះបណ្ដាលអប់រំនយោបាយនេះទេ គឺថាវាអាចបាត់ប្រយោជន៍សម្រាប់យើង។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំសូមលើកឡើងផងដែរ ដោយសារតែវាពាក់ព័ន្ធនឹងក្រុមរបស់យើងខ្ញុំផង។ ខ្ញុំសូមបន្ថែមការលើកឡើងថា សាក្សីរូបនេះបានលើកឡើងថា ២៥ឆ្នាំក្រោយពីហេតុការណ៍នេះកើតឡើង គឺគាត់ចាប់ផ្ដើមសរសេរសៀវភៅ ២៥ឆ្នាំ។ នៅក្នុងចម្លើយរបស់គាត់ គាត់ក៏បានលើកឡើងថា គាត់មិនបានមើលឯកសារ សម្ភារៈ សៀវភៅផ្សេងនោះទេ គឺចេញពីការចងចាំខួរក្បាលរបស់គាត់តែម្ដង។ ហើយគាត់បាន -- ក៏លើកឡើងផងដែរនៅទីនេះថា "វៀតណាមបានចូលរួមវគ្គអប់រំនយោបាយ" ដូច្នេះគាត់ទទួលឥទ្ធិពលនេះ។ ហើយគឺវាអាចពាក់ព័ន្ធនឹងបញ្ហាកម្ពុជាក្រោមផងដែរ។ ដូច្នេះ យើងត្រូវតែមានសិទ្ធិជជីកសួរថា វគ្គអប់រំដុសខាត់នយោបាយ នោះគឺមានន័យយ៉ាងម៉េចដែរ? ២០ឆ្នាំ -- ២៥ឆ្នាំក្រោយមកទើបគាត់ចាប់ផ្ដើមសរសេរសៀវភៅ។ ចំពោះការជំទាស់របស់សហព្រះរាជអាជ្ញាថា យើងមិនអាចសួរក្រៅវិសាលភាពយុត្តាធិការនោះទេនោះ គឺថានៅថ្ងៃទី០៦ ខែសីហា ២០១២ គឺមានការស្នើសុំឱ្យលើកឡើងអំពីហេតុការណ៍នៅក្រៅ នៅបន្ទាប់ពីឆ្នាំ១៩៧៩ ហើយអង្គជំនុំជម្រះនៅពេលនោះមានភាពបត់បែន ហើយអនុញ្ញាតឱ្យភាគីលើកឡើងអង្គហេតុ សួរអំពីអង្គហេតុដែលវាក្រៅវង្វង់ឆ្នាំ៧៥ និង៧៩។ ដូច្នេះហើយយើងគួរតែមានសិទ្ធិសួរអំពីប្រភពនៃចំណេះដឹងរបស់សាក្សីនេះ នៅពេលដែលខ្លួនគាត់សរសេរសៀវភៅផងដែរ។ សូមអរគុណលោកប្រធាន។

[១៤:៣៤:៥៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំក្រោកឈរឡើងនេះ ដោយសារតែឃើញមានការសន្និដ្ឋានបន្ថែម លើកឡើងដោយមេធាវីការពារក្តី។ ប្រសិនបើមានមូលដ្ឋានផ្លូវច្បាប់នោះ ប្រសិនបើមានមូលដ្ឋានផ្លូវច្បាប់ខ្ញុំសូមបញ្ជាក់ថា មានមូលដ្ឋានផ្លូវច្បាប់ក្នុងការសួរទៅកាន់សាក្សី អំពីភាពលម្អៀងក្នុងការផ្តល់ភស្តុតាងនោះ ថាតើមានការគំរាមកំហែងទៅដល់គាត់ដែរឬទេ? ហើយអ្វីដែលលើកឡើងនោះ គឺមានប៉ះពាល់ទៅដល់ការសរសេរសៀវភៅរបស់គាត់ដែរឬទេ? ការចោទប្រកាន់មិនត្រឹមត្រូវអំពីគោលនយោបាយរបស់វៀតណាម និងចិន នៅក្នុងឆ្នាំ១៩៨០ ថាមានឥទ្ធិពលនោះគឺ យើងដឹងហើយថា សាក្សីនេះគឺបានគាត់ច្រានចោលអំពីការបណ្តុះបណ្តាលនយោបាយទៅដល់គាត់។ ប្រសិនបើមិនមានមូលដ្ឋាននោះគឺថាការលើកឡើងនេះ ដូចជាគ្មានមូលដ្ឋាននោះទេ។ យើងដឹងហើយថា ក្រុមមេធាវីការពារក្តីនោះគឺមានសិទ្ធិក្នុងការការពារដោយស្របច្បាប់ ក៏ប៉ុន្តែមេធាវីមិនអាចយកវេទិកានេះមកធ្វើការសួរ អំពីបញ្ហាហ្នឹងនោះទេប្រសិនបើមានមូលដ្ឋានត្រឹមត្រូវតាមផ្លូវច្បាប់យើងមិនជំទាស់នោះទេ។ ហើយគឺមិនអាចដូចដែលមេធាវីការពារក្តីថា មានរដ្ឋាភិបាលមួយចំនួនបានលើកឡើងគោលនយោបាយរបស់ខ្លួន មានឥទ្ធិ-ពលទៅលើបញ្ហាទាំងអស់នេះ។ ការលើកឡើងដូច្នេះ គឺមិនមែនជាមូលដ្ឋានផ្លូវច្បាប់លេចចេញពីភស្តុតាងនោះទេ តាមរយៈការស្តាប់សាក្សីរូបនេះ រយៈពេល១ថ្ងៃរួចមកហើយនោះទេ។ ដូច្នេះហើយសូមឱ្យអង្គជំនុំជម្រះគួរតែទទួលយកការជំទាស់របស់ខ្ញុំ ច្រានចោលអ្វីដែលបានលើកឡើងនេះ។

[១៤:៣៦:៤២]

**លោក ហ្សាស្តេី ប៉ោ៖**

សូមអនុញ្ញាតពីលោកប្រធាន ខ្ញុំឆ្លើយតបអ្វីដែលសហព្រះរាជអាជ្ញាឆ្លើយទៅលោក កាណាវាស ដោយខ្លីៗសិន។ យើងសូមលើកឡើងថា យើងមានមូលដ្ឋានដោយសារតែសាក្សីបានលើកឡើងថា គាត់បានចូលរួមក្នុងវគ្គនយោបាយ ហើយវគ្គអប់រំនោះគឺវគ្គអប់រំនយោបាយតែម្តង។ ចំណុចទី២ គឺមិនត្រឹមតែសាក្សីនេះប៉ុណ្ណោះនោះទេ យ៉ាងហោចណាស់នៅក្នុងភស្តុតាងនេះ គឺយើងត្រូវតែសួរថាតើសាក្សីរូបនេះទទួលឥទ្ធិពលពីវគ្គអប់រំនយោបាយនេះដែរឬទេ? ហើយយើងដឹងហើយថា តើមានការបណ្តុះ

បណ្តាលពីវៀតណាម ដល់ជនជាតិកម្ពុជាដែរឬទេ? គាត់សរសេរនៅក្នុងសៀវភៅរបស់គាត់ថា មានមន្ត្រីបីនាក់ទៅវៀតណាមទទួលវគ្គបណ្តុះបណ្តាលនេះ។ យើងមិនមែនលើកចំណុចនេះដោយខ្លួនឯងទេ សាក្សីគាត់ឆ្លើយតាមរយៈបទពិសោធន៍របស់គាត់។ ដូច្នេះហើយថា ខ្ញុំចង់ដែលសួរថា វគ្គនយោបាយ វគ្គអប់រំនៅវៀតណាមនោះគឺវាពាក់ព័ន្ធនឹងអ្វីខ្លះ? វាមានអ្វីខ្លះ? ហើយឲ្យគាត់ជួយតែពន្យល់តែប៉ុណ្ណោះ តើសមាសភាព -- សមាសធាតុដែលលើកឡើងនៅក្នុងវគ្គនយោបាយនោះ គឺគេរៀបរាប់លើកឡើងអ្វីខ្លះតែប៉ុណ្ណោះ។

[១៤:៣៨:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៤១:៤៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ស៊ីវៀ ខាតវ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចសួរសំណួរមួយចំនួនដោយផ្ទាល់តែម្តងទៅកាន់សាក្សីរូបនេះ។

លោកមេធាវីអាចអង្គុយចុះបានក្នុងពេលដែលយើងខ្ញុំសួរទៅកាន់សាក្សីរូបនេះ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

**ស៖** អង្គចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង សូមសួរឲ្យលោកបញ្ជាក់ថាតើលោកមានប្រើប្រាស់ពាក្យថា “វគ្គដុសខាត់លាងខួរក្បាលនយោបាយនេះដែរឬទេ”។ នៅក្នុងសៀវភៅរបស់លោក?

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ខ្ញុំសរសេរចុងក្រោយនេះ គឺនៅក្នុង អវសានកថា ឬមួយអេពីឡូ គឺអ្វីដែលកើតឡើងក្រោយ ៧៩ បាទ។ ខ្ញុំសរសេរ -- ខ្ញុំសូមមើលសិនបាទ សូម -- ខ្ញុំភ្លេចពាក្យ -- ខ្ញុំ --។

បាទ នៅឆ្នាំ-- នៅឆ្នាំ១៩៧៩ គឺខ្ញុំបានត្រូវចាត់តាំងឲ្យទៅរៀនវគ្គនយោបាយ៦ខែ ជាមួយមន្ត្រីនៅភ្នំពេញ និងនៅខេត្តដទៃទៀតបាទ។ ជាវគ្គរៀនសូត្រនយោបាយបាទ នៅ ធូឡឹក បាទ។ ហើយក្នុងសៀវភៅនេះខ្ញុំបានសរសេរជា -- ចំពោះខ្ញុំ ខ្ញុំសរសេរថាជាវគ្គលាងខួរក្បាលមែនបាទ។ ប៉ុន្តែវគ្គនយោ-

បាយនេះមិនបានមានឥទ្ធិពលអ្វីលើខ្ញុំដូចលោក អារ៉ូកា គឺលោកខាងភាគីមានប្រសាសន៍អី គឺគ្មានឥទ្ធិពលអ្វីចំពោះខ្ញុំទេ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៌៖**

សូមអរគុណ។ នេះគឺជាសំណួរដែលខ្ញុំចង់ -- ចំណុចដែលខ្ញុំចង់សួរសំណួរទី២។ តើលោកគិតថា លោកជឿថាមានឥទ្ធិពលអ្វីខ្លះនៅក្នុងវគ្គអប់រំនយោបាយនោះចំពោះលោក តែលោកបានឆ្លើយមករួចមកហើយថា គ្មានទេ។ ដូច្នេះតើលោកចៅក្រមផ្សេងទៀតចង់សួរមន្ថែមដែរឬទេ? ខ្ញុំគិតថាអង្គចៅក្រម គឺឯកភាពថា សំណួរទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងវគ្គអប់រំសិក្សានយោបាយនេះ គឺថាមិនពាក់ព័ន្ធទៅនឹងអង្គហេតុដែលយើងចាប់អារម្មណ៍ ឬក៏ចង់ស្តាប់នៅក្នុងសំណុំរឿង០០២/០១នោះទេ។

សូមអរគុណច្រើនលោកប្រធាន។

[១៤:៤៥:១០]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ១៥នាទី ចាប់ពីនេះទៅរហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាកសាក្សី និង អ្នកជំនាញ ដល់សាក្សីក្នុងអំឡុងពេលឈប់សម្រាក នឹងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោយឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៥ នាទី ដល់ម៉ោង ១៥:០៥ នាទី)*

[១៥:០៥:៣០]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី នួន ជា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ មុនពេលឈប់សម្រាក យើងបានជជែកគ្នាអំពីវគ្គដុះលាងខាត់ខួរក្បាលនយោបាយនេះ។ អង្គជំនុំជម្រះសាលាដំបូង គឺមិនចង់ឲ្យសួរទៅលើខ្លឹមសារនៃវគ្គសិក្សាដុះខាត់ខួរក្បាលនេះទេ ដូច្នេះ ខ្ញុំនឹងគោរពតាមហ្នឹង។ ជំហររបស់ក្រុមមេធាវីការពារក្តីនោះ គឺថាទោះបីជាសាក្សីរូបនេះ មិនត្រូវបានគេដុះខាត់ខួរក្បាលក៏ដោយ គឺវានៅតែពាក់ព័ន្ធក្នុងការជជីកសួរអំពីប្រភពនៃការដឹងរបស់សាក្សីរូបនេះ ថាតើការបណ្តុះបណ្តាលដុះខាត់ខួរក្បាលនោះ ធ្វើឡើងដោយ--

**ប្រធានអង្គជំនុំ៖**

លោក -- អង្គជំនុំជម្រះសម្រេចរួចហើយ។ លោកដូចយល់ព្រមតាមការសម្រេចរបស់អង្គជំនុំជម្រះរួចហើយ។ បន្តប្រធានបទថ្មីផ្សេងទៀត ប្រសិនបើលោកនៅមានសំណួរដែរសួរ។

[១៥:០៧:៣៣]

**លោក ហ្សាស្តើ ប៉ោ៖**

ខ្ញុំយល់លោកប្រធាន។ ខ្ញុំគ្រាន់តែបញ្ជាក់ថា យើងមិនឯកភាពទៅនឹងសេចក្តីសម្រេចនេះ។

**ប្រធានអង្គជំនុំ៖**

បើយល់ហើយ សូមអញ្ជើញទៅទៀត! រឿងឯកភាព មិនឯកភាពជារឿងរបស់លោក។ ប៉ុន្តែសួរសំណួរតទៅទៀត។ ក្រែងលោមានពេលវេលាសម្រាប់មេធាវីការពារក្តីលោក ខៀវ សំផន។

**លោក ហ្សាស្តើ ប៉ោ៖**

ខ្ញុំនឹងសួរឲ្យបានប្រញាប់ទៅលើចំណុចទាំងអស់នេះ គឺថាខ្ញុំមិនសួរទៅលើខ្លឹមសារនៃវគ្គសិក្សានយោបាយនោះទេ ក៏ប៉ុន្តែខ្ញុំសូមសួរឲ្យសាក្សីបញ្ជាក់ថា តើសាក្សីបានសរសេរនៅក្នុងសៀវភៅរបស់គាត់នេះ គឺថាវគ្គសិក្សានយោបាយនោះ គឺថាមានរយៈពេល៦ខែ។ សាក្សីបានសរសេរនៅត្រង់ទំព័រ 00678934 ជាភាសាខ្មែរ។ គាត់សរសេរថា "ក្រោយពីមក ពីវគ្គបណ្តុះបណ្តាលរយៈពេល៦ខែ គឺគាត់បានទៅចូលនៅទីនោះ វគ្គអប់រំនយោបាយនោះ៦ខែ"។ ហើយខ្ញុំចង់សួរបញ្ជាក់ចំណុចនេះទៅ កាន់សាក្សី។ លេខ ERN ជាភាសាអង់គ្លេសគឺ 00369814, ខ្មែរគឺ 00678934។

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន គឺខ្ញុំចង់សុំសួរ សួរអំពីរយៈពេលវគ្គអប់រំសិក្សា

នយោបាយក្នុងឆ្នាំ១៩៨៦នេះ ធ្វើឡើងក្នុងរយៈពេលប៉ុន្មានដែរ។ ខ្ញុំមិនសួរអ្វីក្រៅពីហ្នឹងទេ គ្រាន់តែសុំសួររយៈពេលវគ្គបណ្តុះបណ្តាលនោះតែប៉ុណ្ណោះ។ តើអនុញ្ញាតទេលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

មិនអនុញ្ញាតទេ! សាក្សីឆ្លើយរួចហើយ រយៈពេល៦ខែ។ មើលប្រតិចារឹកឡើងវិញ។

[១៥:០៩:៥៣]

**លោក ហ្វាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនសួរលើខ្លឹមសារអំពីវគ្គដុសខាត់ខួរក្បាលនោះទេ ក៏ប៉ុន្តែខ្ញុំគ្រាន់តែសួរគាត់ ថាតើក្នុងវគ្គដុសខាត់ខួរក្បាលនោះគឺបានលើកឡើងអ្វីខ្លះ ខ្លឹមសារសំខាន់ដែលក្នុងនោះមានអ្នកទៅសិក្សានោះ បីរូប នៅក្នុងសៀវភៅរបស់គាត់ គឺបានសរសេររៀបរាប់ទៅលើចំណុចនេះ។ ហើយក៏បានលើកឡើងអំពីខ្លឹមសារនៃវគ្គដុសខាត់ខួរក្បាលនោះ គឺខ្ញុំដឹងថាអង្គជំនុំជម្រះមិនចាប់អារម្មណ៍ចង់ស្តាប់ទេអំពី តើនៅក្នុងវគ្គនយោបាយដុសខាត់ខួរក្បាលនោះគេលើកឡើងអ្វីខ្លះ។ ហើយក៏ប៉ុន្តែខ្ញុំគ្រាន់តែសួរសាក្សី បើសិនសាក្សីមិនដឹងក៏មិនជាថ្វីដែរអំពីការដុសខាត់ខួរក្បាលនៅវៀតណាមនោះ តើគេលើកឡើងអ្វីខ្លះខ្លឹមសារសំខាន់។

**ប្រធានអង្គជំនុំ៖**

ពាក់ព័ន្ធនឹងបញ្ហានុងគឺក្រៅវិសាលភាពនៃអង្គហេតុដែលអង្គជំនុំជម្រះកំណត់ឲ្យធ្វើសវនាការ។ រឿងលោកមិនសុខចិត្តជារឿងសិទ្ធិរបស់លោក ប៉ុន្តែអង្គជំនុំជម្រះបានសម្រេចបញ្ហានេះរួចហើយ។ យើងមិនអនុញ្ញាតឲ្យលោកបន្តលើបញ្ហាដដែលនេះទេ សូមលើកពាក់ព័ន្ធជាមួយនឹងប្រធានបទថ្មីផ្សេងទៀត ប្រសិនបើលោកនៅមានសំណួរ។ ហើយមិនប៉ះពាល់ទៅលើពេលវេលាដែលអង្គជំនុំជម្រះចែកឲ្យទៅក្រុមមេធាវី ពីរក្រុមផ្សេងទៀតនោះ។

[១៥:១១:៥១]

**លោក ហ្វាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបន្តទៅមុខទៀត។ ខ្ញុំនឹងឈប់សួរអំពីវគ្គសិក្សានយោបាយនេះ ប៉ុន្តែខ្ញុំសូមចូលសួរទៅកាន់ប្រធានបទផ្សេង។

**សួរដោយលោក ហ្វាស្តើ ប៉ោ៖**

**ស៖** លោកសាក្សី លោកបានសរសេរថានៅពេលដែលវៀតណាមរំដោះបាត់ដំបងនោះគេចែក

អង្ករឲ្យ ដូច្នេះហើយគឺថាគេ -- ខាងទាហាន ខាងវៀតណាមនោះគឺថាមានការចែកអង្ករ។ ហើយខ្ញុំនឹងផ្តល់លេខយោងក្នុងពេលបន្តិចទៀតនេះ។ មន្ត្រីបីរូបដែលត្រូវបានដុសខាត់ខួរក្បាលនោះគឺៗបានប្រកាសក្នុងពេលប្រជុំមួយក្រោយពីការដួលរលំរបស់ខ្មែរក្រហម។ អ្នកទាំងបីនោះបានលើកឡើងថា "រដ្ឋាភិបាលរបស់យើងមិនអនុញ្ញាតឲ្យគណៈកម្មការកាកបាទក្រហមអន្តរជាតិ ឬក៏អង្គការផ្សេងនោះធ្វើការជួយប្រជាជននៅតាមព្រំដែនថៃកម្ពុជានោះទេ"។ ERN ជាភាសាអង់គ្លេសគឺ 00369791, ខ្មែរគឺ 00678964, មួយទៀតគឺ 00369808, ខ្មែរគឺ 00678927។

[១៥:១៣:០៧]

នៅពេលនោះគឺលោករស់នៅក្នុងកន្លែងនោះ ហើយលោកជាគ្រូពេទ្យ។ ហើយតើលោកដឹងទេ គេមិនអនុញ្ញាតឲ្យកាកបាទក្រហមអន្តរជាតិ រួមទាំងអង្គការអន្តរជាតិដទៃទៀតជំនួយដល់ប្រជាជនប្រជារាស្ត្រខ្មែរតាមព្រំដែនថៃ ដែលមិនអាចធ្វើដំណើរឆ្លងកាត់មកចូលព្រំដែនកម្ពុជា។ តើលោកដឹងទេចំណុចហ្នឹង?

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ចំណុចនេះ ខ្ញុំដឹងព្រោះៗមន្ត្រីខេត្តបាននិយាយថា "បើអង្គការអន្តរជាតិចង់ជួយខ្មែរ សូមឲ្យទៅជួយតាមរយៈភ្នំពេញ កុំឲ្យមកជួយតាមព្រំដែនដូច្នេះបាទ"។ គេនិយាយអ៊ីចឹងបាទ។

**ស៖** តើមានលទ្ធផលអ្វីកើតឡើង តើលោកមានដឹងថាមានក្រុមណាមួយឆ្លងទៅព្រំដែនថៃដែរឬទេ ដើម្បីជួយប្រជាជននោះក្រោយការដួលរលំរបស់ខ្មែរក្រហមនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ វាក្រៅឆ្ងាយណាស់ពីវិសាលភាពនៃអង្គហេតុដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការសម្រាប់សំណុំរឿង០០២/០១។ បាទ សំណួរនេះមិនពាក់ព័ន្ធទេ។

[១៥:១៤:៤០]

**លោក ហ្សាស្តេី ប៉ោះ**

សូមអរគុណលោកប្រធាន។ ខ្ញុំដើម្បីប្រតិចារឹកលើកឡើងហេតុផលចំនួនពីរថា ហេតុអ្វីបានជាពាក់ព័ន្ធ? ការស្លាប់ដោយសារខ្មែរក្រហមនោះ ក៏វាអាចពាក់ព័ន្ធទៅនឹងការស្លាប់ ដែលថាអាចបណ្តាលមកពីវៀតណាម មិនអនុញ្ញាតឲ្យកាកបាទក្រហមអន្តរជាតិ ឬអង្គការអន្តរជាតិ មិនឲ្យទៅផ្តល់ជំនួយដល់ប្រជាជនខ្មែរ។ ដូច្នេះ នេះគឺជាភស្តុតាងដោះបន្ទុក--

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រគល់វេទិកាជូនទៅលោក ដើម្បីសួរសំណួរសារធាតុពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការ ហើយនិងលទ្ធភាពនៃការយល់ដឹង ការដឹង ការជួបប្រទះនិងបទពិសោធន៍របស់សាក្សីដោយផ្ទាល់នៅក្នុងយុត្តាធិការដែលអង្គជំនុំជម្រះកំណត់សម្រាប់ធ្វើសវនាការ។

[១៥:១៦:០៥]

**លោក ហ្សាស្តេី ប៉ោ៖**

លោកប្រធាន ប្រសិនបើអត់ពាក់ព័ន្ធទេ គឺថាខ្ញុំបន្តទៅមុខទៀត ប្រសិនសំណួរនេះអត់ពាក់ព័ន្ធ។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** លោកបានសរសេរនៅក្នុងសៀវភៅរបស់លោក លោកសាក្សីគឺលេខ ERN 00369793 ត្រង់ចំណុចហ្នឹងលោកបានសរសេរនៅក្នុងសៀវភៅរបស់លោក ហើយខ្មែរគឺ 00 -- គឺសៀវភៅនេះត្រង់លេខ ERN ជាភាសាខ្មែរគឺ 00678907, ហើយ ERN មួយទៀតគឺ 00678917, ហើយនិងមួយទៀតគឺ 00369793។ ហើយលោកបានលើកឡើងក្នុងនោះថា "មានការបិទនៅទីរួមខេត្តបាត់ដំបងកន្លែងផ្សេងៗមានការបិទទ្វារ។ ដូច្នេះហើយគឺថា ប្រជាជននោះមិនអាចទទួលបាននូវការជំនួយ"។ តើលោកមានបានដឹងទេថា -- មានដឹងហេតុផលអ្វី បានជាវៀតណាមគេបិទខេត្តបាត់ដំបង ហើយប្រជាជននោះមានការពិបាកក្នុងការទទួលបាននូវស្រូវអង្ករនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ! សំណួរនេះមិនពាក់ព័ន្ធទេ ក្រៅវិសាលភាពដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការហើយ។ ទំនងជាមេធាវីអស់សំណួរហើយតាមមើល៍ រកសំណួរសារធាតុដែលមានការពាក់ព័ន្ធនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ឲ្យធ្វើសវនាការលែងបានហើយ។

[១៥:១៧:៥៥]

**លោក ហ្សាស្តេី ប៉ោ៖**

លោកប្រធាន ខ្ញុំសូមធ្វើសំណើ។ សូមសំណើដោយគោរព ឲ្យខ្ញុំនេះ ផ្តល់ហេតុផលថាតើហេតុអ្វីបានសំណួរនេះ វាពាក់ព័ន្ធ។ ខ្ញុំសូម--

**ប្រធានអង្គជំនុំ៖**

យើងសម្រេចរួចហើយ។ យើងអត់អនុញ្ញាតទេណា។ មិនពាក់ព័ន្ធទេ។

**លោក ហ្សាស្តើ ប៉ោ៖**

ខ្ញុំគិតថា ហេតុផលដែលបាន ដែលខ្ញុំចង់លើកឡើងនេះ វាពាក់ព័ន្ធទៅនឹងសំណួរទាំងឡាយដែលវាជាប់ទាក់ទងនឹងសំណុំរឿង០០២/០១។

**ប្រធានអង្គជំនុំ៖**

មិនពាក់ព័ន្ធទេ យើងបានសម្រេចរួចហើយ។ លោកអាចតាំងសំណួរថ្មីផ្សេងទៀត ប្រសិនបើនៅសំណួរ។

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** សូមអរគុណ។ នៅក្នុងរបាយការណ៍មួយចំនួនដែលយើងបានយកមកជជែកគ្នាខាងដើម លេខយោងគឺខ្ញុំបានផ្តល់ជូនរួចមកហើយ នៅក្នុងនោះគឺ ឃើញមានបញ្ជីវគ្គអប់រំ វគ្គសិក្សាមួយចំនួនដែលបានធ្វើឡើងដោយចៀសមិនរួច។ វគ្គសិក្សាចំនួនបី នោះគឺចុះថ្ងៃទី -- ឆ្នាំ១៩៩៣ ទៅដល់ ៩៤ ហើយប្រាំពីរទៀតគឺ ធ្វើឡើងចន្លោះ៩៤ ទៅដល់ឆ្នាំក្រោយៗ។ ដូច្នេះហើយគឺលោកសាក្សី ខ្ញុំនឹងអានអត្ថបទចំណុចមួយចំនួនត្រង់អង់គ្លេស ERN គឺ00369813 និងខ្មែរ 00678932។ ខ្ញុំបានអានត្រង់ផ្នែកដែលលោកបាននិយាយអំពីគម្រោងផែនការ ក៥ នោះចាប់ផ្តើមនៅក្នុងឆ្នាំ៨២ បញ្ចប់ឆ្នាំ១៩៨៩ ហើយលោកនិយាយថាផែនការនេះបញ្ចប់នៅក្នុងឆ្នាំ៩០ ក្រោយពេលដែលវៀតណាមនេះដកចេញ។

**ប្រធានអង្គជំនុំ៖**

បាទ មិនមានការពាក់ព័ន្ធទេ។ លោកមេធាវីរកសំណួរណាដែលមានការពាក់ព័ន្ធទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការ នៅក្នុងសំណុំរឿង០០២/០១។

[១៥:២០:៥៨]

**លោក ហ្សាស្តើ ប៉ោ៖**

លោកប្រធាន គឺខ្ញុំសន្យាថាខ្ញុំព្យាយាមចង់បញ្ជាក់ជូនអង្គជំនុំជម្រះថា--

[១៥:២១:០៧]

**ប្រធានអង្គជំនុំ៖**

មិនពាក់ព័ន្ធទេ យើងបានសម្រេចរួចហើយ។ យើងចង់គ្រប់គ្រងពេលវេលាឲ្យមានប្រសិទ្ធភាព ដើម្បីឲ្យដំណើរការមានប្រសិទ្ធភាព ហើយនិងឆាប់រហ័ស។

**លោក ហ្សាស្តើ ប៉ោះ**

សូមអរគុណ។ ខ្ញុំនឹងបន្តទៅមុខក៏ប៉ុន្តែខ្ញុំសូមពន្យល់ថា របាយការណ៍នេះចុះក្រោយឆ្នាំ១៩៨៩ ដែលក្នុងនោះ អាចមានការស្លាប់មនុស្សនៅក្នុងគម្រោងផែនការ ក៥--

**ប្រធានអង្គជំនុំ៖**

ក្រោយឆ្នាំ៧០ -- ក្រោយដំណាក់កាលជម្លៀសលើកទី២ គឺក្រៅអង្គហេតុហើយ។ ក្រៅអង្គហេតុនៃការកំណត់ឲ្យធ្វើសវនាការហើយ។ ជម្លៀសទី២ អតិបរមាគឺ នៅក្នុងឆ្នាំ៧៧ទេ។ ៧៥,៧៦, និងយ៉ាងយូរបំផុតដើមឆ្នាំ៧៧។

**លោក ហ្សាស្តើ ប៉ោះ**

លោកប្រធាន សំណួរនេះគឺពាក់ព័ន្ធទៅនឹងរបាយការណ៍របស់អ្នកជំនាញដែលសហព្រះរាជអាជ្ញាយកមកធ្វើជាមូលដ្ឋាន។ ដូច្នេះហើយយើងគ្រាន់តែសួរបញ្ជាក់ទៅលើភស្តុតាងរបស់សាក្សីនេះដើម្បីធ្វើការតេស្ត ធ្វើតេស្តទៅលើភស្តុតាង ដែលសហព្រះរាជអាជ្ញានោះយកមកធ្វើមូលដ្ឋានផងដែរ។ យើងរកភស្តុតាងដោះបន្ទុកតែប៉ុណ្ណោះ។ ខ្ញុំចង់ឲ្យសាក្សីរូបនេះបញ្ជាក់ថា ផែនការ ក៥ គឺបានកើតឡើងរហូតមកដល់ឆ្នាំ១៩៨៩ គឺសាមញ្ញតែប៉ុណ្ណោះ។ បន្ទាប់មកគឺ--

[១៥:២២:៤៧]

**ប្រធានអង្គជំនុំ៖**

យើងមិនអនុញ្ញាតឲ្យទេ ហើយលែងឲ្យ ឈប់ឲ្យលោកធ្វើអត្ថាធិប្បាយហើយ ប្រសិនបើលោកនៅតែបន្តនិយាយ យើងបញ្ឈប់ឲ្យនិយាយហើយ។ យើងឲ្យពេលវេលាលោកសម្រាប់តាំងសំណួរជាក់លាក់។ សាក្សីនេះមិនមែនយកសាក្សីមកធ្វើតេស្តទេ។ សាក្សីគឺសួរសារធាតុជាក់លាក់ដែលគាត់បានដឹងបានឮ បានឃើញ បានចងចាំ មានបទពិសោធន៍ផ្ទាល់ ហើយនិងធ្វើការសង្កេតដោយផ្ទាល់ ពាក់ព័ន្ធព្រឹត្តិហេតុទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលសួរ ហើយទាក់ទងទៅនឹងអង្គហេតុដែលចោទប្រកាន់លើជនជាប់ចោទ។

**លោក ហ្សាស្តើ ប៉ោះ**

ចំណុចហ្នឹងហើយដែលខ្ញុំចង់សួរសុំឲ្យសាក្សីបញ្ជាក់អំពីផែនការ ក៥ ដែលបញ្ចប់នៅក្នុងឆ្នាំ១៩៨៩--

**ប្រធានអង្គជំនុំ៖**

យើងមិនឲ្យសួរទេ។ អង្គុយចុះ! យើងយល់ថាលោកអស់សំណួរសារធាតុហើយ។

[១៥:២៤:០៣]

បានហើយ លោកអស់ពេលហើយក្នុងការសួរសាក្សីរូបនេះ។

អស់ហើយ លោកអស់ពេលហើយ។

អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការសួរដេញដោលសាក្សី។ សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព ហើយភាគីទាំងអស់។ លោក ហ៊ុន ឈុនលី ជាទីគោរព។ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ។ ខ្ញុំជាសហមេធាវិការពារក្តីលោក ខៀវ សំផន ខ្ញុំនឹងចាប់ផ្តើមសួរលោកតំណាងឲ្យសហភាតារបស់ខ្ញុំ។ សំណួរខ្ញុំខ្លីៗនោះទេ ហើយសហភាតារបស់ខ្ញុំលោក គង់ សំអុន និងសួរបន្តពីខ្ញុំទៅទៀត។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកបាននិយាយជាមួយសហព្រះរាជអាជ្ញាជាតិថា នៅពេលដែលលោកនៅស្គាល់លោកស្គាល់លោក ខៀវ សំផន ខ្ញុំមិនយល់ចម្លើយរបស់លោកច្បាស់ទេ។ អ៊ីចឹងហើយនេះ ជាកម្មវត្ថុនៃសំណួររបស់ខ្ញុំ។ ខ្ញុំចង់ដឹងថា លោកស្គាល់គាត់ដោយផ្ទាល់តែម្តង ឬក៏លោកគ្រាន់តែឮគេនិយាយអំពីគាត់ទេ នៅមុនឆ្នាំ១៩៧៥។ តើលោកអាចបញ្ជាក់បំភ្លឺបន្តិចបានឬទេ?

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់បន្ថែមពីអ្វីដែលខ្ញុំបាននិយាយរួចហើយបាទ។ ខ្ញុំស្គាល់លោក ខៀវ សំផន ក្នុងឋានៈគាត់ជាបញ្ញវន្តមួយរូប ជាប្រធានកាសែត ឡបសែរវ៉ាទ័រ ហើយនិងជាមន្ត្រីមួយដែលគេទទួលស្គាល់ថា ជាមន្ត្រីស្អាតស្អំ។

**ស៖** សូមអរគុណលោកសាក្សី។ សំណួរខ្ញុំហ្នឹង ខ្ញុំចង់ដឹងថាតើលោកគ្រាន់តែស្គាល់ឈ្មោះគាត់ទេ ឬក៏លោកស្គាល់គាត់ដោយផ្ទាល់តែម្តង?

[១៥:២៧:០៥]

**ឆ៖** គ្រាន់តែស្គាល់គាត់ ធ្លាប់ឃើញគាត់ ប៉ុន្តែខ្ញុំមិនដែលបាននិយាយជាមួយគាត់ទេបាទ។ បាន

ស្គាល់គាត់អ៊ីចឹង។

**ស៖** សូមអរគុណដែលបាលឆ្លើយបំភ្លឺ។ លោកបានលើកឡើងអំពីកាសែត ឡុបសែវ៉ាទ័រ ដែល លោក ខៀវ សំផន ជាប្រធាន។ ខ្ញុំចង់ដឹងថា តើលោកធ្លាប់បានអានកាសែត ឡុបសែវ៉ាទ័រ នេះដែរឬទេ នៅខេត្តបាត់ដំបង?

**ឆ៖** ពេលដែលគាត់សរសេរកាសែត ឡុបសែវ៉ាទ័រ ពេលនោះខ្ញុំនៅភ្នំពេញបាទ។ មិនមែននៅ បាត់ដំបងទេ។ ខ្ញុំនៅភ្នំពេញ ខ្ញុំតែងអាន ខ្ញុំអានកាសែតគាត់មិនទៀងទាត់ទេ ប៉ុន្តែជាៗញឹកញាប់បាទ កាសែតគាត់។

[១៥:២៨:១៦]

**ស៖** ហើយប្រធានបទដែរសរសេរនៅក្នុងកាសែត ឡុបសែវ៉ាទ័រ ហ្នឹងមានអ្វីខ្លះដែរទៅ?

**ឆ៖** ខ្ញុំមិនចាំទេ ប៉ុន្តែគាត់មានសរសេរពីៗផ្នែកនយោបាយ ពីជីវភាពអ្នកក្រីក្រ ដូចជាអ្នកកាន់ សក់អីជាដើមបាទ។ អ៊ីចឹងបាទ សរសេរលក្ខណៈខ្លះជាលក្ខណៈនយោបាយ លក្ខណៈខ្លះជាលក្ខណៈ សាមញ្ញទូទៅបាទ។

**ស៖** បាទ សំណួរចុងក្រោយរបស់ខ្ញុំទាក់ទងទៅនឹងចំណុចនេះ តើលោកអានកាសែតនេះតាម របៀបណាដែរ ជាកាសែតដែលលក់ ជាចំហតែម្តង ឬក៏កាសែតគេចែកចាយតាមផ្លូវសម្ងាត់?

**ឆ៖** បាទ កាសែត ឡុបសែវ៉ាទ័រ ជាកាសែតដែលលក់ជាចំហ ដោយមានការអនុញ្ញាតពីៗរដ្ឋ។

[១៥:២៩:៤៣]

**ស៖** ខ្ញុំសូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមចូលទៅចំណុចមួយទៀត លោកបាននិយាយចំណុចនេះ ជាមួយនិងសហភាតា មេធាវីការពារក្តីលោក នួន ជា។ លោកនិយាយអំពីអង្គការលើ ហើយលោកក៏ បាននិយាយអំពីអង្គការលើនេះ កាលពីម្សិលមិញផងដែរ នៅពេលដែលលោកពន្យល់ថា លោកមិនដឹងថា ពាក្យថា “អង្គការលើ” នេះមានន័យយ៉ាងដូចម្តេចនោះទេ។ អ៊ីចឹងសំណួរខ្ញុំទី១ គឺចង់ដឹងថានៅក្នុងមន្ទីរ ពេទ្យដែលលោកបានធ្វើការនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកទទួលបញ្ជាពីអ្នកណា?

**ឆ៖** អ្នកដែលទទួលបញ្ជា -- ខ្ញុំសូមជម្រាបថាមន្ទីរ ព-២ និងមន្ទីរពេទ្យ ព-១ នៅក្រោមការ គ្រប់គ្រងរបស់អនុប្រធានតំបន់៣។ ដូច្នេះគេទទួលបញ្ជាពីអនុប្រធានតំបន់៣។ ហើយចំពោះនៅក្នុង ការងារបច្ចេកទេសវិញ គឺប្រធានមន្ទីរពេទ្យជាអ្នកបញ្ជាទៅថ្នាក់ក្រោម។ គណៈកម្មការមន្ទីរពេទ្យ ដែល មានប្រធាន អនុប្រធាន ពីរនាក់ហ្នឹងគេអ្នកបញ្ជាទៅថ្នាក់ក្រោមបាទ។

[១៥:៣១:៣៣]

**ស៖** តើលោកអាចផ្ដល់ឈ្មោះអនុលេខាតំបន់នុ៎ង ជូនអង្គតុលាការបានដែរឬទេ?

**ឆ៖** អនុប្រធានតំបន់៣ ដែលគ្រប់គ្រងមន្ទីរពេទ្យ ព-២ និង ព-១ នោះឈ្មោះ មិត្តហឿន។ គាត់ជាប្អូនថ្លៃគណៈភូមិភាគ ឈ្មោះ មូល សម្បត្តិ ហៅ តាកៅ ហៅ រស់ ញឹម។

**ស៖** នៅពេលដែលយើងនិយាយអំពីលេខាភូមិភាគនោះ នៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ តើលោកធ្លាប់មានទំនាក់ទំនងដោយផ្ទាល់ជាមួយគាត់ដែរឬទេ?

**ឆ៖** បាទ នៅ -- គេមិនមែនហៅលេខាភូមិភាគទេ គេហៅប្រធានភូមិភាគ ប្រធានតំបន់ ប្រធានភូមិភាគ អនុប្រធានភូមិភាគ ប្រធានតំបន់ អនុប្រធានតំបន់។ លេខាភូមិភាគ ដូចមិនមានឮសូរឈ្មោះទេបាទ។ ហើយសូមលោកស្រីផ្ដល់សំណួរបន្ថែម ខ្ញុំភ្លេចលោកស្រីសួរបាទ។

[១៥:៣៣:១៧]

**ស៖** សំណួរខ្ញុំអម្បាញ់មិញនោះ ខ្ញុំចង់ដឹងនោះ ឥឡូវខ្ញុំសូមកែពាក្យពេចន៍ហ្នឹងដែលប្រើអម្បាញ់មិញ។ ខ្ញុំចង់ដឹងថា តើលោកធ្លាប់មានទំនាក់ទំនងផ្ទាល់ជាមួយនឹងប្រធានភូមិភាគដែលយើងទើបតែនិយាយអម្បាញ់មិញនេះដែរឬទេនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** ខ្លួនខ្ញុំមិនដែលបានជួបមុខប្រធានភូមិភាគទេ។ ខ្ញុំជួបតែអនុប្រធានតំបន់៣ និងប្រធានតំបន់៤ ឈ្មោះ មិត្តស៊ូ ហ្នឹងឯង គឺកម្មាភិបាលខ្មែរក្រហម ដែលខ្ញុំបានជួប។

**ស៖** សូមអរគុណ។ នៅពេលដែលលោកផ្ដល់ចម្លើយនោះ លោកបាននិយាយថា លោកបានទទួលលិខិតពី មិត្តស៊ូ ដោយមានត្រាគណៈតំបន់៤។ តើជាការត្រឹមត្រូវដែរឬទេ គឺថាលិខិតនេះ គឺជាលិខិតតែមួយគត់ដែលលោកទទួលបានពីតំបន់ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យនៅក្នុងក្របខ័ណ្ឌមុខងាររបស់លោកកាលពីសម័យនោះ?

**ឆ៖** ជាការពិត ខ្ញុំបានទទួលលិខិត មានត្រា ហើយមានឈ្មោះប្រធានតំបន់៤ ឈ្មោះ ខែក ប៉ែន នោះ ឈ្មោះមិត្តស៊ូ។ ហ្នឹងឲ្យទៅធ្វើការនៅមន្ទីរពេទ្យព្រែកហ្លួង ដែលយើងបាននិយាយរួចហើយ។ ហើយបន្ទាប់មក ខ្ញុំបានទទួលលិខិតពីអនុប្រធានតំបន់៣ ឲ្យទៅធ្វើការនៅមន្ទីរពេទ្យឃោធាឈ្មោះ "មន្ទីរពេទ្យព-២" បាទ។

**ស៖** ដូច្នេះបើខ្ញុំមិនច្រឡំទេ គឺថាលោកទទួលបានលិខិតមួយពីតំបន់៤ ហើយមួយទៀតពីតំបន់៣ អ៊ីចឹងមែនទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយ អំមិញអត់ទាន់បានឆ្លើយទេ។

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បាទ អ៊ីចឹងហើយលោកស្រី។

[១៥:៣៦:០០]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** បើអ៊ីចឹង ដើម្បីឲ្យច្បាស់លាស់មែនទែន គឺថាលោកទទួលបញ្ជាពីប្រធានពេទ្យដែលនៅក្នុងពេទ្យទាំងអស់នោះលោកធ្វើការ អ៊ីចឹងមែនទេ? គឺថាក្រៅពីលិខិត២ហ្នឹង ថាលោកទទួលបទបញ្ជាពីប្រធានពេទ្យទាំងអស់នោះ? ហើយទទួលបទបញ្ជានោះដោយផ្ទាល់មាត់ផងដែរ?

**ឆ៖** លិខិតៗបញ្ជានេះ គឺគ្រាន់តែឲ្យខ្ញុំទៅធ្វើការនៅមន្ទីរពេទ្យក្រោមៗគណៈកម្មការដឹកនាំមន្ទីរពេទ្យបាទ។ គណៈកម្មការនោះមានប្រធានម្នាក់ និងអនុប្រធានពីរនាក់។

**ស៖** សូមអរគុណដែលបានបំភ្លឺទាក់ទងលិខិត ប៉ុន្តែសំណួររបស់ខ្ញុំអម្បាញ់មិញនេះគឺខ្ញុំចង់ឲ្យលោកបញ្ជាក់ដល់អង្គជំនុំជម្រះថា ក្រៅពីលិខិតទាំងពីរហ្នឹង ដែលៗតែងតាំងលោកឲ្យធ្វើតាមមន្ទីរពេទ្យនោះគឺថាក្រៅពីលិខិតពីរហ្នឹង គឺថាលោកទទួលបញ្ជាពីប្រធានពេទ្យដែលលោកធ្វើការហ្នឹងដោយផ្ទាល់តែម្តង អ៊ីចឹងមែនទេ លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ ខ្ញុំទទួលបញ្ជាពីប្រធានមន្ទីរពេទ្យ ឬអនុប្រធានមន្ទីរពេទ្យក្នុងការងារបច្ចេកទេស។

**ស៖** សូមអរគុណដែលបានឆ្លើយបំភ្លឺ។ ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយចំណុចថ្មីមួយទៀត គឺប្រជុំនៅខែឧសភា ឆ្នាំ១៩៧៥ ដែលលោកបានលើកឡើងជាមួយសហព្រះរាជអាជ្ញាអន្តរជាតិ។ ហើយកិច្ចប្រជុំនេះបានប្រព្រឹត្តទៅនៅក្នុងវត្តក្លាំងងារ។ ខ្ញុំសូមអាន គឺថា K-D-A-I-N-G N-G-E-A ហើយលោកក៏បានលើកឡើងអំពីសុន្ទរកថា មិត្តស៊ូ នៅក្នុងពេលនោះ។

[១៥:៣៨:៤១]

ខ្ញុំសូមត្រឡប់មកនិយាយអំពីចំណុចពីរនៅពេលនោះ ដែលលោកបានលើកឡើងនៅក្នុងសៀវភៅរបស់លោកផងដែរ គឺថាឯកសារ D313/1.2.8។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបញ្ចាំងទំព័រនេះ ERN ជាភាសាខ្មែរគឺ 00678778, ជាភាសាអង់គ្លេសគឺ 00369696។ តើខ្ញុំអាចបញ្ចាំងវគ្គនេះបានទេ តើលោកសាក្សីមានអត្ថបទនេះទេ។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតបញ្ចាំង។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលមើលទៅជួយបង្ហាញដល់សាក្សី នៅទំព័រដែលមេធាវីសុំបង្ហាញអម្បាញ់មិញនេះ។

[១៥:៤០:០០]

**កញ្ញា អង់តា ហ្គីសសេះ**

ក្រុមខ្ញុំមានបញ្ហាបច្ចេកទេស យើងកំពុងតែដោះស្រាយបញ្ហានេះ ហើយសូមអភ័យទោសលោកប្រធាន ដែលមានការយឺតយ៉ាវ។

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖** លោកសាក្សី តើលោកឃើញអត្ថបទនេះទេ? លោករកកន្លែងទំព័រហ្នឹងឃើញទេ? ខ្ញុំឃើញថា លោកងក់ក្បាល គឺថាឃើញហើយ។ ឥឡូវនេះ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស ពីព្រោះថា ពុំមានជាសំណៅជាភាសាបារាំង។ ហើយខ្ញុំសូមអភ័យទោសអំពីសំណាក់អ្នកបកប្រែ ពីព្រោះសំនៀងខ្ញុំអានមិនសូវច្បាស់។ ខ្ញុំសូមរំឭក ERN ជាភាសាអង់គ្លេសគឺ 00369696។ “អ្នកនិយាយគឺឈ្មោះ ខែក ប៉ែន ហៅ មិត្តស៊ូ ដែលជាប្រធានតំបន់៤ ដែលយើងបានឃើញនៅ -- ជួបនៅក្នុងទីរួមខេត្តបាត់ដំបង។ ដូចកម្មាភិបាលខ្មែរក្រហមទូទៅដែរ មិត្តស៊ូ មិនបង្ហាញឈ្មោះនិងឋានៈរបស់គេជូនអង្គប្រជុំសាធារណៈឡើយ”។ បាទ សូមបញ្ចប់ការដកស្រង់។ លោកសាក្សីសំណួរទី១របស់ខ្ញុំ តើលោកដឹងថា មិត្តស៊ូ កាន់តំណែងអីនោះតាមរបៀបណា? ហើយដឹងនោះនៅពេលណាដែរ?

[១៥:៤១:៥២]

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ខ្ញុំមិនដឹងថា មិត្តស៊ូ គាត់ត្រូវតែងតាំងជាប្រធានតំបន់៤ ពីពេលណាមកទេ។ គ្រាន់តែដឹងថា ពេលចូលមកហ្នឹង គឺមានតែមិត្តស៊ូ ទេ នៅពេលដែលខ្មែរក្រហមចូលមក គឺថ្ងៃទី២ គឺមានតែមិត្តស៊ូ មួយទេដែលចេញមុខចេញមាត់ឲ្យប្រជារាស្ត្រឃើញ។ ហើយត្រង់ថាអ្នកណាតែងតាំងគាត់ ឬមួយ

គាត់តែងតាំងពីអង្កាល់ខ្ញុំមិនដឹង ប៉ុន្តែគ្រាន់តែគេនិយាយគ្រប់គ្នាថា គាត់ជាប្រធានតំបន់៤។ ពាក្យតំបន់ហ្នឹងវាជាថ្មីចំពោះយើងទាំងគ្នាហើយ ពីព្រោះយើងមិនដែលប្រើពាក្យ “តំបន់” ទេបាទ។ ហើយពេលនោះជាថ្មីហើយ ពាក្យ “តំបន់” យើងមិនដែលប្រើពាក្យតំបន់ យើងមានតែភូមិ ឃុំ ស្រុក ខេត្ត។ “តំបន់” អត់មានទេបាទ ប៉ុន្តែគេៗបញ្ចូលពាក្យ “តំបន់”។

**ស៖** ខ្ញុំយល់ចម្លើយរបស់លោក គឺថាមានអ្នកដទៃទៀត ដែលនិយាយប្រាប់លោក អំពីតំណែងរបស់ មិត្តស៊ូ តើលោកអាចប្រាប់ដល់អង្គជំនុំជម្រះ ពីអ្នកដែលប្រាប់លោកថា មិត្តស៊ូ នោះធ្វើអីបានដែរឬទេ?

**ឆ៖** គឺយើងឮតៗគ្នាថា មិត្តស៊ូ ឋានៈរបស់គេ ជាប្រធានតំបន់៤ ប៉ុណ្ណឹងបាទ។

**ស៖** ខ្ញុំយល់ច្បាស់ហើយ លោកសាក្សី អ្វីដែលខ្ញុំចង់ដឹងនោះគឺថា ខ្ញុំចង់បានឈ្មោះមនុស្សមួយចំនួនដែលប្រាប់លោក អំពីតំណែងរបស់ មិត្តស៊ូ នេះ តើលោកអាចបានប្រាប់តុលាការបានទេថាអ្នកណាខ្លះដែលប្រាប់ពីតំណែងគាត់នេះ?

**ឆ៖** ខ្ញុំអត់ដឹងបាទ។ ខ្ញុំអត់ដឹង។

**ស៖** នៅក្នុងសម្រង់ដែលខ្ញុំទើបនឹងអានអំមិញនេះនោះគឺថា ដូចខ្មែរក្រហមផ្សេងដែរ គឺថា មិត្តស៊ូ មិនមកបង្ហាញឈ្មោះ ឬក៏បង្ហាញតំណែងរបស់ខ្លួនទេ។ តើលោក បើតាមបទពិសោធន៍របស់លោកនោះ តើលោកហេតុអីក៏ខ្មែរក្រហមមិនបង្ហាញឈ្មោះ ហើយនិងឋានៈ ឬតំណែងរបស់ខ្លួនដល់ -- ឱ្យគេដឹងជាសាធារណៈនោះ បើតាមបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោកនោះ លោកអាចជម្រាបជូនតុលាការបានទេ?

**ឆ៖** ខ្ញុំទម្លាប់ឃើញថា កម្មាភិបាលខ្មែរក្រហមនៅពេលប្រជុំ គេមិនដែលបង្ហាញអំពីឈ្មោះ ឋានៈរបស់គេទេ។ ខ្ញុំយល់ថានេះជាវប្បធម៌របស់ពួកគេបាទ។

**ស៖** អ៊ីចឹងគឺជាការសន្និដ្ឋានផ្ទាល់ខ្លួនរបស់លោក។ អ៊ីចឹងគ្រាន់តែលោកមិនដឹងពីមូលហេតុច្បាស់លាស់នោះទេ។ តើខ្ញុំត្រូវយល់យ៉ាងដូច្នេះឬ តាមរយៈចម្លើយរបស់លោកអម្បាញ់មិញនេះ?

[១៥:៤៦:១០]

**ឆ៖** បាទ ខ្ញុំសង្កេតឃើញតែអ៊ីចឹង គឺថាគេមិនដែលបង្ហាញឈ្មោះ បង្ហាញតួនាទីរបស់គេ គឺទូទៅអ៊ីចឹងតែម្តង។ បានខ្ញុំហ៊ាននិយាយថាជាវប្បធម៌របស់គេបាទ។

**ស៖** ឥឡូវនេះខ្ញុំសូមចូលទៅនិយាយចំណុចមួយទៀត គឺថាទាក់ទងទៅនឹងកិច្ចប្រជុំនៅខែឧសភា

ឆ្នាំ១៩៧៥ ដែរ ហើយខ្ញុំសូមដកស្រង់ចំណុចមួយ គឺថាទំព័រដែលនេះតែម្តង ដែលចំណុចនេះលោកបានលើកឡើងយ៉ាងលម្អិតអំពីសុន្ទរកថារបស់ មិត្តស៊ូ និងពាក្យស្លោកមួយចំនួនដែលគេនិយាយនៅថ្ងៃនោះ ហើយលោកបាននិយាយដូចតទៅនេះ។ ខ្ញុំសូមប្រាប់ដល់អ្នកបកប្រែ គឺថាខ្ញុំដល់ស្រង់ជាភាសាអង់គ្លេស ហើយមានបញ្ចើពាក្យស្លោកនៅថ្ងៃហ្នឹងៗ គឺថាលោកនិយាយដូចតទៅនេះ "គឺថា មិត្តស៊ូ មិនបាននិយាយពីអ្វីដែល -- គឺមិត្តិស៊ូ មិនបាននិយាយមួយម៉ាត់អំពីសម្តេច នរោត្តម សីហនុ, ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម នោះទេ"។ សំណួរខ្ញុំដូចតទៅនេះ នៅពេលដែលលោកនិយាយថា យើងកត់សម្គាល់ឃើញថា គេមិនបានលើកឡើងពី សីហនុ, ខៀវ សំផន, ហ៊ូ យន់, ឬក៏ ហ៊ូ នឹម។ តើលោកនិយាយ -- លោកចង់សំដៅទៅអ្នកណា? ពាក្យដែលថា "គេ" នេះ? តើគេបាននិយាយអ្វីខ្លះដោយជាក់លាក់តែម្តងនោះ បើសិនៗជាលោកចាំ?

[១៥:៤៨:១៨]

**ឆ៖** អត់ទោស សូមលោកស្រីមានប្រសាសន៍ម្តងទៀតបាទ។

**ស៖** អត់បញ្ហាអ្វីទេ។ ខ្ញុំគ្រឹមតែដកស្រង់ចេញពីសៀវភៅលោកមួយ គឺថាដែលមាន លោកនិយាយថា មានគេ និយាយថាមានពាក្យ ប្រើពាក្យ គេមិនបាននិយាយអំពី សីហនុ, ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម ហើយសំណួរខ្ញុំចង់ដឹងថា នៅពេលដែលលោកនិយាយថា "មានគេចាប់អារម្មណ៍"។ អ៊ីចឹងខ្ញុំចង់ដឹងថា "គេ" នោះសំដៅអ្នកណា? ហើយគេនិយាយអំពីអ្វីដែរនៅថ្ងៃហ្នឹង? ព្រោះពាក្យ "យើង" នៅក្នុងសៀវភៅលោកហ្នឹង ថាសរសេរពាក្យ "យើង" បាទ។ យើង ហ្នឹងជាអ្នកណា? សំដៅទៅអ្នកណា?

**ឆ៖** ខ្ញុំមិនទាន់ឃើញពាក្យ "គេ" ផងលោក ខ្ញុំមិនទាន់ឃើញពាក្យហ្នឹង សូមបញ្ចាំងពាក្យឲ្យឃើញ។ ខ្ញុំអត់ឃើញពាក្យហ្នឹងបាទ។

[១៥:៤៩:៤១]

**ស៖** បាទ ជារឿងធម្មតាទេ ព្រោះថាខ្ញុំអំមិញនេះ ខ្ញុំដកស្រង់ជាភាសាអង់គ្លេស។

**ប្រធានអង្គជំនុំ៖**

អត់ទាន់ អត់ៗបើក -- ចាំក្បាលមីក្រូសិនណា។

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** បាទ ត្រង់ឃ្លាថា "អ្វីដែលយើងចាប់អារម្មណ៍" គឺចង់និយាយថាអ្នកដែលមកស្តាប់ អ្នកមក

ស្តាប់យើងបាទ។ បាទ ចង់និយាយអ៊ីចឹង។ អ្នកដែលមកស្តាប់ មិត្តស្ញ៊ ហ្នឹង ខ្ញុំនិយាយពាក្យ “យើង” បាទ។

**ស៖** អ៊ីចឹងដោយច្បាស់លាស់តែម្តងនោះ គឺថាអ្នកៗមកចូលប្រជុំនោះ កត់សម្គាល់ឃើញថា មិនមាននិយាយពីសីហនុ, ខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់ តើគេឆ្ងល់ -- សាធារណជនអ្នកមកចូលរួមកិច្ចប្រជុំនុ៎ងគាត់ឆ្ងល់យ៉ាងម៉េចដែរ ថានៅពេលដែលអត់មាននិយាយពីឈ្មោះអម្បាញ់មិញទាំងប៉ុន្មាននេះ សីហនុ, ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម នោះ ហើយលោកផ្ទាល់នោះលោកឆ្ងល់យ៉ាងម៉េចដែរ?

**ឆ៖** អ្នកដែលស្តាប់ទាំងអស់នោះ គឺថាមិនដែល មិនឮ មិត្តស្ញ៊ និយាយពីនាក់ទាំងប៉ុន្មានដែលលោកស្រីរៀបរាប់អំមិញទេ បាទ។ គឺថាយើងគ្រាន់តែមានការងឿងឆ្ងល់ ប៉ុន្តែយើងពុំមាន ពុំហ៊ានជជែក ពុំហ៊ានសាកសួរទេ។

[១៥:៥១:៣៣]

**ស៖** បើសិនយើងខ្ញុំយល់មិនខុសទេ នៅក្នុងកថាខណ្ឌនេះ នៅពេលដែលលោកនិយាយថា “យើងចាប់អារម្មណ៍ខ្លាំង” គឺថាមានតែលោកទេដែលចាប់អាម្មណ៍ត្រង់ចំណុចនេះ ឬក៏លោកអាចរកបាននិយាយជាមួយអ្នកដែលចូលរួមកិច្ចប្រជុំហ្នឹងផ្សេងទៀតដែរ ពីចំណាប់អារម្មណ៍នេះ?

**ឆ៖** ពាក្យ “យើង” នេះមិនមែនមានតែខ្ញុំទេ គឺចង់សំដៅទៅអ្នកស្តាប់ទាំងអស់ “យើង” នេះបាទ។ អ្វីដែលយើងចាប់អារម្មណ៍ខ្លាំង គឺមិត្តស្ញ៊ មិនបាននិយាយមួយម៉ាត់ពីសម្តេច យើងគឺអ្នកស្តាប់ទាំងអស់គ្នា។

**ស៖** បាទ ខ្ញុំយល់។ ប៉ុន្តែសំណួរខ្ញុំប្រហែលជាមិនច្បាស់ទេ អម្បាញ់មិញ អ៊ីចឹងខ្ញុំសូមបញ្ជាក់ឡើងវិញ។ លោកសាក្សីលោកបានកត់ស្គាល់ឃើញអ៊ីចឹង ចាប់អារម្មណ៍ឃើញអ៊ីចឹង ហើយអ្នកផ្សេងទៀតហ្នឹងគាត់ក៏មានចំណាប់អារម្មណ៍អ៊ីចឹងដែរ។ តើលោកមានបាននិយាយអំពីការដែលថា ឈ្មោះទាំងអស់នុ៎ងមិនបានលើកឡើង ខ្ញុំចង់ដឹងថា តើអ្នកផ្សេងនោះមានបានចាប់អារម្មណ៍ត្រង់ចំណុចហ្នឹងដូចលោកដែរឬទេ?

[១៥:៥២:៥៣]

**ឆ៖** ខ្ញុំយល់ថាគេមានអារម្មណ៍ដូចគ្នា ប៉ុន្តែគឺថាយើងមិនហ៊ានធ្វើការបកស្រាយជាសាធារណៈ មិនហ៊ានសាកសួរគ្នាទៅវិញទៅមកទេ គឺគ្រាន់តែស្តាប់ប៉ុណ្ណោះឯង។ ការងឿងឆ្ងល់ទុកក្នុងខ្លួន។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកសាក្សី ខ្ញុំសូមអរគុណដែលបានឆ្លើយតបនឹងសំណួរទាំងអស់នេះ ហើយខ្ញុំសូមបញ្ចប់ការចោទសួរត្រឹមនេះហើយលោកប្រធាន។ សូមអរគុណច្រើន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ ខ្ញុំសូមបន្តបញ្ចប់បណ្តោយទៅ កុំឲ្យ -- ខ្ញុំព្យាយាមសួរខ្លីៗទេ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមជម្រាបសាក្សី។ ខ្ញុំ គង់ សំអុន ជាមេធាវីរបស់លោក ខៀវ សំផន ហើយខ្ញុំមានសំណួរមួយចំនួនសម្រាប់សួរទៅលោក។ អម្បាញ់មិញនេះសហភាតារបស់ខ្ញុំបានលើកសំណួរពាក់ព័ន្ធទៅនឹងកាសែត ឡូបសេវ៉ាទ័រ ដែលលោកបានអានហើយ។ ខ្ញុំចង់សួរបញ្ជាក់បន្ថែមថា តើកាសែត ឡូបសេវ៉ាទ័រហ្នឹងមានបញ្ចេញទស្សនៈបែបណាខ្លះទាក់ទង -- ជាពិសេសទាក់ទងទៅនឹងទស្សនៈនយោបាយរបស់កាសែតនោះ ជាកាសែតដែលគាំទ្រចលនាកុម្មុយនីស្ត ឬក៏ចលនាសង្គមនិយម ឬក៏ជាកាសែតដែលបង្ហាញពីទិដ្ឋភាពសង្គម?

[១៥:៥៤:៥១]

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** តាមទស្សនៈរបស់ខ្ញុំ កាសែតឡូបសេវ៉ាទ័រ ជាកាសែត គេហៅថា "ឆ្វេងនិយម"។ មិនមែនឆ្វេងហួសហេតុទេ ឆ្វេងនិយម ហើយមានសរសេរច្រើនពីបញ្ហាសង្គម។

**ស៖** បាទ សូមអរគុណ។ សូមលោកជួយបញ្ជាក់ពីពាក្យថា "ឆ្វេងនិយម" ដែលលោកមានប្រសាសន៍អម្បាញ់មិញនេះជូនអង្គជំនុំជម្រះផងបាទ?

**ឆ៖** ឆ្វេងនិយម គឺថាលម្អៀងទៅខាង -- ស្តាំនិយម បើនិយាយស្តាំនិយម គឺថាលម្អៀងទៅខាងលោកសេរី។ ឆ្វេងនិយម គឺថាលម្អៀងទៅខាងលោកកុម្មុយនីស្តបាទ។

[១៥:៥៥:៥២]

**ស៖** បាទ សូមអរគុណ។ តើមានកត្តាអ្វីខ្លះនៅក្នុងទស្សនៈនៃកាសែតនោះដែលអាចបញ្ជាក់អំពីឆ្វេងនិយម ដូចលោកមានប្រសាសន៍អម្បាញ់មិញនេះ?

**ឆ៖** សម្បត្តិមួយចំនួនដែលបញ្ជាក់នូវទស្សនៈរបស់គាត់ -- របស់កាសែតដែលខុសពីកាសែតដទៃទៀតបាទ ប៉ុន្តែខ្ញុំមិនចាំទាំងអស់នូវអត្ថបទកាសែតទាំងអស់នោះទេបាទ។

**ស៖** លោកអាចបញ្ជាក់ពីកត្តាជាក់លាក់ដែលអាចធ្វើឱ្យលោកវិនិច្ឆ័យថា កាសែតឡុបសែវ៉ាទ័រនេះជាកាសែតឆ្វេងនិយមបានទេ?

**ឆ៖** អ្វីដែលខ្ញុំអាចបញ្ជាក់ថាកាសែតនេះជាកាសែតឆ្វេងនិយម គឺត្រង់ចំណុចថា កាសែតនេះមិនមែនជាកាសែត ៗគាំទ្រនូវរបប -- គាំទ្រអយុត្តិធម៌ កាសែតនេះ ជាកាសែតប្រឆាំងនឹងអយុត្តិធម៌សង្គម។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងកត្តាមួយដែលលោកបញ្ជាក់ថា កាសែតរបស់ ឡុបសែវ៉ាទ័រៗគឺគាំទ្រអយុត្តិធម៌ ឬក៏គាំទ្រ -- ប្រឆាំងនឹងអយុត្តិធម៌។

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** សូមអធ្យាស្រ័យសូមលោកបញ្ជាក់សាថ្មី ថាលោកមានប្រសាសន៍ថា កាសែតឡុបសែវ៉ាទ័រ គឺប្រឆាំងទៅនឹងអំពីអយុត្តិធម៌ក្នុងសង្គម។ អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ កាសែតឡុបសែវ៉ាទ័រនេះ គឺមិនឆ្វេងចង្អៀក មិនគាំទ្រអយុត្តិធម៌សង្គម។

[១៥:៥៨:១៥]

**ស៖** សូមអរគុណ។ លោកមានកត្តាអ្វីបញ្ជាក់បន្ថែមទៀតទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** សូមលោកជួយឆ្លើយម្តងទៀត ដោយសារអំមិញអត់ទាន់បើកមីក្រូ!

**ឆ៖** ខ្ញុំមានតែយោបល់ប៉ុណ្ណឹង ពីព្រោះយូរហើយ ខ្ញុំភ្លេច។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការស្គាល់លោក ខៀវ សំផន ជាលក្ខណៈបុគ្គលអម្បាញ់មិញលោកបានឆ្លើយហើយថា លោកមិនបានសំណេះសំណាលនិយាយ ស្គាល់ជាលក្ខណៈផ្ទាល់ទេ គ្រាន់តែបានស្គាល់លោក។ អ៊ីចឹងខ្ញុំចង់ដឹងថា តើលោកមានចំណាប់អារម្មណ៍អ្វីចំពោះលោក ខៀវ សំផន ដែរទេនៅពេលតាំងពីដំណាក់កាលដែលលោកសរសេរកាសែត រហូតដល់លោកធ្វើជាមន្ត្រីរបស់រដ្ឋាភិបាលនោះក្នុងសម័យនោះ?

**ឆ៖** ខ្ញុំជា -- ពេលនោះ ខ្ញុំជាយុវជនមួយរូបដែលមានការកោតសរសើរ និងគោរពចំពោះលោក ខៀវ សំផន ពីព្រោះខ្ញុំយល់ឃើញថាគាត់ជាមនុស្សសាមញ្ញ គាត់ជិះម៉ូតូ។ ជាមនុស្សសាមញ្ញ ហើយ

គាត់ជាមនុស្សស្អាតស្អំ មិនពុករលួយ។ នេះអ្វីដែលខ្ញុំបានដឹងរហូតដល់គាត់បាត់ខ្លួនបាទ។

**ស៖** បាទសូមអរគុណ។ តើលោកដឹងពីមូលហេតុនៃការបាត់ខ្លួនរបស់គាត់នៅពេលនោះដែរទេ?

**ឆ៖** ខ្ញុំមិនដឹងទេបាទ។

**ស៖** ចុះលោកបានដឹងដំណឹងពីការបាត់ខ្លួនរបស់លោក ខៀវ សំផន ហ្នឹងដោយរបៀបណាដែរ?

**ឆ៖** កាលនុ៎ងមែន -- មិនមែនបាត់ខ្លួនតែលោក ខៀវ សំផន មួយទេ គឺបាត់ខ្លួនលោក ខៀវ សំផន, លោក ហ៊ូ យន់, លោក ហ៊ូ នឹម បើខ្ញុំមិនច្រឡំទេ បីនាក់នោះបាទ។ ហើយបាត់ខ្លួននោះក៏នៅក្នុងការៗងងឹតៗឈឹង គឺថាបាត់ដោយយ៉ាងម៉េច? បាត់ពេលណា? បាត់ថ្ងៃណា? អត់ដឹង។ ហើយ -- បាទ ប៉ុណ្ណឹងបាទ។

[១៦:០១:១៦]

**ស៖** បាទ សូមអរគុណ។ ចុះរហូតដល់ពេលណាទើបលោកដឹងដំណឹងពីការលេចរបស់វិញរបស់លោក ខៀវ សំផន?

**ឆ៖** ដឹងគឺនៅពេលក្រោយទម្លាក់សម្តេច សីហនុ បានដឹងថាលោក ខៀវ សំផន គាត់មិនមែនគេយកទៅណាមកណាទេ គឺគាត់រត់បាទ។ រត់ចូលព្រៃ គឺនៅក្រោយពេលសម្តេច គេទម្លាក់សម្តេច សីហនុ ពីតំណែងបាទ។

**ស៖** បាទ សូមអរគុណ។ ចុះលោកមានបានដឹងមូលហេតុដែលនាំឲ្យលោក ខៀវ សំផន រត់ចូលព្រៃនៅពេលនោះទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** សូមលោកចាំឆ្លើយម្តងទៀតបាទ។

**ឆ៖** ខ្ញុំមិនដឹងទេ ពីព្រោះពេលនោះខ្ញុំនៅបាត់ដំបងបាទ។

**ស៖** ខ្ញុំសូមសួរលោកទាក់ទងទៅនឹងទ្រង់ ភូរីស្សារា ដែលលោកមានប្រសាសន៍ថាលោកបានជួបនៅក្នុងមន្ទីរពេទ្យបាត់ដំបងក្រោយសម័យរំដោះ១៩៧៥មក។ នៅក្នុងអត្ថបទសៀវភៅរបស់លោក ត្រង់ ERN ជាភាសាខ្មែរលេខ 00678824, ជាភាសាអង់គ្លេស 00369729។ ត្រង់ទំព័រ៧៨ ក្នុងសៀវភៅរបស់លោក ហើយបញ្ចប់មកខាងក្រោយទំព័រ៧៩ បានន័យថាតែពីរបន្ទាត់ទេនៅខាងលើហ្នឹង។ ខ្ញុំសូមអានជូន "ទ្រង់ ភូរីស្សារា និយាយប្រាប់ខ្ញុំថា ខ្ញុំមិនប្រឆាំងបដិវត្តន៍ទេ តែខ្ញុំប្រឆាំងការសម្លាប់មនុស្ស។ គាត់បន្ថែមថា ខ្ញុំស្តាយណាស់ ខ្ញុំបាត់បង់ឱកាសមួយយ៉ាងធំ ដោយខ្ញុំមិនបានសុំសិទ្ធិជ្រកកោន

នៅប្រទេសថៃ កាលប្រតិភូកម្ពុជាប្រជាធិបតេយ្យ ដែលរួមមានខ្ញុំជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មានតែឈ្មោះផងនោះ ធ្វើទស្សនកិច្ចក្រុងបាងកក"។ ខ្ញុំសូមលោកជួយឆ្លើយថាតើទ្រង់ ភូរីស្សារា នេះជានរណាដែរ? អាចជួយជម្រាបពីប្រវត្តិសង្ខេបបន្តិចជូនអង្គជំនុំជម្រះផងបានទេ?

**ឆ៖** នៅជំនាន់សម្តេច សីហនុ, ទ្រង់ភូរីស្សារា បានធ្លាប់ធ្វើរដ្ឋមន្ត្រីជាច្រើនដង បើតាម បើខ្ញុំមិនច្រឡំទេបាទ។ ហើយព្រឹត្តិការណ៍ ដែលលោកមានប្រសាសន៍នេះ គឺនៅមួយខែក្រោយចូលឆ្នាំ ឆ្នាំ១៩៧៦ ពេលនោះគឺថា ខ្ញុំកំពុងតែធ្វើពលកម្ម កាប់ព្រៃដើម្បីដាំស្ពៃ ស្រាប់តែខ្ញុំឃើញឡានពើហ្សូមួយដឹកទ្រង់ដឹកមនុស្ស ហើយបើកទ្វារឃើញមនុស្សបីនាក់ចេញ ហើយគេនាំចូលក្នុងមន្ទីរពេទ្យចូលក្នុងបន្ទប់មួយ ហើយបន្ទាប់មកអ្នកបើកឡាននោះ គឺចេញមកខ្ញុំគឺអនុប្រធានតំបន់៣ នោះឯងបាទ បានមកប្រាប់ខ្ញុំថា សូមបងជួយព្យាបាលអ្នកជំងឺនេះផង។ ហើយខ្ញុំក៏លាងដៃ លាងជើង ហើយទៅជួបអ្នកជំងឺ ខ្ញុំមិនដឹងថាទ្រង់ ភូរីស្សារា ទេ ដល់ទៅស្រាបខ្ញុំឃើញទ្រង់ ភូរីស្សារា ខ្ញុំឃើញ ខ្ញុំភ្ញាក់ ហើយខ្ញុំលើកដៃសំពះគាត់ថា សូមជម្រាបសួរទ្រង់ ហើយគាត់ថា ខ្ញុំឈ្មោះ មិត្តមឿន។ ខ្ញុំគេឲ្យនៅស៊ីសុផុន ហើយខ្ញុំឈឺ ខ្ញុំសូមទៅភ្នំពេញ ប៉ុន្តែគេឲ្យខ្ញុំមកព្យាបាលនៅបាត់ដំបង។ ហើយទ្រង់ ភូរីស្សារា គាត់មានជំងឺគេហៅ ស្កន់ជ្រូកៗ ធុនស្រាលគឺថា ប្រកាច់ម្តងៗមិនដឹងខ្លួនបាទ បាត់ស្មារតី។

[១៦:០៧:១៤]

**ស៖** បាទ សូមអរគុណ។ ចំណុចដែលខ្ញុំចាប់អារម្មណ៍ ចង់សួរឲ្យលោកបញ្ជាក់នៅក្នុងអត្ថបទរបស់លោកនេះ គឺត្រង់ដែលគាត់បញ្ជាក់ថា គាត់ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌មានតែឈ្មោះ។ ខ្ញុំចង់សួរលោកបន្ថែមថា តើលោក តើទ្រង់ ភូរីស្សារា ហ្នឹងមានបានជម្រាបលោកថា ហេតុអ្វីបានជាលោកមានឋានៈជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មានតែឈ្មោះ មិនអាចមានអំណាចអីជាក់ស្តែងក្នុងការគ្រប់គ្រងក្រសួងក្នុងសម័យនោះ?

**ឆ៖** ក្នុងខណៈរដ្ឋមន្ត្រីខ្មែរក្រហម គឺយើងដឹងហើយថា រដ្ឋមន្ត្រីភាគច្រើនគ្មានអំណាចទេ មានតែឈ្មោះ។ ហើយដូចលោករដ្ឋមន្ត្រី ដូចជាលោកដុកទ័រ ជួន ជឿន អ៊ីចឹង គាត់ជាវេជ្ជបណ្ឌិត គាត់ជារដ្ឋមន្ត្រីក្រសួងសុខាភិបាល ប៉ុន្តែគាត់គ្មានតួនាទី គ្មានអំណាចអ្វីទេបាទ។ ហើយចំពោះទ្រង់ភូរីស្សារា គាត់ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ហើយជំនាន់ ប៉ុល ពត តើមានយុត្តិធម៌ឯណា? ហ្នឹងវាអ៊ីចឹងៗបានគាត់និយាយថា គាត់ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌មានតែឈ្មោះ ហើយគាត់បាននិយាយការសោកស្តាយរបស់គាត់ដែលគាត់មិនបានសុំភៀសខ្លួននៅថៃ នៅពេលដែលគណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យ បានទៅ

ទស្សនកិច្ចនៅថៃបាទ។ គាត់និយាយអ៊ីចឹងបាទ។

[១៦:០៩:១៧]

**ស៖** បាទ សូមអរគុណ។ តាមអ្វីដែលខ្ញុំបានស្តាប់លោកមានប្រសាសន៍បញ្ជាក់កន្លងមកអំពីគោលការណ៍ នៃការលាក់ការណ៍សម្ងាត់របស់កម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំចង់សួរបញ្ជាក់បន្ថែមថា ហេតុអ្វីបានជាទ្រង់ភូរីស្សារា និយាយប្រាប់លោកពីការខកចិត្តរបស់ទ្រង់ ដែលមិនបានសុំសិទ្ធិជ្រកកោននៅប្រទេសថៃនៅពេលនោះ ពីព្រោះថាចំណុចនេះវាអាចជាចំណុចក្តៅ ប៉ះពាល់សុវត្ថិភាពខ្លាំងមែនទែន?

**ឆ៖** ខ្ញុំយល់ថា សមាជិកនៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ពុំមែនស្រលាញ់ ប៉ុល ពត ទាំងអស់គ្នាទេ។ ហើយទ្រង់ភូរីស្សារា គាត់ៗហ៊ាននិយាយប្រាប់ខ្ញុំដោយត្រង់ៗអ៊ីចឹងតែម្តង។ ហើយនៅពេលដែលប្រធានភូមិភាគយកទ្រង់ភូរីស្សារា មកនៅមន្ទីរពេទ្យប្រគល់ឲ្យខ្ញុំព្យាបាល គាត់នៅជាង១ខែ គ្មានៗបុគ្គលិកពេទ្យខ្មែរក្រហមណាមកជិតទេ។ គឺអ្នកព្យាបាលមានតែខ្ញុំមួយគត់ ហើយអ្នកបម្រើបាយទឹកមានតែម្នាក់មួយគត់ដែរបាទ។ ហើយម្ហូបៗពិសេស គឺម្ហូបមានត្រីមានសាច់គ្រប់គ្រាន់ មានចាន មានស្លាបព្រា មានកែវ ប៉ុន្តែអត់មានសមទេបាទ។ ហើយគាត់មកនោះ មិនមែនម្នាក់គាត់ទេ គឺគាត់ទ្រង់ភូរីស្សារា ម្នាក់ ប្រពន្ធគាត់ ហើយនិងចៅគាត់ម្នាក់ទៀត។

[១៦:១១:០៣]

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរបញ្ជាក់បន្ថែមថា តើទ្រង់ភូរីស្សារា មានបានជម្រាបលោកពីមូលហេតុដែលនាំឲ្យលោកសុខចិត្តទទួលតំណែកជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដែរគ្មានអំណាចនោះដែរទេ?

**ឆ៖** ទ្រង់ភូរីស្សារា នៅពេលស្នាក់នៅមន្ទីរពេទ្យជាង១ខែ ខ្ញុំមិនដែលឃើញលោកញញឹមម្តងទេ គឺមុខក្រៀមជានិច្ច ទ្រង់ភូរីស្សារា បាទ។ ហើយគឺព្រលឹមឡើង ខ្ញុំឃើញគាត់កាន់អាវ៉ាដ្យូមួយ គាត់ស្តាប់ ប៊ី.ប៊ី.ស៊ី និង វិទ្យុបារាំង។ គាត់ស្តាប់អ៊ីចឹង ដើរស្តាប់អត់ខ្លាចនរណាទេ។ កាន់ស្តាប់វ៉ាដ្យូ ប៊ី.ប៊ី.ស៊ី ហើយនិងវ៉ាដ្យូបារាំង រាល់ព្រឹកបាទ។

**ស៖** អ៊ីចឹងទាក់ទងនឹងសំណួររបស់ខ្ញុំវិញ ថាតើលោកទ្រង់ភូរីស្សារា ហ្នឹងបានជម្រាបលោកពីមូលហេតុដែលកាន់អំណាច ដែលទទួលយកឋានៈជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដែរទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ! អត់ទាន់ ក្បាលមីក្រូមិនទាន់ប្រតិបត្តិការទេ។

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** គាត់មិនបានពន្យល់ខ្ញុំអំពីមូលហេតុដែលគេចាត់តាំងគាត់ជារដ្ឋមន្ត្រីទេ ហើយគាត់សួរខ្ញុំវិញ ម៉េចបានក្មួយឯងមកធ្វើ -- គាត់សួរខ្ញុំថា ម៉េចក្មួយឯងមកធ្វើការនៅនេះ? នៅមន្ទីរពេទ្យនេះ? ខ្ញុំប្រាប់គាត់ថា គេហៅខ្ញុំមក។ ខ្ញុំនិយាយប្រាប់គាត់ប៉ុណ្ណឹងបាទ។

[១៦:១២:៥៨]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីទំនងជានៅច្រើនសំណួរទេ? ទំនងជាមិនអាចចប់នៅរសៀលនេះទេ បើនៅច្រើនសំណួរទៀតគប្បីពិចារណា លើកបន្តទៅថ្ងៃសប្តាហ៍ក្រោយ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំនៅសល់មួយចំណុចទៀត ប្រហែលជាខ្លីទេ បើសិនជាលោកប្រធានអនុញ្ញាតបញ្ចប់តែម្តង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំសូមចូលចំណុចថ្មី ទាក់ទងទៅនឹងការឆ្លើយបញ្ជាក់របស់លោកថា លោកបានស្តាប់វិទ្យុនៅក្នុងអង្គប្រជុំមួយដែលមានលោក ខៀវ សំផន ជាអ្នកអានអត្ថបទរដ្ឋធម្មនុញ្ញ ហើយមានសម្តេចសីហនុ ធ្វើសេចក្តីថ្លែងពីមុនផងដែរនោះ មុននឹងនោះណ៎ា បាទ។ ខ្ញុំចង់សួរបញ្ជាក់ថា តើរដ្ឋធម្មនុញ្ញដែលលោកបានស្តាប់នៅពេលនោះ ជារដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ អនុម័តចប់សព្វគ្រប់ហើយ ឬក៏ជាសេចក្តីព្រាង?

[១៦:១៤:២០]

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** ខ្ញុំបាននិយាយពីម្សិលមិញដែរថា មុនដំបូងគឺសម្តេចនិយាយបាទ អំពីការលាលែងរបស់លោកជាភាសាខ្មែរ ក្រោយមកជាភាសាបារាំង។ បន្ទាប់មកបានឮការតែងតាំងលោក ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋ ឱ្យលោក ខៀវ សំផន អានរដ្ឋធម្មនុញ្ញ ដែលមានជាង២០មាត្រានោះបាទ។ ត្រង់ថា ខ្ញុំមិនជឿថា មាត្រានោះរដ្ឋធម្មនុញ្ញ ជារដ្ឋធម្មនុញ្ញជាពង្រាងទេ ព្រោះថា បើពង្រាងគេមិនអានតាមវិទ្យុទេ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីពេលវេលាបានទេថា នៅពេលនោះថ្ងៃខែឆ្នាំណាដែរ? សូមលោក--

**ប្រធានអង្គជំនុំ៖**

អត់ទាន់ៗ ក្បាលមីក្រូអត់ទាន់ប្រតិបត្តិការទេ។

**លោក ហ៊ុន ឈុនលី៖**

**ឆ៖** នៅពេលនោះ បើខ្ញុំមិនច្រឡំគឺនៅក្រោយពេលចូលឆ្នាំខ្មែរ ៧៦ បាទ។

**ស៖** បាទ សូមអរគុណ។ តើនៅក្នុងព័ត៌មាន មានបានបញ្ជាក់អំពីរបៀបធ្វើរដ្ឋធម្មនុញ្ញ ឬការតាក់តែងរដ្ឋធម្មនុញ្ញនោះដោយរបៀបណាដែរឬទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** សូមលោកជួយឆ្លើយម្តងទៀត!

**ឆ៖** នៅពេលនោះ គឺដូចខ្ញុំបានៗនិយាយម្សិលមិញ គេប្រជុំបុគ្គលិក គេហៅបុគ្គលិកមកជួបជុំគ្នាហើយ--

**ស៖** សូមទោស សូមលោកឆ្លើយតែទាក់ទងនឹងសំណួររបស់ខ្ញុំបានហើយ កុំឱ្យខាតពេលព្រោះយើងកាន់តែអស់ពេលហើយបាទ។

[១៦:១៦:១០]

**ឆ៖** គឺបុគ្គលិកពេទ្យទាំងអស់ រួមទាំងខ្ញុំស្តាប់វិទ្យុភ្នំពេញប្រកាស។

**ស៖** បាទ សំណួររបស់ខ្ញុំថា តើលោកបានដឹងអំពីរបៀបនៃការធ្វើរដ្ឋធម្មនុញ្ញនោះដែរឬទេ? វិទ្យុនៅពេលនោះមានបានផ្សព្វផ្សាយព័ត៌មានអំពីរបៀបធ្វើរដ្ឋធម្មនុញ្ញដែរឬទេ?

**ឆ៖** អត់មានទេបាទ អត់មានទេ។

**ស៖** អ៊ីចឹងមានន័យថា លោកក៏អត់ដឹងអំពីថានរណា ជាអ្នកគាត់តែងរៀបចំរដ្ឋធម្មនុញ្ញនោះដែរ ឬក៏អង្គការណាដែរអ៊ីចឹងមែនទេ?

**ឆ៖** បាទ ការងារធំៗ គេមិនដែលឲ្យប្រជារាស្ត្រដឹងទេបាទ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកសាក្សី។ ខ្ញុំអស់សំណួរលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្ដីលោក អៀង សារី តើត្រូវការពេលវេលាទំនងប្រហែលជាប៉ុន្មានក្នុងការសួរសាក្សីរូបនេះ?

[១៦:១៧:២៦]

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោកប្រធាន សូមជម្រាបសួរលោក លោកស្រីចៅក្រម និងសូមជម្រាបសួរអស់លោក លោកស្រីទាំងអស់នៅក្នុង និងក្រៅសាលសវនាការ។ ខ្ញុំគិតថា សាក្សីត្រូវត្រឡប់មកវិញនៅសប្ដាហ៍ក្រោយ ព្រោះគាត់ -- ខ្ញុំត្រូវការប្រហែលជា ១ម៉ោង ឬក៏ ១ម៉ោងជាងឯណោះ ដើម្បីធ្វើការសាកសួរទៅលើសក្ខីកម្មរបស់គាត់។ ដូច្នេះ ខ្ញុំគិតថា សាក្សីត្រូវតែត្រឡប់មកវិញនៅពេលក្រោយ ព្រោះខ្ញុំត្រូវការពេលវេលា។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ បាទ អរគុណសាក្សី។ ឥឡូវនេះ កិច្ចដំណើរការសវនាការថ្ងៃនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃអង្គារ ទី១១ ខែធ្នូ ឆ្នាំ២០១២ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃអង្គារ សប្ដាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មសាក្សី ហ៊ុន ឈុនលី បញ្ចប់ ហើយនិងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម TCW-307 ដែលនឹងចាប់ផ្ដើមសួរដេញដោល ដោយតំណាងសហព្រះរាជអាជ្ញាមុនភាគីដទៃទៀតនៃរឿងក្ដី។ សូមភាគី និងសាធារណជនជ្រាប។

[១៦:១៨:៣១]

លោក ហ៊ុន ឈុនលី ការស្ដាប់សក្ខីកម្មរបស់លោក នៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះ

នឹងបន្តធ្វើសក្ខីកម្ម -- ធ្វើសវនាការស្ដាប់សក្ខីកម្មរបស់លោក នៅថ្ងៃអង្គារ ទី១១ ខែធ្នូ គឺសប្ដាហ៍ក្រោយទៀត។ ដូច្នេះ អង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្ដល់សក្ខីកម្មនៅព្រឹកថ្ងៃអង្គារ ទី១១ ធ្នូ ទៀត។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រី នៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់វិញ និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញ នៅបន្ទប់សវនាការនេះនៅព្រឹកថ្ងៃអង្គារទី១១ ធ្នូ ២០១២ វេលាម៉ោងប្រាំបួនព្រឹក។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូប ត្រឡប់ទៅកាន់មន្ទីរឃុំឃាំង នៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃអង្គារទី១១ ខែធ្នូ ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ដោយឡែក លោក អៀង សារី ឲ្យនាំគាត់នៅត្រឹមបន្ទប់ឃុំខ្លួនពីខាងក្រោមសាលសវនាការនេះ ដែលរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:១៩ នាទី)*